សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royal de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រង និងការពារ ពូជដំណាំថ្មីនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ ៖ **ក. លី ពីន**
**ក. សាម ពិសី**

សាស្ត្រាចារ្យណែនាំ ៖
**បណ្ឌិត ឃីម គិរី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# លិខិតថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **លី ពីន** និងឈ្មោះ **សាម ពិសី** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ ២១ ឆ្នាំសិក្សា ២០២០-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច។

**សូមថ្លែងអំណរគុណជាអនេកប្បការចំពោះ**

-លោកឪពុក **សុខ ផលី** និង អ្នកម្តាយ **ស្រី គីមហុង**

-លោកឪពុក **សាម គួអូន** និង អ្នកម្តាយ **គង់ នេងលី**

កូនៗសូមថ្លែងអំណរគុណ និងអរគុណដល់លោកអ្នកមានគុណដ៏ឧដ្តុងឧត្តមជាទីបំផុតចំពោះកូនៗ ដែលលោកបានផ្តល់កំណើតដល់រូបយើងខ្ញុំ ហើយបានខិតខំលះបង់កម្លាំងញើសឈាមក្នុងការចិញ្ចឹមបីបាច់ថែរក្សាទំនុកបម្រុងរូបកូនៗទាំងស្មារតី និងសម្ភារៈជាពន់ពេក។ លើសពីនេះទៅទៀត លោកទាំងពីរបានអប់រំទូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌គឺ មេត្តា ករុណា មុទិតា និងឧបេក្ខា ដ៏ល្អប្រពៃពេញមួយជីវិតស្ទើរតែក្លាយជាមហាសមុទ្រ ដែលរូបយើងខ្ញុំជាកូនៗមិនអាចហែលឆ្លងបានឡើយ។ លោកទាំងពីរបានលះបង់ទ្រព្យធន ដែលលោកទាំងពីរបានខិតខំស្វែងរកក្រោមកម្តៅព្រះអាទិត្យសម្រាប់ធ្វើការឧបត្ថម្ភ និងលើកទឹកចិត្តមកលើរូបយើងខ្ញុំចំពោះការសិក្សាអស់រយៈពេល១៦ឆ្នាំ ចាប់តាំងពីថ្នាក់បឋមសិក្សារហូតដល់បញ្ចប់ថ្នាក់ឧត្តមសិក្សាប្រកបដោយភាពជោគជ័យត្រចះត្រចង់ និងមានវិជ្ជាជីវៈចំណេះជំនាញមួយច្បាស់លាស់ប្រកបដោយសីលធម៌ គុណធម៌ និងសច្ចធម៌សម្រាប់សង្គម។ ស្របពេលជាមួយគ្នានេះដែរ យើងខ្ញុំជាកូនៗ សូមធ្វើការក្រាបលំឱនកាយគោរពនូវមហាករុណា ទិគុណដ៏មហិមាទាំងអស់នេះដែលបានធ្វើឱ្យរូបយើងខ្ញុំជាកូនៗចងចាំជានិរន្តចំពោះការលះបង់គ្មានទីបញ្ចប់ និងដ៏ធំធេង ដើម្បីជួយជ្រោមជ្រែងជីវិតរបស់ពួកយើងខ្ញុំជាកូនៗបានទទួលនូវផ្លែផ្កាដែលជាលទ្ធផលដ៏វិសេសវិសាល សម្រាប់ជាទុនក្នុងការប្រកបរបរចិញ្ចឹមជីវិតក៏ដូចជាសកម្មភាពយ៉ាងសកម្មសម្រាប់ជួយអភិវឌ្ឍប្រទេសជាតិឱ្យស្របទៅតាមកាលានុវត្តភាពនៃទិដ្ឋភាពសង្គមផងដែរ។

លោកនាយក នាយករង លោកគ្រូ អ្នកគ្រូ នៃសាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យទាំងអស់ដែលបានបង្ហាត់បង្រៀន និងផ្តល់នូវចំណេះដឹងជាមូលដ្ឋានគ្រឹះសម្រាប់រូបយើងខ្ញុំជាសិស្សក្រេបយកចំណេះវិជ្ជា ដែលជាមាគ៌ាឱ្យរូបយើងខ្ញុំបានសម្រេចបន្តឆ្ពោះមកកាន់សាកលវិទ្យាល័យ។

ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ **លុយ ចន្ណា** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ព្រមទាំងបុគ្គលិកការិយាល័យស្រាវជ្រាវ ការិយាល័យសិក្សា នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងកិច្ច

ការដឹកនាំគ្រប់គ្រង ជាពិសេសគឺបង្ហាត់បង្រៀន ដើម្បីផ្តល់ចំណេះដឹងដែលជាទ្រព្យធនដ៏គាប់ប្រសើរ និងមានតម្លៃឥតគណនាសម្រាប់និស្សិតគ្រប់ៗរូបអោយទទួលបាននូវវិជ្ជាជីវៈផ្នែកច្បាប់បានច្បាស់លាស់ ដើម្បីជម្រុញឱ្យព្រះរាជាណាចក្រកម្ពុជាបានឈានទៅរកនីតិរដ្ឋមួយដ៏រឹងមាំសម្រាប់ប្រជាពលរដ្ឋ។

ជាពិសេស ស្នាដៃដ៏ស្រឡាងមួយនេះ បានលេចចេញជារូបរាងបានឡើងដោយសារតែមានការជួយជ្រោមជ្រែងពីលោកសាស្ត្រាចារ្យ **បណ្ឌិត ឃឹម គីរី** ដែលលោកបានខិតខំបង្ហាត់បង្រៀន ជួយផ្តល់ដំបូន្មានល្អ ព្រមទាំងជួយទំនុកបម្រុងក្នុងការស្រាវជ្រាវឯកសារផ្សេងៗ ដើម្បីយកមកធ្វើការចងក្រងជាសារណាបញ្ចប់ការសិក្សារបស់រូបយើងខ្ញុំយកមកប្រគល់ជូនសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ធ្វើការវាយតម្លៃនូវចំណេះដឹងរបស់រូបនាងខ្ញុំទាំងពីរនាក់ដែលបានសិក្សាអស់រយៈបួនឆ្នាំកន្លងមកនេះ។

លោក លោកស្រីបណ្ណារក្ស រាមច្បងនិស្សិតថ្នាក់នីតិសាស្ត្រ និងមិត្តរួមថ្នាក់ទាំងអស់ដែលបានជួយផ្តល់ជាមតិយោបល់ និងឯកសារដែលទាក់ទងទៅនឹងប្រធានបទនេះសម្រាប់ជាទុនក្នុងការធ្វើសារណានេះ ដើម្បីបន្សល់ទុកជាឯកសារបន្តសម្រាប់មិត្តនិស្សិតជំនាន់ក្រោយ។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរនាក់សូមធ្វើការខន្តីអភ័យទោសនូវរាល់ចំនុចអវិជ្ជមានទាំងឡាយ និងរួមទាំងពាក្យពេចន៍ អក្ខរាវិរុទ្ធដែលកើតមានឡើងដោយកំហុសអចេតនា ស្របពេលជាមួយគ្នានេះ យើងខ្ញុំសូមលើកដៃបួងសួងដល់វត្ថុស័ក្ខសិទ្ធទាំងអស់នៅក្នុងលោក ព្រមទាំងទេវតាទាំងប្រាំបីទិស ប្រសិទ្ធិពរជ័យ សិរីសួស្តីជ័យមង្គល វិបុលសុខគ្រប់ប្រការកើតមានដល់ចំពោះលោកអ្នកដែលមានគុណទាំងអស់ប្រកបដោយសេចក្តីសុខ និងសម្រេចនូវរាល់បំណងប្រាថ្នាទាំងពួង។

# អារម្ភកថា

យើងខ្ញុំទាំងពីរ សូមគោរពចំពោះលោកឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យ មិត្តអ្នកអាន និងនិស្សិតគ្រប់រូបដោយសេចក្តីគោរព និងសេចក្តីរាប់អាន។

ក្រោយពីបានសិក្សារយៈពេល៤ឆ្នាំ ផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំទាំងពីរនាក់បានសម្រេចចិត្តជ្រើសរើសការសរសេរសារណាសម្រាប់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រតាមឯកទេសដែលយើងខ្ញុំទាំងពីរនាក់បានសិក្សា។ គោលបំណងនៃការសរសេរសារណាបញ្ចប់ការសិក្សានេះ គឺដើម្បីពង្រឹង និងពង្រីកបន្ថែមនូវចំណេះដឹងដែលខ្លួនមាន សិក្សាបន្ថែមលើអ្វីដែលមានស្រាប់ ស្រាវជ្រាវលើអ្វីដែលខ្វះខាត និងចូលរួមជាចំណែកមួយក្នុងការចងក្រងឯកសារដែលទាក់ទងទៅនឹងប្រធានបទ សម្រាប់ជាចំណេះវិជ្ជាអោយយុវនិស្សិតជំនាន់ក្រោយបានដឹង និងសិក្សាស្វែងយល់ ដើម្បីជាស្ពានឆ្លោះទៅរកការអភិវឌ្ឍន៍។ យើងដឹងហើយថា ចំណេះវិជ្ជាជាប្រទីបបំភ្លឺផ្លូវសម្រាប់ជនគ្រប់រូបដែលនាំយើងទៅរកអ្វីដែលត្រូវមានវិចារណញ្ញាណមានហេតុផលនៅក្នុងការដោះស្រាយបញ្ហានានាបាន។

ប្រធានបទដែលយើងទាំងពីរនឹងលើកមកសរសេរគឺ " **ការគ្រប់គ្រង និងការពារពូជដំណាំថ្មីនៅកម្ពុជា** " ដែលស្ថិតនៅក្នុងកម្មសិទ្ធិឧស្សាហកម្មរបស់កម្មសិទ្ធិបញ្ញា។ ដោយយល់ឃើញថាវិស័យកម្មសិទ្ធិបញ្ញានៅកម្ពុជាមិនទាន់ទូលំទូលាយ ជាពិសេសផ្នែកកម្មសិទ្ធិឧស្សាហកម្មនេះ ទើបយើងខ្ញុំទាំងពីរនាក់ជ្រើសរើសប្រធានបទនេះឡើង ដើម្បីជាចំណែកមួយបន្ថែមចំណេះដឹងផ្នែកច្បាប់ដល់មិត្តអ្នកអាន ជាពិសេសគឺជួយអ្នកទាំងអស់គ្នានូវពុទ្ធិបន្ថែមទាក់ទងទៅនឹងការការពារ និងលក្ខខណ្ឌ ដើម្បីទទួលបានការការពារពូជដំណាំ និងទោសទណ្ឌនានាដែលអ្នកល្មើសត្រូវទទួលខុសត្រូវមុខច្បាប់ជាដើម។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរអរគុណចំពោះឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យ សិស្ស និស្សិត និងមិត្តអ្នកអានទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការយកចិត្តទុកដាក់អានសារណាមួយនេះ។ យើងខ្ញុំទាំងពីរនាក់ពិតជាមានសេចក្តីត្រេកអររកអ្វីប្រៀបពុំបាន មានតែការជូនពរឲ្យជួបប្រទះនូវសេចក្តីសុខ សេចក្តីចម្រើន និងទទួលជោគជ័យគ្រប់ភារកិច្ច ជាពិសេសពុទ្ធិពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

## សេចក្តីផ្តើម

ទំព័រ

១. លំនាំបញ្ហា........................................................................................ ១

២. ចំណោទបញ្ហា........................................................................................ ៣

៣. គោលបំណងនៃការស្រាវជ្រាវ........................................................................................ ៣

៤. ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ........................................................................................ ៤

៥. សារៈសំខាន់នៃការស្រាវជ្រាវ........................................................................................ ៤

៦. វិធីសាស្រ្តនៃការស្រាវជ្រាវ........................................................................................ ៤

៦.១ ការប្រមូលទិន្នន័យ........................................................................................ ៤

៦.២ វិធីសាស្រ្តក្នុងការវិភាគទិន្នន័យ........................................................................................ ៥

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ........................................................................................ ៥

## ជំពូកទី១

## យន្តការគ្រប់គ្រង និងការពារពូជដំណាំថ្មីនៅកម្ពុជា

**១.១ ៖ សញ្ញាណនៃការគ្រប់គ្រង និងការពារពូជថ្មីនៃដំណាំ**........................................................................................ ៧

១.១.១ និយមន័យ........................................................................................ ៧

១.១.២ គោលបំណង........................................................................................ ១០

១.១.៣ ចរិតលក្ខណៈ........................................................................................ ១១

១.១.៤ ប្រព្រឹត្តកម្មជាតិ........................................................................................ ១២

**១.២ ៖ លក្ខខណ្ឌនៃពូជដំណាំដែលអាចទទួលបាននូវកិច្ចការពារ**........................................................................................ ១២

១.២.១ ភាពថ្មី........................................................................................ ១២

១.២.២ ភាពខុសប្លែក........................................................................................ ១៣

១.២.៣ ឯកសណ្ឋានភាព........................................................................................ ១៤

១.២.៤ ស្ថេរភាព........................................................................................ ១៥

**១.៣ ៖ ការដាក់ពាក្យស្នើសុំការការពារ**........................................................................................ ១៥

១.៣.១ ការដាក់ឈ្មោះពូជដំណាំ........................................................................................ ១៥

១.៣.២ ករណីលើកលែងចំពោះពូជដំណាំដែលមិនទទួលបានការការពារ........................១៦
១.៣.៣ ការដាក់ពាក្យ និងសិទ្ធិអាទិភាព ........................................................................១៦
១.៣.៤ ការត្រួតពិនិត្យពាក្យស្នើសុំ និងការបោះពុម្ពផ្សាយ..............................................១៧
១.៣.៥ ភ្នាក់ងារដាក់ពាក្យសុំ ...................................................................................................១៨

## ជំពូកទី២

## សិទ្ធិអាទិភាព និង ឈាត្តិភាពនៃការគ្រប់គ្រង

**២.១ ៖ អានុភាពនៃការគ្រប់គ្រង និងការពារ**..............................................................១៩
២.១.១ សិទ្ធិអាទិភាពដែលទទួលបាន ..............................................................................១៩
២.១.១.១ កិច្ចការពារបណ្ដោះអាសន្ន ...............................................................................១៩
២.១.១.២ វិសាលភាពនៃសិទ្ធិអ្នកបង្កាត់ពូជដំណាំ ..............................................................១៩
២.១.១.៣ ការលើកលែងចំពោះសិទ្ធិអ្នកបង្កាត់ពូជដំណាំ....................................................២០
២.១.១.៤ ការកម្រិតការអនុវត្តសិទ្ធិអ្នកបង្កាត់ពូជដំណាំ........................................................២១
២.១.១.៥ រយៈពេលការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ ..........................................................២១
២.១.២ សិទ្ធិអនុញ្ញាតឲ្យតតិយជនធ្វើអាជីវកម្ម.................................................................២២
២.១.២.១ ការធ្វើអាជីវកម្មបានដោយការអនុញ្ញាត.................................................................២២
២.១.២.២ ការធ្វើអាជីវកម្មបានដោយមិនមានការអនុញ្ញាត.....................................................២៣
២.១.៣ សិទ្ធិហាមឃាត់ធ្វើអាជីវកម្ម ...................................................................................២៤
**២.២ ៖ ទោសបញ្ញត្តិ** .......................................................................................................២៥
២.២.១ ភ្នាក់ងារអធិការកិច្ចពូជដំណាំ....................................................................................២៥
២.២.២ វិធានការបណ្ដោះអាសន្ន...........................................................................................២៦
២.២.៣ ទណ្ឌកម្មនៃអំពើរំលោភសិទ្ធិនៃពូជដំណាំថ្មី..................................................................២៦
២.២.៣.១ សំណងរដ្ឋប្បវេណី..............................................................................................២៦
២.២.៣.២ ទោសព្រហ្មទណ្ឌ ...............................................................................................២៩
២.២.៣.៣ វិធានការរដ្ឋបាល ...............................................................................................៣០
**២.៣ ៖ ការបញ្ចប់ មោឃភាព និងការលុបចោល** ...........................................................៣០
២.៣.១ ការបញ្ចប់..............................................................................................................៣០

២.៣.២ មោឃភាព ........................................................................................................ ៣១

២.៣.៣ ការលុបចោល.................................................................................................... ៣១

## ជំពូកទី៣

## ស្ថាប័នអនុវត្តទៅលើការគ្រប់គ្រងពូជដំណាំថ្មី

៣.១ ៖ **ស្ថាប័នជាតិ** .............................................................................................. ៣២

៣.១.១ គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា.................................................... ៣២

៣.១.២ ក្រសួងពាណិជ្ជកម្ម.............................................................................................. ៣៤

៣.២ ៖ **ស្ថាប័នអន្តរជាតិ**.............................................................................................. ៣៦

៣.២.១ សហភាពអន្តរជាតិសម្រាប់ការការពារពូជដំណាំថ្មី ( UPOV ) ................................ ៣៦

៣.២.១.១ សញ្ញាណទូទៅនៃសហភាពអន្តរជាតិសម្រាប់ការការពារពូដំណាំថ្មី............ ៣៦

៣.២.១.២ រចនាសម្ព័ន្ធរបស់សហភាពអន្តរជាតិសម្រាប់ការការពារពូជដំណាំថ្មី ........... ៣៨

៣.២.១.៣ គោលការណ៍ទូទៅដើម្បីក្លាយជាសមាជិករបស់ UOPV.............................. ៤០

៣.២.២ វេទិកាការពារការបង្កាត់ពូជដំណាំអាស៊ីបូព៌ា ( EAPVP )...................................... ៤៣

៣.៣៖ **អង្គការនានាដែលពាក់ព័ន្ធនឹងការការពារពូជដំណាំថ្មី** ................................... ៤៥

៣.៣.១ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ( WTO ) ......................................................... ៤៥

៣.៣.១.១ ប្រវត្តិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក................................................. ៤៥

៣.៣.១.២ គោលបំណងរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក.................................. ៤៦

៣.៣.១.៣ រចនាសម្ព័ន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក.................................. ៤៨

៣.៣.២ ក្រុមប្រឹក្សា TRIPS ............................................................................................ ៥១

៣.៣.២.១ តួនាទីក្នុងការត្រួតពិនិត្យ និងការពិគ្រោះយោបល់................................... ៥២

៣.៣.២.២ ការពិនិត្យឡើងវិញ និងការចរចារស្តីពីកម្មវត្ថុជាក់លាក់............................. ៥២

៣.៣.២.៣ សហប្រតិបត្តិការខាងបច្ចេកទេស ......................................................... ៥២

**សេចក្តីសន្និដ្ឋាន** .................................................................................................. ៥៤

**អនុសាសន៍**............................................................................................................ ៥៦

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# តារាងអក្សរកាត់

| ល.រ | អក្សរកាត់ | ពាក្យពេញជាភាសាអង់គ្លេស | ពាក្យពេញជាភាសាខ្មែរ |
|---|---|---|---|
| ១ | ASSINSEL | International Association of Plant Breeders for the Protection of Plant Varieties | សមាគមន៍អ្នកបង្កាត់ពូជដំណាំសម្រាប់ការការពារពូជដំណាំ |
| ២ | APSA | American Political Science Association | សមាគមន៍វិទ្យាសាស្ត្រនយោបាយអាមេរិច |
| ៣ | BIRPI | United International Bureau for the Protection of Intellectual Property | ការិយាល័យអន្តរជាតិសម្រាប់ការការពារកម្មសិទ្ធិបញ្ញា |
| ៤ | BMT | Working Group on Biochemical and Molecular Technique and DNA-Profiling in Particular | ក្រុមការងារលើបច្ចេកទេសជីវគីមី និងម៉ូលេគុល និងការធ្វើទម្រង់ DNA ល្អិត |
| ៥ | BAT | Agreement between the United States of America and the Kingdom of Cambodia on Trade Relations and Intellectual Property Rights Protection | កិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងព្រះរាជាណាចក្រកម្ពុជា ស្តីពីការការពារកម្មសិទ្ធិបញ្ញា |
| ៦ | BTA | Bilateral Trade Agreement | កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី |
| ៧ | CAJ | Administrative and Legal Committee | គណៈកម្មាធិការរដ្ឋបាល និងនីតិកម្ម |
| ៨ | CAJ-AG | Administrative and Legal Committee-Advisory Group | ក្រុមប្រឹក្សាអមគណៈកម្មាធិការរដ្ឋបាល និងនីតិកម្ម |
| ៩ | CCIAR | Consultative Group on International Agricultural Research | ក្រុមប្រឹក្សាពិគ្រោះយោបល់លើការស្រាវជ្រាវកសិកម្មអន្តរជាតិ |

| | | | |
|---|---|---|---|
| ១០ | DUS | Distinct, uniform and stable (Plant variety) | ភាពប្លែក ឯកសណ្ឋាន និង ស្ថេរភាព |
| ១១ | EAPVP | The East Asia Plant Variety Protection Forum | វេទិកាការពារការបង្កាត់ពូជដំណាំ អាស៊ីអាគ្នេយ៍ |
| ១២ | IP | Intellectual Property | កម្មសិទ្ធិបញ្ញា |
| ១៣ | IPP | Intellectual Property Protection | ការការពារកម្មសិទ្ធិបញ្ញា |
| ១៤ | IPPC | Intellectual Plant Protection Convention | អនុសញ្ញាស្តីពីការការពារដំណាំ អន្តរជាតិ |
| ១៥ | IPRs | Intellectual Property rights | សិទ្ធិកម្មសិទ្ធិបញ្ញា |
| ១៦ | ISTA | International Seed Testing Association | សមាគមធ្វើតេស្តសាកល្បងពូជ ដំណាំអន្តរជាតិ |
| ១៧ | PBRs | Plant Breeders Rights | សិទ្ធិអ្នកបង្កាត់ពូជដំណាំ |
| ១៨ | PCT | Paten Cooperation Treaty | សន្ធិសញ្ញាសហប្រតិបត្តិការ ប្រកាសនីយបត្រតក្កកម្ម |
| ១៩ | PVP | Plant Variety Protection | ការការពារពូជដំណាំ |
| ២០ | TC | Technical Committee | គណៈកម្មាធិការបច្ចេកទេស |
| ២១ | TRIPS | Trade Related Aspects of Intellectual Property Rights | កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា |
| ២២ | TWA | Technical Working Party for Agricultural Crops | ក្រុមការងារសម្រាប់ដំណាំកសិកម្ម |
| ២៣ | TWO | Technical Working Party for Ornamental Plant and Forest Trees | ក្រុមការងារបច្ចេកទេសសម្រាប់រុក្ខជាតិតុបតែងលម្អ និងព្រៃឈើ |
| ២៤ | TWP | Technical Working Parties | ក្រុមការងារបច្ចេកទេស |
| ២៥ | UPOV | International Convention of the Protection of Plant and Varieties | អនុសញ្ញាសហព័ន្ធអន្តរជាតិ ការពារពូជថ្មីនៃដំណាំ |
| ២៦ | WIPO | World Intellectual Property Organization | អង្គការកម្មសិទ្ធិបញ្ញាពិភពលោក |

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ព្រះរាជាណាចក្រកម្ពុជា បច្ចុប្បន្នជាប្រទេសមួយដែលមានឯករាជ្យ សន្តិភាព ហើយជាប្រទេសមួយកំពុងតែអភិវឌ្ឍយ៉ាងខ្លាំងលើគ្រប់វិស័យទាំងអស់ ដូចជាបណ្តាប្រទេសដទៃទៀតនៅលើពិភពលោកយើងនេះដែលកំពុងតែមានភាពជឿនលឿនលើគ្រប់វិស័យទាំងអស់ ជាពិសេសគឺវិស័យពាណិជ្ជកម្មតែម្តង។ នាពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញថា ប្រជាពលរដ្ឋខ្មែរមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើវិស័យកម្មសិទ្ធិបញ្ញា ពីព្រោះមិនថាប្រទេសណាក៏ដូចប្រទេសណាដែរ សុទ្ធតែមានការលួចចម្លងនូវស្នាដៃគំនិតរបស់បុគ្គលដទៃ ទោះតិចក្តី ឬច្រើនក្តី វាជាទង្វើដែលនាំឱ្យប៉ះពាល់ដល់ផ្នែកសីលធម៌ ក៏ដូចជាផ្នែកសេដ្ឋកិច្ចរបស់តក្កករ ឬ ម្ចាស់សិទ្ធិ និងប៉ះពាល់សេដ្ឋកិច្ចជាតិផងដែរ គឺធ្វើអោយបាត់បង់នូវចំណូលជាតិមួយផ្នែកធំ ដូចនេះហើយទើបប្រទេសនីមួយៗចាំបាច់ត្រូវតែមានការបង្កើតនូវច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីការពារនូវស្នាដៃរបស់អ្នកច្នៃប្រឌិតថ្មី អ្នកផលិត និងអ្នកដែលបានរកឃើញនូវតក្កកម្មទាំងនោះ។

នៅក្នុងវិស័យកម្មសិទ្ធិបញ្ញាបានបែងចែកជាពីរផ្នែកគឺ កម្មសិទ្ធិឧស្សាហកម្ម និងកម្មសិទ្ធិអ្នកនិពន្ធ។ អនុសញ្ញាបង្កើតអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ឆ្នាំ១៩៦៧ បានចែងថា កម្មសិទ្ធិបញ្ញាត្រូវបានរាប់បញ្ចូលនូវសិទ្ធិដែលទាក់ទងនឹង ៖ ស្នាដៃអក្សរសាស្ត្រ សិល្បៈ និងវិទ្យាសាស្ត្រ, ការសម្តែងរបស់សិល្បៈករ ភាពយន្ត និងបណ្តាញការផ្សាយ, ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ, ការច្នៃប្រឌិតថ្មី, ការបង្កើតថ្មី, គំនូរឧស្សាហកម្ម, ម៉ាក, ការការពារប្រឆាំងនឹងការប្រកួតប្រជែងមិនស្មោះត្រង់, ម៉ាកបញ្ជាក់ទីតាំងភូមិសាស្ត្រ, ប្រកាសនីយបត្រតក្កកម្ម, Presentation and Research topic, Utility models, និងការបង្កាត់ពូជដំណាំថ្មី។ ទាក់ទងនឹងការបង្កាត់ពូជដំណាំថ្មី គឺជាចំណុចមួយដែលគួរអោយចាប់អារម្មណ៍ផងដែរ ដោយសារបណ្តាប្រទេសជាច្រើនលើពិភពលោកយល់ឃើញថាពូជដំណាំដែលបានបង្កើតតាមគំរូហ្សែនរុក្ខជាតិដែលមានស្រាប់ ឬបន្សុំគំរូហ្សែនរុក្ខជាតិមួយទៅរុក្ខជាតិមួយផ្សេង ដើម្បីបង្កើតបានរុក្ខជាតិថ្មីមួយប្រភេទ ដែលមានលក្ខណៈខុសប្លែក ឬផ្លាស់ប្តូរទាំងស្រុងតែម្តងពីប្រភេទរុក្ខជាតិចាស់វាមានភាពពិសេស។ លក្ខណៈដែលប្លែកនេះហើយ ដែលជាចំណុចមួយដែលជំរុញអោយប្រទេសដែលមានបច្ចេកវិទ្យាជឿនលឿន ក្នុងការបង្កើតនូវប្រភេទរុក្ខជាតិថ្មីជាច្រើន បានខិតខំស្វះស្វែងរកនូវការការពារស្នាដៃរបស់ខ្លួនដែលបានរកឃើញ។ ដោយសារកត្តាជំរុញខាងលើនេះទើបបណ្តាលអោយមានការបង្កើតនូវអនុសញ្ញាយូប៉ូវ **The International Union for the Protection of New Varieties of Plants (UPOV)** នេះឡើង ក្នុងគោលបំណងការពារដល់សិទ្ធិបុគ្គលដែលបានរកឃើញផង និងការពារពូជដំណាំផងដែរ។

ដោយយល់ឃើញថា ប្រទេសកម្ពុជាក៏ជាប្រទេសដែលមានកំណើនសេដ្ឋកិច្ចឿនលឿនមួយក្នុងតំបន់អាស៊ីអាគ្នេយ៍ ទើបរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ធ្វើយ៉ាងណាអោយគ្រប់វិស័យទាំងអស់មានការអភិវឌ្ឍតួយ៉ាងដូចជាវិស័យកម្មសិទ្ធិបញ្ញា ការការពារទៅលើការបង្កាត់ពូជដំណាំថ្មី ការចូលរួមរបស់រដ្ឋាភិបាលក្នុងវិស័យនេះ គឺខិតខំធ្វើយ៉ាងណាអោយប្រទេសកម្ពុជាជាចំណែកមួយនៃបណ្តាប្រទេសដែលជាសមាជិកអនុសញ្ញាយូប៉ូវ (UPOV) ទោះបីជាកម្ពុជាពុំទាន់បានចូលជាសមាជិកពេញសិទ្ធិក្តី ប៉ុន្តែកម្ពុជានឹងកំពុងតែខិតខំយ៉ាងខ្លាំងក្នុងការស្នើសុំចូលជាសមាជិកនៃអនុសញ្ញាមួយនេះ តាមរយៈអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ មិនត្រឹមតែធ្វើការសុំចូលជាផ្នែកមួយនៃអនុសញ្ញាយូប៉ូវប៉ុណ្ណោះទេ ប្រទេសកម្ពុជាក៏បានអនុម័តនូវច្បាប់មួយស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៨ ដើម្បីគ្រប់គ្រងទៅលើដំណើរការប្រព្រឹត្តទៅរបស់ម្ចាស់នៃសិទ្ធិ ក៏ដូចជាការធ្វើអាជីវកម្មទៅលើតក្កកម្មនោះផងដែរ។

ជាការពិតណាស់ យើងបានដឹងស្រាប់មកហើយថា ប្រទេសកម្ពុជាមានវិស័យកម្មសិទ្ធិបញ្ញាតាំងពីក្នុងកំឡុងទសវត្សទី៦០ និង ៧០ មកម្ល៉េះ ប៉ុន្តែដោយសារវិបត្តិនៃសង្គ្រាមស៊ីវិលរបបប្រល័យពូជសាសន៍ បានកើតឡើងទើបបណ្តាលឱ្យវិស័យកម្មសិទ្ធិបញ្ញាបាត់បង់ទៅវិញ តែយ៉ាងណាមិញបន្ទាប់ពីរបបមួយនេះបានបញ្ចប់ទៅប្រទេសកម្ពុជាបានទទួលនូវសេរីភាពសុខសន្តិភាពពេញលេញវិញ ដោយមានរដ្ឋធម្មនុញ្ញជាច្បាប់កំពូលបានអនុម័តនៅថ្ងៃទី២១ ខែ កញ្ញា ឆ្នាំ១៩៩៣ កម្ពុជាបានធ្វើការអភិវឌ្ឍ ពង្រឹង និងពង្រីកគ្រប់វិស័យឡើងវិញ ជាពិសេសគឺវិស័យកម្មសិទ្ធិបញ្ញា ដោយយោងតាមអនុសញ្ញាទីក្រុងប៉ារីស ឆ្នាំ ១៩៩១ វិស័យមួយនេះបានដំណើរការឡើងវិញ។ ក្រៅពីជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកនេះ កម្ពុជាបានចូលជាសមាជិកអង្គការអន្តរជាតិ និងបទដ្ឋានអន្តរជាតិ ដែលពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញាជាច្រើនចាប់តាំងពីឆ្នាំ ១៩៩៥ រហូតមកដល់បច្ចុប្បន្ននេះដែលមានទាំងអនុសញ្ញា សន្ធិសញ្ញា កិច្ចព្រមព្រៀង ពិធីសារផងដែរ និងកំពុងបន្តស្នើសុំចូលជាសមាជិកនៃអនុសញ្ញាចំនួន ៣ ទៀតបន្ថែម។ ការចូលជាសមាជិកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក កម្ពុជាត្រូវបំពេញនូវលក្ខន្តិកៈសិទ្ធិ និងកាតព្វកិច្ចជាច្រើន ព្រមទាំងត្រូវអនុម័តសម្រចបង្កើតនូវច្បាប់មួយចំនួនដូចជា ច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងថ្មីៗនេះកម្ពុជាបានអនុម័តនូវច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។ ការចូលជាសមាជិកនៃបទដ្ឋានអន្តរជាតិ ប្រទេសកម្ពុជាគឺត្រូវមានកាតព្វកិច្ចក្នុងការអនុវត្តតាមបទបញ្ញត្តិផ្សេងៗ ដែលបានចែងក្នុងគោលបំណងលើកកម្ពស់វិស័យកម្មសិទ្ធិបញ្ញាពិសេសនោះគឺ ការគ្រប់គ្រងពូជថ្មីនៃដំណាំផងដែរ ដោយធ្វើការលើកទឹកចិត្តដល់អ្នកបង្កាត់ពូជដំណាំថ្មីៗតាម

រយៈការបង្កើតឱ្យមានយន្តការនៃការការពារកម្មសិទ្ធិបញ្ញាលើពូជដំណាំដែលបានបង្កើតថ្មីទាំងនោះ។ ប្រសិនបើយើងក្រឡេកមើលមកព្រះរាជាណាចក្រកម្ពុជាយើងវិញ សព្វថ្ងៃនេះមានប្រភពចំណូលមួយផ្អែកបានពីវិស័យកសិកម្ម ក្នុងឆ្នាំ២០១៩ មានប្រជាពលរដ្ឋចំនួន ៧៥.១% រស់នៅតំបន់ជនបទ ក្នុងនោះភាគច្រើនប្រកបរបរកសិកម្មជាមុខរបរចម្បងសម្រាប់ចិញ្ចឹមជីវិត។[1]

## ២. ចំណោទបញ្ហា

តាមរយៈការសិក្សាស្វែងយល់ពីវិស័យកម្មសិទ្ធិបញ្ញាកន្លងមក ទាក់ទងនឹងការបង្កាត់ពូជដំណាំថ្មី និងព្រមទាំងមើលឃើញថា ប្រភពសេដ្ឋកិច្ចមួយភាគធំរបស់បងប្អូនប្រជាពលរដ្ឋខ្មែរគឺពឹងផ្អែកលើវិស័យកសិកម្មផងដែរនោះ ទើបញ៉ាំងឱ្យក្រុមខ្ញុំមានគំនិតក្នុងការសរសេរសារណានេះឡើងក្រោមប្រធានបទ " **ការគ្រប់គ្រង និងការពារពូជដំណាំថ្មីនៅកម្ពុជា** " ។ ដើម្បីធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទពាក់ព័ន្ធនឹងប្រធានបទដែលបានលើកយកមកនេះ ឱ្យកាន់តែមានភាពស៊ីជម្រៅ និងច្បាស់លាស់ថែមទៀតនោះ ចម្ងល់ដែលអ្នកសិក្សាចង់ដឹងនោះគឺ (១) តើលក្ខខណ្ឌនៃពូជដំណាំដែលទទួលបាននូវការការពារ និងការដាក់ពាក្យស្នើសុំមានដូចម្តេចខ្លះ? (២) តើអានុភាពទោសបញ្ញត្តិនៃការគ្រប់គ្រងពូជថ្មីនៃដំណាំយ៉ាងណាខ្លះ? (៣) តើប្រវត្តិ គោលបំណង និងរចនាសម្ព័ន្ធរបស់ស្ថាប័នជាតិ និងអន្តរជាតិដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងពូជថ្មីនៃដំណាំមានអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ជាការពិតណាស់ ដើម្បីឱ្យការសិក្សាស្រាវជ្រាវប្រកបដោយជោគជ័យ យើងត្រូវកំណត់គោលបំណងឱ្យបានច្បាស់ជាមុនសិន ដែលគោលបំណងទាំងនោះរួមមាន៖

- សិក្សាស្វែងយល់ពីសារតា គោលបំណង ព្រមទាំងចរិតលក្ខណៈនៃការគ្រប់គ្រងនិងការពារពូជថ្មីនៃដំណាំ
- សិក្សាស្វែងយល់អំពីលក្ខខណ្ឌ ដែលទទួលបានការការពារពូជដំណាំថ្មី
- សិក្សាស្វែងយល់អំពីនីតិវិធី នៃការដាក់ពាក្យស្នើសុំការការពារ
- សិក្សាស្វែងយល់ពីការអនុវត្តនូវសិទ្ធិដែលទទួលបាន និងស្ថាប័នដែលអនុវត្តនូវសិទ្ធិនៃការគ្រប់គ្រងពូជដំណាំថ្មី
- ចូលរួមចែករំលែកនូវចំណេះដឹងបន្ថែមទាក់ទងនឹងកម្មសិទ្ធិបញ្ញាស្តីពីពូជដំណាំថ្មី

[1] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២០

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវប្រធានបទស្តីពី " ការគ្រប់គ្រង និងការពារពូជដំណាំថ្មីនៅកម្ពុជា " ក្រុមយើងខ្ញុំបានផ្តោតសំខាន់ទៅកម្មសិទ្ធិបញ្ញាជាតិតែប៉ុណ្ណោះ ពោលគឺក្រុមខ្ញុំបានធ្វើការសិក្សាទៅលើតែច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ឆ្នាំ២០០៨ ដោយផ្អែកទៅលើឯកសារដែលមានជាក់ស្តែងតែប៉ុណ្ណោះយើងនឹងធ្វើការសិក្សាវែកញែក និងបកស្រាយនូវសេចក្តីលម្អិតនីតិវិធីទាំងអស់នៃការទទួលបានការការពារពូជដំណាំថ្មី។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះ បានជួយឱ្យយើងខ្ញុំទទួលបាននូវចំណេះដឹងបន្ថែមដែលផ្សារភ្ជាប់ពីការសិក្សាទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែង ពាក់ព័ន្ធលើការអនុវត្តគោលការណ៍ ការគ្រប់គ្រងទៅលើពូជថ្មីនៃដំណាំ និងការទទួលបាននូវសិទ្ធិការពារទៅលើពូជដំណាំនោះ ដែលជាចំណែកមួយក្នុងការចូលរួមលើកទឹកចិត្តដល់តក្កករដែលបានរកឃើញ ឬបង្កើតនូវអ្វីដែលថ្មី ពុំទាន់មានពីមុនមក ក៏ដូចជាចូលរួមលើកកម្ពស់វិស័យកម្មសិទ្ធិបញ្ញានៅកម្ពុជាឱ្យបានកាន់តែប្រសើរឡើង។ ជាពិសេសជាងនេះទៀត យើងខ្ញុំនឹងអាចបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានយ៉ាងជោគជ័យនាពេលខាងមុខផងដែរ។

លើសពីនេះទៅទៀត ការសិក្សាស្រាវជ្រាវមួយនេះនឹងបានផ្តល់ជាឧត្តមប្រយោជន៍យ៉ាងសំខាន់សម្រាប់សង្គមផងដែរ ជាពិសេសការចូលរួមផ្សព្វផ្សាយនូវប្រព័ន្ធកម្មសិទ្ធិបញ្ញាទាក់ទងការគ្រប់គ្រងពូជដំណាំ និងអ្នកបង្កាត់ពូជដំណាំថ្មី ឱ្យកាន់តែមានភាពទូលំទូលាយ ប្រកបដោយតម្លាភាព ដើម្បីជម្រុញឱ្យប្រព័ន្ធកម្មសិទ្ធិបញ្ញាមួយនេះកាន់តែមានភាពល្អប្រសើរ។

ក្រៅពីនេះ ការសិក្សាស្រាវជ្រាវនេះ នឹងផ្តល់ជាប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយសម្រាប់យកទៅសិក្សា និងស្រាវជ្រាវបន្តបន្ទាប់ទៀតបាន។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវជ្រាវនេះ គឺធ្វើឡើងតាមរបៀបពិពណ៌នាពន្យល់ (វិធីសាស្ត្រគុណភាព) និងប្រើនូវរូបភាពសម្រាប់ជាជំនួយក្នុងការបកស្រាយ និងបញ្ជាក់ឱ្យកាន់តែច្បាស់។

### ៦.១ ការប្រមូលទិន្នន័យ

ក្នុងសារណានេះ ទិន្នន័យទាំងអស់ ត្រូវបានប្រមូលតាមរបៀបទិន្នន័យបន្ទាប់បន្សំ (Secondary data) សម្រាប់ដកស្រង់យកទិន្នន័យសំខាន់ៗដែលពាក់ព័ន្ធ។ ទិន្នន័យបន្ទាប់បន្សំ (Secondary data) គឺសំដៅទៅលើប្រភេទទិន្នន័យស្រាវជ្រាវ ដែលប្រមូលបានតាមរយៈសៀវភៅ របាយការណ៍ ឯកសារផ្សេងៗជាច្រើនដូចជា៖

- សៀវភៅសារណា នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសេដ្ឋកិច្ច
- ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ឆ្នាំ ១៩៩១
- ឯកសាររបស់សមាគមន៍ជាតិនៃរុក្ខជាតិបង្កាត់ពូជ National Association of Plant Breeders
- មគ្គុទេសក៏សម្រាប់ការរៀបចំច្បាប់ផ្អែកលើច្បាប់ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ
- ឯកសារបានមកពីការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធើណេត បណ្ណាល័យ និងស្ថាប័ននានា។

### ៦.២ ការវិភាគទិន្នន័យ

បន្ទាប់ពីប្រមូលព័ត៌មាន និងទិន្នន័យរួចហើយ ក្រុមយើងខ្ញុំបានធ្វើការជ្រើសរើសព័ត៌មាន និងទិន្នន័យដែលពាក់ព័ន្ធ ដែលមានប្រយោជន៍សម្រាប់យកមកពិភាក្សាបកស្រាយលើលក្ខខណ្ឌ ក៏ដូចជានីតិវិធីក្នុងការទទួលបានការការពារ ព្រមទាំងលើកយកនូវទោសបញ្ញត្តិសម្រាប់អនុវត្តទៅលើបុគ្គលដែលល្មើសនឹងច្បាប់ដែលបានចែង និងធ្វើការបង្ហាញនូវស្ថាប័នជាច្រើនដែលពាក់ព័ន្ធនឹងការការពារពូជដំណាំថ្មី មានទាំងស្ថាប័នជាតិ ស្ថាប័នអន្តរជាតិ និងអង្គការនានា ដើម្បីឆ្ពោះទៅរកការសន្និដ្ឋានជារួម និងលើកជាអនុសាសន៍ ដើម្បីចូលរួមចំណែកក្នុងការកែលម្អ នូវចំណុចខ្វះខាតមួយចំនួនឱ្យកាន់តែមានភាពល្អប្រសើរថែមមួយកម្រិតទៀត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

អត្ថបទសារណាក្រោមប្រធានបទ “ **ការគ្រប់គ្រង និងការពារពូជដំណាំថ្មីនៅកម្ពុជា** ” ត្រូវបានបែងចែកជា ៥ ផ្នែកធំៗដូចជា៖

- **សេចក្តីផ្តើម៖** គឺជាផ្នែកដំបូងគេបង្អស់ដែលបរិយាយអំពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណង នៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងវិធីសាស្ត្រនៃការស្រាវជ្រាវ។
- **ជំពូកទី១ យន្តការគ្រប់គ្រង និងការពារពូជដំណាំថ្មីនៅកម្ពុជា៖** ក្នុងផ្នែកនេះ យើងនឹងលើកឡើងអំពីប្រវត្តិខ្លះរបស់កម្មសិទ្ធិបញ្ញា និងនិយមន័យរបស់ពូជដំណាំថ្មី ព្រមទាំងគោលបំណង និងចរិតលក្ខណៈនៃកិច្ចការពារពូជថ្មីនៃដំណាំ។
- **ជំពូកទី២ សិទ្ធិអាទិភាព និង ណត្តិភាពនៃការគ្រប់គ្រង៖** ផ្នែកនេះ យើងនឹងបង្ហាញអំពីសិទ្ធិមួយចំនួនដែលពាក់ព័ន្ធនឹងការការពារពូជថ្មីនៃដំណាំ និងការបញ្ចប់ មោឃភាព និងការលុបចោលនូវសិទ្ធិទាំងនោះ រួមទាំងសិក្សាទៅលើទោសបញ្ញត្តិដែលត្រូវអនុវត្តមានទាំងផ្នែករដ្ឋប្បវេណី ទោសព្រហ្មទណ្ឌ និងវិធានការរដ្ឋបាលផងដែរ។

- **ជំពូកទី៣ ស្ថាប័នអនុវត្តទៅលើការគ្រប់គ្រងពូជដំណាំថ្មី៖** ក្នុងផ្នែកនេះ យើងនឹងធ្វើការបង្ហាញអំពីប្រវត្តិរចនាសម្ព័ន្ធ ក៏ដូចជាគោលការណ៍ទូទៅរបស់ស្ថាប័នដែលពាក់ព័ន្ធនឹងការគ្រប់គ្រងពូជថ្មីនៃដំណាំ។
- **សេចក្តីសន្និដ្ឋាន និង អនុសាសន៍៖** ផ្នែកនេះជាចំណុចចុងក្រោយនៃអត្ថបទសារណានេះដែលសង្ខេបឡើងវិញនូវរាល់លទ្ធផលទាំងអស់ដែលទទួលបានមកពីការស្រាវជ្រាវ និងបង្ហាញអំពីអនុសាសន៍ ដែលជាដំណោះស្រាយសម្រាប់ដោះស្រាយបញ្ហាដែលបានកើតឡើងចំពោះការគ្រប់គ្រង និងការពារពូជដំណាំថ្មីនៅកម្ពុជា។

# ជំពូកទី ១
# យន្តការគ្រប់គ្រង និងការពារពូជដំណាំថ្មីនៅកម្ពុជា

# ជំពូកទី ១

# យន្តការគ្រប់គ្រង និងការពារពូជដំណាំថ្មីនៅកម្ពុជា

## ១.១ សញ្ញាណទូទៅនៃការគ្រប់គ្រង និងកិច្ចការពារពូជថ្មីនៃដំណាំ

### ១.១.១ និយមន័យ

យើងដឹងហើយថា កម្មសិទ្ធិបញ្ញាត្រូវបានបែងចែកជាពីរផ្នែកធំៗ ដែលរួមមានកម្មសិទ្ធិឧស្សាហកម្ម និងកម្មសិទ្ធិអ្នកនិពន្ធ។ សម្រាប់កិច្ចការពារពូជថ្មីនៃដំណាំ ក៏ទទួលបានការការពារជាកម្មសិទ្ធិបញ្ញាផងដែរ ដែលវាស្ថិតនៅក្នុងផ្នែកកម្មសិទ្ធិឧស្សាហកម្មរបស់កម្មសិទ្ធិបញ្ញា ហើយវាគឺជាការទទួលបានការការពារទៅលើរុក្ខជាតិ ឬ ដំណាំដែលគេបង្កាត់ចេញជាពូជថ្មីមួយទៀត។

ការបង្កាត់ពូជដំណាំតាមន័យទូទៅ គឺជាការបង្កាត់ពូជរុក្ខជាតិជាច្រើនចំរុះគ្នា កែលម្អហ្សែនរបស់រុក្ខជាតិ និង អភិវឌ្ឍរុក្ខជាតិទៅជារុក្ខជាតិថ្មីមួយទៀតដែលមានលក្ខណៈល្អបំផុត។ អ្នកបង្កាត់ពូជធ្វើការជ្រើសរើសពូជប្រភេទណាដែលមានសក្តានុពលធំ ដោយការជ្រើសរើសពឹងផ្អែកទៅលើទិន្នន័យដែលបានមកពីការវិវត្តនៃរុក្ខជាតិ និងព័ត៌មានពីហ្សែននោះ។




ខាងក្រោមនេះជានិយមន័យដែលផ្តល់ដោយជីវវិទូទៅលើការបង្កាត់ពូជរុក្ខជាតិៈ

- *"ការបង្កាត់ពូជថ្មីរុក្ខជាតិ គឺជាសិល្បៈនិងវិទ្យាសាស្ត្រនៃការកែលម្អហ្សែនរបស់រុក្ខជាតិ" ។ Fehr, Principles of Cultivar Development: Theory and Technique, 1987*
- *"ការបង្កាត់ពូជរុក្ខជាតិ គឺជាសិល្បៈនិងវិទ្យាសាស្ត្រនៃការផ្លាស់ប្តូរលក្ខណៈរបស់រុក្ខជាតិ ដើម្បីផលិត លក្ខណៈដែលចង់បាន" ។ Sleper and Poehlman, Breeding Field Crops, 1995*

- *"ការបង្កាត់ពូជរុក្ខជាតិ គឺជាការកែលម្អហ្សែនរបស់រុក្ខជាតិដើម្បីជាប្រយោជន៍ដល់មនុស្ស" ។ Bernardo, Breeding for Quantitative Traits in Plants, 2010* [2]

ដោយឡែកតាមការបកស្រាយនៅក្នុងអនុសញ្ញា UPOV "ការបង្កាត់ពូជដំណាំ ឬអាចហៅថាពូជថ្មីនៃដំណាំ គឺជាលទ្ធផលដែលបានមកពីគំរូហ្សែនរុក្ខជាតិ ឬ ការរួមបញ្ចូលគ្នានៃគំរូហ្សែនរុក្ខជាតិ ដោយការដាក់រុក្ខជាតិតាមលំដាប់ជាក្រុមៗ និងធ្វើការជ្រើសចេញពីក្នុងចំណោមប្រភេទតែមួយដែលមានលក្ខណៈរួមគ្នា ហើយមានលក្ខណៈខុសប្លែកពីក្រុមរុក្ខជាតិផ្សេងទៀត" ។ នេះសបញ្ជាក់ថាលទ្ធផលនៃការបង្កាត់ពូជដំណាំ មកពីការបែងចែកប្រភេទទាបបំផុតនៃ Plant Kingdom។




Plant Kingdom គឺសម្តៅទៅលើពពួករុក្ខជាតិទាំងអស់ដែលរួមមានទាំងពពួកបន្លែ ផ្លែឈើ វល្លិ៍ ផ្កា ស្មៅជាដើម។ Plant Kingdom ជាដំណាក់កាលទី១ នៃដំណើរការបង្កាត់ពូជដំណាំ។ រីឯ Species សម្តៅ ដល់ក្រុមរុក្ខជាតិ ឬពូជរុក្ខជាតិ ដែលមានលក្ខណៈស្រដៀងគ្នា ឬនៅក្នុងក្រុមតែមួយជាមួយគ្នា ទោះបីវាមានភាពខុសគ្នាទាំងរូបរាង ទំហំ និងពណ៌ខុសពីគ្នា។ Species ត្រូវបានគេចាត់ទុកថាជាចំណាត់ថ្នាក់រុក្ខជាតិទាបបំផុត របស់ Plant Kingdom។ កសិករ និងអ្នកដែលដាំដុះ បានកំណត់ច្បាស់លាស់ពីរុក្ខជាតិដែលពួកគេនឹងធ្វើការជ្រើសរើសសម្រាប់បង្កើតពូជដំណាំថ្មី ហើយពួកគេជ្រើសយករុក្ខជាតិប្រភេទណាមួយពី Species ដែលគេយល់ ថាលក្ខណៈពិសេសដែលចេញពីការបង្កាត់ពូជថ្មីនោះ ផ្តល់អោយពួកគេនូវរុក្ខជាតិមួយដែលអាចសម្របខ្លួននៅក្នុងបរិស្ថានដែលពួកគេធ្វើការដាំដុះ និងអាចទាញយកផលចំណេញសម្រាប់ការរស់នៅប្រចាំថ្ងៃពួកគេ។ ពូជថ្មីដែល

[2] https://www.plantbreeding.org/ (កាលបរិច្ឆេទចូលមើលថ្ងៃទី០១ ខែ ឧសភា ឆ្នាំ២០២១)

បង្កាត់ចេញពី Species ហៅថា Variety។ ពូជនៃដំណាំ (Variety) សម្តៅដល់រាល់ប្រភេទពូជដំណាំ ឬក្រុមផ្សេងៗនៃប្រភេទពូជដំណាំណាមួយដែលមានលក្ខណៈដូចគ្នា និងមានភាពខុសប្លែកពីរុក្ខជាតិដទៃដែលនៅក្នុងក្រុមតែមួយក្នុងលក្ខណៈមួយឬច្រើន ហើយដែលការប្រែប្រួលលក្ខណៈទាំងនេះនៅតែអាចរក្សាបានសម្រាប់យកទៅប្រើប្រាស់ធ្វើជាពូជដំណាំ ឬការបង្កាត់ជាសរីរាង្គដទៃទៀត។ ម្យ៉ាងវិញទៀត បើតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបានអោយនិយមន័យថាពូជថ្មីនៃដំណាំសម្តៅដល់ពូជដំណាំទាំងឡាយដែលទើបនឹងរកឃើញនិងអភិវឌ្ឍថ្មីៗដោយរុក្ខជម្រើសវិទូ ឬ អ្នកបង្កាត់ពូជដំណាំ[3] និងកាន់កាប់ផ្តាច់មុខយ៉ាងទូលំទូលាយក្នុងរយៈពេលមួយជាក់លាក់ ដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។[4]

តើអ្វីជាការការពារពូជថ្មីនៃដំណាំ?

កិច្ចការពារពូជថ្មីនៃដំណាំ ឬហៅថាសិទ្ធិរបស់អ្នកបង្កាត់ពូជ គឺជាទម្រង់មួយប្រភេទនៃកម្មសិទ្ធិបញ្ញាដែលបានផ្តល់សិទ្ធិឲ្យអ្នកបង្កាត់ពូជថ្មី។ ពូជ សំដៅដល់ក្រុមរុក្ខជាតិនៃចំណាត់ថ្នាក់តែមួយដែលគេស្គាល់តិចបំផុតទោះជាមិនបានបំពេញឱ្យបានពេញលេញនូវលក្ខខណ្ឌនៃការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំក្តីដែលអាចៈ

- ត្រូវកំណត់ដោយការបង្ហាញចរិតលក្ខណៈ ដែលជាលទ្ធផលនៃគំរូហ្សែន ឬ បន្សំគំរូហ្សែន
- ត្រូវខុសប្លែកពីក្រុមរុក្ខជាតិផ្សេងទៀត តាមរយៈការបង្ហាញយ៉ាងហោចណាស់នូវលក្ខណៈណាមួយនៃចរិតលក្ខណៈខាងលើហើយ
- ត្រូវចាត់ទុកជាក្រុមមួយ ចំពោះលទ្ធភាពដែលអាចដាំដុះបន្តដោយមិនផ្លាស់ប្តូរ។[5]

ប្រសិនបើអ្នកជាបុគ្គលដែលបង្កាត់ រកឃើញ និងអភិវឌ្ឍពូជថ្មីនៃដំណាំ អ្នកត្រូវបានចាត់ទុកថាជា "អ្នកបង្កាត់ពូជដំណាំ" ហើយអ្នកអាចស្វែងរកកិច្ចការពារពូជដំណាំថ្មីរបស់អ្នក ដោយដាក់ពាក្យសុំកិច្ចការពារទៅ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។[6] ដោយឡែក បើយោងតាមអនុសញ្ញា UPOV មាត្រា១(៤) បានឲ្យនិយមន័យថាៈ

---

[3] អ្នកបង្កាត់ពូជ ឬរុក្ខជម្រើសវិទូ សម្តៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការអភិរក្ស អភិវឌ្ឍ ឬបង្កាត់ ពិសោធន៍ សាកល្បង ជ្រើសរើស និងរំដោះពូជ ដំណាំ និងរុក្ខជាតិ ដើម្បីបុព្វហេតុបសិដ្ឋកម្មពូជដំណាំ ស្បៀង និងកសិកម្មប្រកបដោយនិរន្តរភាព។

[4] វាក្យស័ព្ទនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

[5] https://www.cambodiaip.gov.kh/TemplateTwo.aspx?parentId=45&menuid=291&childMasterMenuId=291(កាលបរិច្ឆេទចូលមើលថ្ងៃទី០១ ខែ ឧសភា ឆ្នាំ២០២១)

[6] https://www.cambodiaip.gov.kh/TemplateTwo.aspx?parentId=45&menuid=291&childMasterMenuId=291(កាលបរិច្ឆេទចូលមើលថ្ងៃទី០១ ខែ ឧសភា ឆ្នាំ២០២១)

- អ្នកបង្កាត់ពូជដំណាំ គឺជាអ្នកដែលបានបង្កាត់ ឬរកឃើញ ឬអភិវឌ្ឍពូជដំណាំ
- បុគ្គលដែលជានិយោជកនៃអ្នកដែលបានបង្កាត់ ឬរកឃើញ ឬអភិវឌ្ឍពូជដំណាំ
- សន្តតិជននៃបុគ្គលដែលបានរៀបរាប់ខាងលើ

បច្ចុប្បន្ននេះ វិស័យកសិកម្មជាវិស័យគោលសម្រាប់ប្រទេសនីមួយៗ ដែលធ្វើឲ្យវិស័យនេះមានការអភិវឌ្ឍយ៉ាងខ្លាំង។ ដូចនេះហើយ ការបង្កាត់ពូជដំណាំមានសារៈសំខាន់ណាស់សម្រាប់ជីវភាពប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗ និងសម្រាប់អ្នកដែលវិនិយោគទៅលើផ្នែកកសិកម្ម និងឧស្សាហកម្មដូចជា៖

- បង្កើតពូជដំណាំថ្មីៗ ដើម្បីចិញ្ចឹមមនុស្ស និងភពផែនដី
- បន្សាំដំណាំជាប្រភេទផ្សេងៗ ធ្វើឲ្យដំណាំមានច្រើនប្រភេទ និងសម្បូរបែប
- បំពេញតម្រូវការរបស់មនុស្ស ដោយអ្នកខ្លះត្រូវការបែបល្អើង ខ្លះគ្មានគ្រាប់។
- ដំណាំបង្កាត់ពូជខ្លះអាចបង្កើតទៅជាថាមពល (ជីវឥន្ធនៈ) , ឧស្សាហកម្ម (ស្ករស, ប្រេងធញ្ញជាតិ)
- ដើម្បីអភិវឌ្ឍវិស័យកសិកម្ម និងជនបទ ទាំងសាធារណៈ និងឯកជនតាមរយៈការនាំចូល និងនាំចេញទៅក្រៅប្រទេស
- បញ្ចេញផលិតផលដែលធ្វើឲ្យមានសុខភាពល្អសម្រាប់អ្នកប្រើប្រាស់ និងមានតំលៃសមរម្យទៅកាន់ទីផ្សារ
- ទទួលបាននូវពូជថ្មីដែលផ្តល់នូវទិន្នផលខ្ពស់ជាងមុន លឿនជាងមុន និងល្អជាងមុន សម្រាប់អ្នកដែលធ្វើការដាំដុះពូជនោះបង្កើតជម្រើសដល់អ្នកប្រើប្រាស់។[7]
- បង្កើតជម្រើសដល់អ្នកប្រើប្រាស់
- សម្រាប់លម្អទីក្រុង
- មិនធ្វើអោយរុក្ខជាតិមួយចំនួនផុតពូជ ឧទាហរណ៍៖ ប្រភេទរុក្ខជាតិធម្មជាតិដែលគេប្រើសម្រាប់ធ្វើ ឱសថ។

### ១.១.២ គោលបំណង

កាលពីឆ្នាំ១៩៩៨ ប្រទេសកម្ពុជាបានចេញអនុក្រឹត្យមួយពាក់ព័ន្ធនឹងការការពារពូជដំណាំ គឺអនុក្រឹត្យស្តីពីស្តង់ដា និងការគ្រប់គ្រងសម្ភារៈកសិកម្ម។ បន្ទាប់មកដោយមានការជួយជ្រោមជ្រែងលើបច្ចេកទេសពី អង្គការ UPOV កម្ពុជាបានរៀបចំសេចក្តីព្រាងច្បាប់នានាទាក់ទងនឹងការការពារពូជដំណាំ និងការបង្កើតសៀវភៅ មួយដែលមានចំណងជើងថា "មគ្គុទេសក៍សម្រាប់ការរៀបចំច្បាប់ផ្អែកលើច្បាប់ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ" ដែល

[7] https://www.upov.int/edocs/mdocs/upov/en/upov_trainer_en_16/upov_trainer_en_16_world_cafe_1.pdf (កាលបរិច្ឆេទចូលមើលថ្ងៃទី០១ ខែ ឧសភា ឆ្នាំ២០២១)

ទាំងអស់នេះហើយ ធ្វើអោយប្រទេសកម្ពុជាបង្កើតបានសមិទ្ធិផលមួយឡើង គឺច្បាប់ស្ដីពីការការពារពូជថ្មី នៃដំណាំត្រូវបានអនុម័តឲ្យប្រើប្រាស់នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៨ ដោយរួមមាន៩ជំពូក និងមាន៨៤ មាត្រា។

ច្បាប់នេះបង្កើតឡើងក្នុងគោលដៅគ្រប់គ្រង និងត្រួតពិនិត្យលើការបង្កាត់ បញ្ចេញឲ្យប្រើការផលិត ការកែច្នៃ ការចុះបញ្ជី ការចែកចាយ ការនាំចូល នាំចេញ ពូជដំណាំថ្មី និងគោលបំណងធានានូវការគ្រប់គ្រង ការលើកទឹកចិត្តនិងការអភិវឌ្ឍពូជដំណាំដោយនិរន្តភាព ដើម្បីប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន។[8] ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលពឹងផ្អែកទៅលើវិស័យកសិកម្ម ហើយការបង្កើតច្បាប់នេះឡើង ក៏ជាផ្នែកមួយដែលធ្វើអោយវិស័យកសិកម្មកាន់តែរីកចម្រើនថែមទៀត។ ម្យ៉ាងវិញទៀត ច្បាប់ថ្មីនេះ បានលើកទឹកចិត្តឲ្យអ្នកដែលមានធនធាន ឬអ្នកដែលមានគំនិតច្នៃប្រឌិតធ្វើការពិសោធន៍ និងស្រាវជ្រាវរកពូជថ្មីល្អៗ ដែលមិនទាន់រកឃើញពីមុន ហើយរដ្ឋាភិបាលនឹងចេញលិខិតសម្គាល់ការការពារសិទ្ធិលើអ្វីដែលពួកគេរកឃើញ ដោយពួកគេគ្រាន់តែបំពេញទៅតាមលក្ខខណ្ឌដែលស្របតាមច្បាប់តែប៉ុណ្ណោះ។ យោងតាមលិខិតសម្គាល់នេះ គឺគេមិនអាចអោយមានការកេងប្រវ័ញ្ចនៃពូជដែលត្រូវបានការពារ និងតម្រូវអោយមានការបង្កាត់ពូជ លុះត្រាតែមានការអនុញ្ញាតជាមុនពីអ្នកបង្កាត់ពូជនេះ។

### ១.១.៣ ចរិតលក្ខណៈ

កិច្ចការពារពូជថ្មីនៃដំណាំ បង្កើតឡើងសម្រាប់ការពារចំពោះម្ចាស់សិទ្ធិដែលរកឃើញពូជថ្មីនោះ។ វិសាលភាពនៃកិច្ចការពារនេះ ធ្វើឲ្យម្ចាស់សិទ្ធិមានសិទ្ធិរារាំងបុគ្គលដទៃពី៖

- ការផលិត ឬផលិតឡើងវិញនៃពូជដំណាំ
- ការដាក់លក្ខខណ្ឌក្នុងគោលបំណងនៃការដាំដុះ
- ការដាក់លក់ ឬចរាចរណ៍ផ្សេងៗ
- ការនាំចូល
- ការនាំចេញ
- ការស្តុកទុកនៅក្នុងគោលបំណងណាមួយ។

---

[8] មាត្រា១ និងមាត្រា២ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០០៨

បន្ថែមពីនេះទៅទៀត សុពលភាពសិទ្ធិការពារពូជថ្មីនៃដំណាំមានរយៈពេល២០(ម្ភៃ)ឆ្នាំ លើកលែងតែដំណាំដែលមានលក្ខណៈពិសេសដូចជាដំណាំវល្លិ និងដំណាំឈើដែលត្រូវមានរយៈពេល២៥(ម្ភៃប្រាំ)ឆ្នាំ ក្រោយពីទទួលបានសិទ្ធិការពារលើពូជថ្មីនៃដំណាំនោះ។ រយៈពេលដែលច្បាប់ផ្តល់ឲ្យនេះ ស្ថិតក្នុងកំឡុងពេល យូរធ្វើអោយម្ចាស់សិទ្ធិនេះទទួលបានអត្ថប្រយោជន៍ជាច្រើន។

### ១.១.៤ ប្រព្រឹត្តកម្មជាតិ

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានបង្កាត់ ឬរកឃើញ និងអភិវឌ្ឍពូជថ្មីនៃដំណាំ ហើយមានបំណងការពារកម្មសិទ្ធិលើពូជថ្មីនោះ ត្រូវដាក់ពាក្យស្នើសុំនៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលត្រូវបញ្ជូនឯកសារនោះទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសិក្សាវាយតម្លៃអំពីលទ្ធផលបច្ចេកទេសដោយអនុលោមតាមបទបញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។ បន្ទាប់ពីទទួលបានលិខិតបញ្ជាក់លទ្ធផលនៃការសិក្សាវាយតម្លៃបច្ចេកទេសពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទើបក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ផ្តល់វិញ្ញាបនបត្របញ្ជាក់ពីសិទ្ធិការពារពូជថ្មីនៃដំណាំ។[9] សម្រាប់វិញ្ញាបនបត្រនេះ មានអានុភាពការពារត្រឹមតែដែនដីនៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ទោះបីច្បាប់នេះមានលក្ខណៈស្រដៀងគ្នាទៅនឹងច្បាប់ដែលមានចែងក្នុង UPOV ក៏ដោយ តែដោយសារប្រទេសកម្ពុជាពុំទាន់ក្លាយជាសមាជិកពេញសិទ្ធិរបស់ UPOV នៅឡើយទេ ដែលបច្ចុប្បន្នប្រទេសកម្ពុជាគ្រាន់តែជាសមាជិកសង្កេតការប្រចាំនៅក្រុមប្រឹក្សានៃសហភាពនេះប៉ុណ្ណោះ។

## ១.២ លក្ខខណ្ឌនៃពូជដំណាំដែលអាចទទួលបាននូវកិច្ចការពារ

ការបង្កាត់ចេញជាពូជថ្មីមិនទទួលបានការការពារឡើយ ប្រសិនបើពូជនោះមិនស្របទៅតាមលក្ខខណ្ឌគតិយុត្តនោះទេ។ ដូច្នេះ ដើម្បីអោយពូជដំណាំមួយអាចទទួលបាននូវការការពារ ពូជនោះត្រូវបានគេវិនិច្ឆ័យទៅលើលក្ខណៈទាំងបួនរបស់វាដែលរួមមាន ភាពថ្មី (Novelty), ភាពខុសប្លែក (distinctness) , ឯកសណ្ឋានភាព (Uniformity) និង ស្ថេរភាព (Stability)។

### ១.២.១ ភាពថ្មី ( Novelty )

[9] មាត្រា១១ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

ដំបូងបំផុតនៃដំណើរការវិនិច្ឆ័យទៅលើលក្ខណៈនៃពូជដំណាំដែលចង់ទទួលបាននូវការការពារ គឺគេពិនិត្យទៅលើភាពថ្មី។ ភាពថ្មី តាមន័យទូទៅ ត្រូវបានគេប្រើទៅលើវត្ថុ ឬឧបករណ៍ប្រើប្រាស់ផ្សេងៗដែលគេមិនធ្លាប់បានប្រើ ឬមិនធ្លាប់បានឃើញពីមុនមក។ ប៉ុន្តែអត្ថន័យនៃពាក្យនេះត្រូវបានគេកំណត់ផ្សេងៗពីគ្នា តួយ៉ាងនៅក្នុងម៉ូដែលមានអត្ថប្រយោជន៍បានកំណត់ថាភាពថ្មី គឺថ្មីទៅលើតក្កកម្មដែលមានស្រាប់ ដោយតក្កកម្មគ្រាន់តែមានការអភិវឌ្ឍទៅលើបច្ចេកទេស កែប្រែទៅលើរូបរាង ហើយបន្ថែមនូវតួនាទីច្រើនជាងមុន ឬទំនើបជាងមុន។ ដោយឡែកនៅក្នុងលក្ខខណ្ឌសម្រាប់ផ្តល់ទៅលើពូជថ្មីដែលទទួលបានការការពារវិញ ភាពថ្មីនេះត្រូវបានគេបកស្រាយថា ពូជដំណាំដែលអាចចាត់ទុកថាថ្មី លុះត្រាតែពុំទាន់បានដាក់លក់ ឬចរាចរលើទីផ្សារកន្លងមក ប៉ុន្តែដោយមានការឯកភាពពីអ្នកបង្កាត់ពូជពូជថ្មីនៃនោះត្រូវបានដាក់លក់ ឬចរាចរលើទីផ្សារ ក្នុងរយៈពេលមិនលើសពី១ឆ្នាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមិនលើសពី៦ឆ្នាំ ចំពោះដំណាំវល្លិ និងដំណាំឈើ និងមិនលើសពី៤ឆ្នាំ ចំពោះគ្រប់ដំណាំផ្សេងៗទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជា ដោយគិតមកដល់ថ្ងៃដាក់ពាក្យស្នើសុំសិទ្ធិការពារ។ ដូចគ្នានេះដែរ នៅក្នុងមាត្រា៦ ជំពូកទី៣ នៃអនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារពូជថ្មីនៃដំណាំ ក៏មានចែងនូវអត្ថន័យនៃភាពថ្មីនេះដែរ ដែលអត្ថន័យន័យពាក្យថ្មីក្នុង UPOV មានលក្ខណៈដូចគ្នានឹងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាដែរ។ លក្ខណៈដូចគ្នានឹង លិខិតតុបករណ៍អន្តរជាតិនេះ ដោយសារតែច្បាប់នៃប្រទេសកម្ពុជាទទួលបានការប្រឹក្សាផ្នែកច្បាប់ពីអ្នកជំនាញមកពី UPOV និងលិខិតគតិយុត្តដែលមានស្រាប់។

**១.២.២ ភាពខុសប្លែក** ( Distinctness )

កិច្ចការពារពូជថ្មីនៃដំណាំ វិនិច្ឆ័យលក្ខណៈទី២ទៅលើភាពខុសប្លែក។ ពូជដំណាំដែលចាត់ទុកថាមានភាពខុសប្លែកពីគេ លុះត្រាតែមានភាពខុសគ្នាដាច់ស្រឡះពីពូជឯទៀត ដែលគេស្គាល់ជាទូទៅត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំសិទ្ធិ ឬកាលបរិច្ឆេទសិទ្ធិអាទិភាព។[10] កាលបរិច្ឆេទសិទ្ធិអាទិភាព ជាកាលបរិច្ឆេទ ដែលបានដាក់ក្នុងសំណុំលិខិតស្នើសុំមុនគេបង្អស់ដែលប្រើប្រាស់សម្រាប់ធ្វើជាមូលដ្ឋានក្នុងការទទួលបាន សិទ្ធិអាទិភាព ដូចដែលមានចែងក្នុងអនុសញ្ញាទីក្រុងប៉ារីស ឆ្នាំ១៩៦៧។ សម្រាប់សមាជិកអង្គការអន្តរជាតិ UPOV វិញ គេបង្កើតឲ្យមានកម្មវិធីមួយហៅថា "DUS Examination" ដែលវាជាគោលការណ៍មួយដែលមាន មន្ត្រីជំនាញ ធ្វើការត្រួតពិនិត្យ និងវាយតម្លៃទៅលើលក្ខណៈទាំង៣នៃពូជ ដែលទាមទារការការពារដូចជា ភាពខុសប្លែក

[10] មាត្រា៨ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

(distinctness), ឯកសណ្ឋានភាព (Uniformity) និង ស្ថេរភាព (Stability) ហើយសមាជិកភាពនៃសហភាពយ៉ូប៉ូវ អាចប្រើប្រាស់លទ្ធផលនោះ សម្រាប់បំពេញក្នុងលក្ខណៈវិនិច្ឆ័យក្នុងការសុំការការពារពូជថ្មីនៃដំណាំបាន ។

**១.២.៣ ឯកសណ្ឋានភាព** ( Uniformity )




លក្ខណៈវិនិច្ឆ័យទី៣នោះគឺ ឯកសណ្ឋានភាព។ ពូជដំណាំដែលចាត់ទុកថាមានឯកសណ្ឋានភាព លុះត្រាតែអាចរក្សាឯកសណ្ឋានភាពគ្រប់គ្រាន់នូវចរិតលក្ខណៈពាក់ព័ន្ធរបស់ពូជ ទោះបីពូជដំណាំនោះត្រូវបានផលិតតាមរយៈភេទ[11] ឬអភេទក្តី[12]។[13] ដើម្បីដឹងថាពូជដំណាំមួយមានឯកសណ្ឋានភាពឬអត់ គេត្រូវឆ្លងការពិសោធន៍នៅមន្ទីរពិសោធន៍ ឬក៏អាចធ្វើការស្នើសុំធ្វើការវាយតម្លៃតាម DUS Examination ក៏បាន។ ការពិសោធន៍ នោះត្រូវធ្វើតាមដំណាក់កាល ដើម្បីឲ្យច្បាស់ថាទទួលបានពូជដំណាំនោះតាមជំនាន់នីមួយៗរបស់វា។




[11] ពូជដំណាំដែលផលិតដោយភេទ គឺជាប្រភេទរុក្ខជាតិមានគ្រាប់ ហើយផ្ការបស់វាមានកេសរញី និងកេសរឈ្មោល និងមានការចូលរួមពីកាម៉េតញី និងកាម៉េតឈ្មោល។

[12] ពូជដំណាំដែលផលិតដោយអភេទ គឺជាប្រភេទរុក្ខជាតិដែលអត់គ្រាប់ ហើយវាបន្តពូជតាមស្លឹក ដើម មែក និងមានស្ប៉ និងគ្មានការចូលរួមពីកាម៉េតញី និងកាម៉េតឈ្មោលទេ។

[13] មាត្រា៩នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

**១.២.៤ ស្ថេរភាព** ( Stability )

មិនខុសពីឯកសណ្ឋានភាពទេ លក្ខណៈវិនិច្ឆ័យចុងក្រោយក្នុងការទទួលបានការការពារពូជដំណាំនោះគឺស្ថេរភាព ដែលការវិនិច្ឆ័យទៅលើស្ថេរភាពទាមទារអោយឆ្លងកាត់ការពិសោធន៍ផងដែរ។ លទ្ធផលនៃការពិសោធន៍ជោគជ័យលុះត្រាតែពូជដំណាំតាមជំនាន់នីមួយៗត្រូវមានស្ថេរភាព ដែលវាមិនត្រូវខុសពីពូជដើមរបស់វាឡើយ។ មាត្រា១០ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជក៏បានចែងដែលថា **"ពូជដំណាំ ដែលចាត់ទុកថាមានស្ថេរភាព លុះត្រាតែចរិតលក្ខណៈចាំបាច់របស់វាគ្មានការប្រែប្រួលនៅគ្រប់ដំណាក់កាលនៃ វដ្តលូតលាស់ និងជំនាន់នីមួយៗ"** ។




## ១.៣ ៖ ការដាក់ពាក្យស្នើសុំការការពារ

នៅក្នុងផ្នែកនេះ យើងនឹងលើកយកមកសិក្សាអំពីការដាក់ឈ្មោះពូជដំណាំដែលបានរកឃើញរួមទាំងប្រភេទពូជដំណាំដែលពុំទទួលបាននូវការការពារផងដែរ និងធ្វើការសិក្សាលើនីតិវិធីនៃការដាក់ពាក្យស្នើសុំការការពារ និងសិទ្ធិអាទិភាពដែលទទួលបានក្រោយពីទទួលបានការការពារដែលច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់ដល់ម្ចាស់នៃពូជដំណាំ នៅក្នុងនីតិវិធីនៃការដាក់ពាក្យសុំក៏ចាំបាច់ត្រូវមានការត្រួតពិនិត្យទៅលើពាក្យស្នើសុំឱ្យបានល្អិតល្អន់ ច្បាស់លាស់ថាត្រឹមត្រូវគ្រប់លក្ខខ័ណ្ឌិកៈដែលច្បាប់បានចែង រួចទើបធ្វើការផ្សព្វផ្សាយជាសាធារណៈ និងចុងក្រោយការដាក់ពាក្យស្នើសុំអាចត្រូវធ្វើដោយបុគ្គលរូបណាខ្លះ ដែលមានសិទ្ធិក្នុងការដាក់ពាក្យស្នើសុំ។

**១.៣.១ ការដាក់ឈ្មោះពូជដំណាំ**

ការដាក់ឈ្មោះពូជដំណាំ គឺជាការប្រើសម្រាប់សម្គាល់ ឬ ញែកប្រភេទពូជដំណាំមួយទៅនឹងប្រភេទពូជផ្សេងទៀត។ ដោយអ្នកបង្កាត់ពូជដំណាំត្រូវធ្វើការស្នើសុំការអនុញ្ញាត ដើម្បីដាក់ឈ្មោះពូជដំណាំដែលសមស្រប

សម្រាប់កំណត់ពូជដំណាំ។ ឧទាហរណ៍៖ ឈ្មោះ “ Summer Snow ” ជាឈ្មោះរបស់រុក្ខជាតិមួយប្រភេទ របស់ Rosa ដែលនៅក្នុងប្រទេសដែលជាសមាជិកមួយនៃអនុសញ្ញាយ៉ូប៉ូវ។[14]

ការដាក់ឈ្មោះត្រូវតែអាចសម្គាល់ពូជដំណាំបាន ហើយការដាក់ឈ្មោះមិនត្រូវមានសញ្ញាតែមួយទេ លើកលែងសញ្ញានេះជាការអនុវត្តពីមុន ក្នុងការកំណត់ពូជដំណាំ។ ការដាក់ឈ្មោះ មិនត្រូវនាំឱ្យយល់ខុស ឬ បណ្តាលឱ្យភ័ន្តច្រឡំទៅនឹងចរិតលក្ខណៈ តម្លៃ ឬ អត្តសញ្ញាណនៃពូជដំណាំ ឬ អត្តសញ្ញាណរបស់អ្នកបង្កាត់ពូជដំណាំឡើយ។ នៅពេលដែលពូជដំណាំមួយត្រូវបានដាក់លក់ ឬ ចរាចរ ពូជដំណាំត្រូវបានអនុញ្ញាតឱ្យភ្ជាប់ទៅនឹងពាណិជ្ជសញ្ញា ពាណិជ្ជនាម ជាមួយនឹងការដាក់ឈ្មោះពូជដំណាំដែលបានចុះបញ្ជី។ ជាពិសេសនោះ ការដាក់ឈ្មោះពូជដំណាំត្រូវតែខុសគ្នាពីឈ្មោះដែលមានរួចហើយ។

### ១.៣.២ ករណីលើកលែងចំពោះពូជដំណាំដែលមិនទទួលបានការការពារ

ការកំណត់ពូជដំណាំ ដោយការដាក់ឈ្មោះចាំបាច់ណាស់ត្រូវតែដាក់ឱ្យបានសមរម្យ ហើយអាចសម្គាល់បាននូវប្រភេទនៃពូជដំណាំនោះ ក្នុងករណីដែលឈ្មោះពូជថ្មីនៃដំណាំ មិនទទួលបាននូវការការពារ រួមមានដូចជា៖

- មិនអាចសម្គាល់ពូជដំណាំបាន
- មានសញ្ញាតែមួយ លើកលែងតែសញ្ញានោះ អាចសម្គាល់ពូជដំណាំបាន
- នាំឱ្យសាធារណៈជនយល់ខុស ឬ បណ្តាលឱ្យភ័ន្តច្រឡំទៅនឹងចរិតលក្ខណៈ ឬ តម្លៃ ឬ អត្តសញ្ញាណនៃពូជដំណាំ ឬ អត្តសញ្ញាណរបស់អ្នកបង្កាត់ពូជ
- ដូចទៅនឹងឈ្មោះពូជដំណាំ ដែលមានរួចហើយក្នុងព្រះរាជាណាចក្រកម្ពុជា ឬ រដ្ឋជាភាគីហត្ថលេខី ដូចទៅនឹងឈ្មោះពូជដំណាំ ដែលទទួលបានសិទ្ធិមុន។[15]

### ១.៣.៣ ការដាក់ពាក្យ និងសិទ្ធិអាទិភាព

❖ **ការដាក់ពាក្យស្នើសុំសម្រាប់ការផ្តល់សិទ្ធិដល់អ្នកបង្កាត់ពូជដំណាំ**

[14] https://www.cambodiaip.gov.kh/TemplateTwo.aspx?parentId=45&menuid=291&childMasterMenuId=291(កាលបរិច្ឆេទចូលមើលថ្ងៃទី០២ ខែ ឧសភា ឆ្នាំ២០២១)

[15] មាត្រា ២៦ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

អ្នកដាក់ពាក្យសុំការការពារពូជថ្មីនៃដំណាំ ត្រូវដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជីតាមគំរូពាក្យសុំដែលបាន កំណត់។ អ្នកដាក់ពាក្យសុំ ត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់ ឯកសារ ឬពូជដំណាំ តាមកាលបរិច្ឆេទ និង ទីកន្លែង ដែលបានកំណត់ដោយមន្ត្រីកាន់កាប់បញ្ជី។ មន្ត្រីកាន់កាប់បញ្ជី ត្រូវចុះកាលបរិច្ឆេទទទួលពាក្យសុំ បន្ទាប់ពីបាន បង់កម្រៃរួច។ កាលបរិច្ឆេទការដាក់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ ត្រូវជាកាលបរិច្ឆេទនៃការទទួលពាក្យ ស្នើសុំដែលបានដាក់ត្រឹមត្រូវ។ គំរូពាក្យសុំ ឯកសារ ឬ ពូជដំណាំនឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម។

❖ **សិទ្ធិអាទិភាព**

អ្នកដាក់ពាក្យសុំ អាចប្រើប្រាស់សិទ្ធិអាទិភាពនៃពាក្យសុំលើកដំបូងនៅបរទេសសម្រាប់ពូជដំណាំដូច គ្នានៅប្រទេសណាមួយដែលភាគីហត្ថលេខីនៃអនុសញ្ញាសហព័ន្ធអន្តរជាតិការពារពូជថ្មីនៃដំណាំ។ ប្រសិនបើ យើងក្រឡេកមកមើលអនុសញ្ញាយូប៉ូវក៏បានចែងដែរថា “ **អ្នកបង្កាត់ពូជដំណាំ ដែលបានដាក់ពាក្យស្នើសុំដំបូង សម្រាប់ការការពារពូជដំណាំត្រឹមត្រូវ ក្នុងសមាជិកមួយនៃយូប៉ូវ ចំពោះពូជដំណាំតែមួយ ត្រូវទទួលបាន សិទ្ធិ អាទិភាពក្នុងរយៈពេល ១២ខែ។ រយៈពេលនេះត្រូវរាប់ចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដំបូង**” ។[16]

ដើម្បីប្រើប្រាស់សិទ្ធិអាទិភាពរបស់ខ្លួនបាន អ្នកដាក់ពាក្យសុំត្រូវប្រគល់ឯកសារចម្លងនៃសំណុំលិខិត ស្នើសុំដែលបានដាក់ដំបូងបង្អស់ចំនួនមួយច្បាប់ និង ត្រូវមានការបញ្ជាក់ថា ត្រឹមត្រូវតាមច្បាប់ដើម ដោយ ការិយាល័យដែលបានទទួលសំណុំលិខិតស្នើសុំដំបូងបង្អស់ក្នុងរយៈពេល ៣(បី)ខែ គិតចាប់ពីកាលបរិច្ឆេទនៃ ការដាក់ពាក្យសុំនៅព្រះរាជាណាចក្រកម្ពុជា។

## ១.៣.៤ ការត្រួតពិនិត្យពាក្យស្នើសុំ និងការបោះពុម្ពផ្សាយ

❖ **ការត្រួតពិនិត្យពាក្យស្នើសុំ**

មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យពាក្យសុំដើម្បីកំណត់ថា បានបំពេញនូវលក្ខខណ្ឌនៃភាពថ្មី ភាពខុសប្លែក ឯកសណ្ឋានភាព និងស្ថេរភាព ត្រឹមត្រូវគ្រប់គ្រាន់ តាមច្បាប់កំណត់ដែរឬទេ ប្រសិនបើពិនិត្យទៅឃើញថា លក្ខខណ្ឌដែលបានកំណត់នោះមិនត្រូវបានបំពេញទេ នោះមន្ត្រីកាន់កាប់បញ្ជីត្រូវបដិសេធពាក្យស្នើសុំនោះ។ ក្នុងករណី នៅពេលដែលការត្រួតពិនិត្យបង្ហាញថា ការស្នើសុំដាក់ឈ្មោះពូជដំណាំមិនអាចចុះបញ្ជីបាន មន្ត្រីកាន់ កាប់បញ្ជីត្រូវស្នើឱ្យអ្នកដាក់ពាក្យផ្តល់ឈ្មោះផ្សេងទៀត ប្រសិនបើឈ្មោះនោះពិនិត្យទៅឃើញថាបានប្រើរួច ឬក៏

[16] មគ្គុទេសក៏សម្រាប់ការរៀបចំច្បាប់ផ្អែកលើច្បាប់ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ មាត្រា១១

មិនសមរម្យ នាំឱ្យមានការភ័ន្តច្រឡំ ការដាក់ពាក្យផ្ដល់ឈ្មោះនេះគឺត្រូវធ្វើឡើងក្នុងកំឡុងពេលមិនឱ្យលើសពី ៣ (បី)ខែ នោះទេ។

❖ **ការបោះពុម្ពផ្សាយ**

សាធារណជន ត្រូវបានជូនដំណឹងតាមរយៈការបោះពុម្ពផ្សាយពត៌មានជាទៀងទាត់ពាក់ព័ន្ធនឹង៖

- ការដាក់ពាក្យស្នើសុំនិងការផ្ដល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ និង
- ការដាក់ឈ្មោះដែលបានស្នើនិងបានយល់ព្រម។

### ១.៣.៥ ភ្នាក់ងារអ្នកដាក់ពាក្យសុំ

អ្នកបង្កាត់ពូជដំណាំ អាចដាក់ពាក្យស្នើសុំដោយខ្លួនឯង ឬ ភ្នាក់ងារ តំណាងមកដាក់ពាក្យស្នើសុំជំនួសខ្លួនបាន។ ក្នុងករណីដែលមានទីលំនៅអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មរបស់អ្នកស្នើសុំស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជា អ្នកស្នើសុំនោះ ត្រូវមានភ្នាក់ងារតំណាងដែលមានទីលំនៅអចិន្ត្រៃយ៍ ឬ កំពុងប្រកបវិជ្ជាជីវៈ នៅព្រះរាជាណាចក្រកម្ពុជា។

ភ្នាក់ងារតំណាង ដែលដាក់ពាក្យស្នើសុំចុះបញ្ជីពូជថ្មីនៃដំណាំក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងបំពេញបានលក្ខខណ្ឌ ដែលច្បាប់បានចែងផងដែរ។

# ជំពូកទី ២
# សិទ្ធិអំណាច និង សមត្ថភាពនៃការគ្រប់គ្រងពូជដំណាំ

# ជំពូកទី ២

# សិទ្ធិអាទិភាព និង ណត្តិភាពនៃការគ្រប់គ្រងពូជដំណាំថ្មី

ក្រោយពីយើងបានសិក្សាជំពូកទី១ ដែលនិយាយអំពីសញ្ញាណនៃការគ្រប់គ្រងពូជដំណាំថ្មី លក្ខខណ្ឌ និងការដាក់ពាក្យស្នើសុំការការពាររួចហើយ បន្ទាប់ពីនេះយើងនឹងធ្វើការសិក្សាលម្អិតទៅលើជំពូកទី២នេះម្តងគឺ សិទ្ធិអាទិភាព និងណត្តិភាពនៃការគ្រប់គ្រងទៅលើពូជដំណាំថ្មី ។

## ២.១ អានុភាពនៃការគ្រប់គ្រង និងការពារ

### ២.១.១ សិទ្ធិអាទិភាពដែលទទួលបាន

#### ២.១.១.១ កិច្ចការពារបណ្តោះអាសន្ន

ដំណើរការនៃការដាក់ពាក្យសុំចុះបញ្ជីការពារពូជដំណាំត្រូវឆ្លងកាត់ដំណាក់កាលជាច្រើន ដែលក្នុងរយៈពេលរងចាំវាអាចធ្វើអោយប៉ះពាល់ប្រយោជន៍នៃម្ចាស់សិទ្ធិបាន។ ដូចនេះ ដើម្បីចៀសវាងនូវបញ្ហានានា និងដើម្បីការពារផលប្រយោជន៍របស់អ្នកបង្កាត់ពូជ គេបានបង្កើតអោយមានយន្តការការពារបណ្តោះអាសន្នក្នុងកំឡុងពេលនៃការដាក់ពាក្យស្នើសុំ ឬការបោះផ្សាយនៃពាក្យស្នើសុំរហូតដល់ការទទួលបានសិទ្ធិការពារពូជថ្មី នៃដំណាំ។ យន្តការនេះបានចែងនៅក្នុងមាត្រា១៣នៃអនុសញ្ញាអន្តរជាតិស្តីពីការការពារពូជថ្មីនៃដំណាំ UPOV ឆ្នាំ ១៩៩១។ ដោយឡែកសម្រាប់ព្រះរាជាណាចក្រកម្ពុជាក៏បានចែងយ៉ាងច្បាស់នៅក្នុងមាត្រា៣០ វាក្យខណ្ឌ៥ និងបានកំណត់ថា ក្នុងចន្លោះពេលពីការបោះពុម្ពផ្សាយនៃពាក្យស្នើសុំរហូតដល់ការផ្តល់សិទ្ធិការពារពូជដំណាំ ម្ចាស់សិទ្ធិមានសិទ្ធិទាមទារសំណងសមស្របចំពោះសកម្មភាពមួយចំនួនដែលច្បាប់បានកំណត់រួមមាន ការយកពូជ ឬបំណែកពូជដែលបានការពារទៅប្រើប្រាស់ក្នុងសកម្មភាពការផលិត ឬការផលិតឡើងវិញ ការកំណត់លក្ខខណ្ឌក្នុងគោលបំណងពង្រីកពូជ ការផ្គត់ផ្គង់សម្រាប់ ការលក់ ឬការចែកចាយនៅលើទីផ្សារ ការនាំចេញ ការនាំចូល ការធ្វើសន្និធិជាដើម។[17]

#### ២.១.១.២ វិសាលភាពនៃសិទ្ធិអ្នកបង្កាត់ពូជដំណាំ

សិទ្ធិបង្កាត់ពូជដំណាំ ជាសិទ្ធិដែលផ្តល់អោយអ្នកបង្កាត់ពូជដំណាំទៅលើស្នាដៃបង្កាត់ពូជថ្មីរបស់ខ្លួន ដែលមានទំនាក់ទំនងទៅនឹងបទបញ្ញត្តិមួយចំនួន ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងអាជីវកម្មទៅលើពូជដំណាំ

[17] វាក្យខណ្ឌទី១ មាត្រា១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០០៨

ពោលគឺការពារសិទ្ធិរបស់អ្នកបង្កាត់ពូជពីការកេងប្រវ័ញ្ចនានាអំពីពូជថ្មីនោះ ហើយប្រសិនបើមានបុគ្គលណាមួយចង់យកពូជថ្មីនោះទៅធ្វើអាជីវកម្មត្រូវតែមានការអនុញ្ញាតជាមុនសិន។ ល្គឹកណាមានបុគ្គលរំលោភទៅលើសិទ្ធិនេះ បុគ្គលនោះនឹងត្រូវទទួលខុសត្រូវតាមច្បាប់ ព្រោះមិនមាននរណាម្នាក់អាចប្រើប្រាស់សិទ្ធិលើកម្មសិទ្ធិដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិករឡើយ។ ច្បាប់បានការពារយ៉ាងតឹងរឹងចំពោះម្ចាស់សិទ្ធិនៅពេលដែលគេទទួលបានវិញ្ញាបនបត្របញ្ជាក់សិទ្ធិការពារពូជថ្មីនៃដំណាំ ប៉ុន្តែករណីខ្លះច្បាប់ក៏អនុញ្ញាតអោយដកហូតសិទ្ធិនោះពីម្ចាស់សិទ្ធិ បើគេមិនបានយកពូជថ្មីនៃដំណាំនោះទៅប្រើប្រាស់ក្នុងវិស័យកសិកម្ម ឬអាជីវកម្មនានា ឬប្រព្រឹត្តអំពើនានាផ្ទុយនឹងលក្ខណៈគតិយុត្តនៃច្បាប់។

សិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំក៏មានវិសាលភាពគ្របដណ្តប់ផងដែរទៅលើពូជ ៖

- ដែលបានបង្កើតថ្មីដោយលក្ខណៈពិសេសសំខាន់ៗចេញពីពូជបានការពារ
- ដែលពុំមានភាពខុសគ្នាដាច់ស្រឡះពីពូជបានការពារ
- ដែលផលិតកម្មរបស់វាត្រូវការប្រើប្រាស់ឡើងវិញនូវពូជដែលបានការពារ។[18]

### ២.១.១.៣ ការលើកលែងចំពោះសិទ្ធិអ្នកបង្កាត់ពូជដំណាំ

ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បានកម្រិតសិទ្ធិអ្នកបង្កាត់ពូជដែលធ្វើឡើងក្នុងគោលបំណងមិន សមស្របទៅនឹងច្បាប់នេះ ហើយសិទ្ធិអ្នកបង្កាត់ពូជគ្មានវិសាលភាពដល់សកម្មភាពមួយចំនួនដែលច្បាប់បានកំណត់ដូចជា:

- សកម្មភាពដែលធ្វើឡើងដោយឯកជន និងគ្មានបំណងពាណិជ្ជកម្ម
- សកម្មភាពដែលធ្វើឡើងក្នុងគោលបំណងពិសោធន៍
- សកម្មភាពដែលធ្វើឡើងក្នុងគោលបំណងបង្កាត់ពូជដំណាំផ្សេងទៀត និងសកម្មភាពដូចមានចែងក្នុងមាត្រា១៤ ទាក់ទងនឹងពូជដំណាំផ្សេងទៀត លើកលែងតែបទប្បញ្ញត្តិនៃមាត្រា១៥។[19]

ជាទូទៅ គេតែងតែលើកទឹកចិត្តទៅដល់អ្នកបង្កាត់ពូជថ្មីៗ ដើម្បីអោយពួកគេទទួលបានកម្រៃពីអាជីវកម្មដែលទទួលបានពីពូជថ្មីនៃការបង្កាត់ពូជនោះ ចែករំលែកដំណាំបង្កាត់ពូជនោះជាសាធារណៈក្នុងគោលបំណង

[18] វាក្យខណ្ឌទី៤ មាត្រា១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

[19] ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

អោយមានប្រសិទ្ធិភាពការងារកសិកម្ម ប៉ុន្តែក្នុងករណីដែលអ្នកបង្កាត់ពូជនោះធ្វើឡើងសម្រាប់តែប្រយោជន៍ផ្ទាល់ខ្លួននោះ ច្បាប់មិនបានការពារទៅលើទង្វើទាំងនោះឡើយ។

### ២.១.១.៤ ការកម្រិតការអនុវត្តសិទ្ធិអ្នកបង្កាត់ពូជដំណាំ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និង នវានុវត្តន៍ បានដាក់ចេញនូវបទប្បញ្ញត្តិមួយដោយធ្វើការកម្រិតសិទ្ធិអ្នកបង្កាត់ពូជដំណាំក្នុងគោលបំណងដើម្បី អនុញ្ញាតឲ្យកសិករផលិត និងប្រើប្រាស់ជាសម្បត្តិផ្ទាល់ខ្លួននូវផលិតផលដែលប្រមូលផលបានពីការដាំដុះពូជ ថ្មីនៃដំណាំដែលបានការពារក្នុងគោលបំណងយកទៅដាំដុះបន្ត។ ការដាក់ចេញនូវបទប្បញ្ញត្តិបែបនេះ មិនត្រឹមតែបានការពារផលប្រយោជន៍ស្របច្បាប់ និងព្រំដែនសិទ្ធិរបស់ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំប៉ុណ្ណោះទេ វាថែមទាំងជាប្រយោជន៍ដល់សង្គមជាតិ ដែលបានផ្តល់ចំណូលបន្ថែមសម្រាប់កសិករក្នុងដំណើរការកសិកម្មរបស់ពួកគេតាមរយៈពូជថ្មីនេះ កសិករអាចដាំដុះបានទិន្នផលច្រើនជាងមុន បំពេញតម្រូវការអ្នកប្រើប្រាស់ និងបំពេញ តាមសេចក្តីចង់បានរបស់មនុស្សជាដើម។

### ២.១.១.៥ រយៈពេលការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ

គ្រប់ផ្នែកទាំងអស់នៃកម្មសិទ្ធិបញ្ញាទទួលបានការពារក្នុងកំឡុងពេលផ្សេងៗពីគ្នា ហើយការការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំក៏បានត្រូវគេកំណត់រយៈពេលនៃការការពារដែរ។ ការការពារខ្លះមានរយៈពេលខ្លី និងវែង ផ្អែកទៅតាមតក្កកម្មដែលគេរកឃើញ និងតាមការកំណត់នៃច្បាប់។ ម្យ៉ាងវិញទៀតរយៈពេលនៃការការពារទៅលើផ្នែកតែមួយក៏មិនប្រាកដថាមានរយៈពេលដូចគ្នាដែរ អាស្រ័យទៅលើច្បាប់ប្រទេសនីមួយៗ តែជាទូទៅសម្រាប់ផ្នែកការពារពូជថ្មីនៃដំណាំនេះត្រូវបានគេកំណត់រយៈពេលការពារ២០ឆ្នាំសម្រាប់ពូជថ្មីធម្មតា និង២៥ឆ្នាំសម្រាប់ដំណាំវល្លិ៍ និងដំណាំឈើ។ ដោយឡែក បើយោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៨ បានចែងថា ***សុពលភាពសិទ្ធិការពារលើពូជថ្មីនៃដំណាំមានរយៈពេល២០ឆ្នាំ លើកលែងតែដំណាំមានលក្ខណៈពិសេសដូចជា ដំណាំវល្លិ៍ និងដំណាំឈើ ដែលមានរយៈពេល២៥ឆ្នាំ ក្រោយពីទទួលបានសិទ្ធិការពារលើពូជថ្មី នៃដំណាំនោះ*** ។[20] បើមើលទៅលើមាត្រានេះ ច្បាប់បានចែងយ៉ាងច្បាស់ពីការទទួលបានការការពារនេះ ប្រសិន បើអ្នកបង្កាត់ពូជនោះជោគជ័យក្នុងការរកឃើញពូជថ្មីក៏ដោយ បើមិនបានបំពេញលក្ខណៈសម្បត្តិជាម្ចាស់សិទ្ធិ

[20] មាត្រា១៩ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

តាមលក្ខណៈច្បាប់ ឬចូលក្នុងចំណុចណាមួយនៃមាត្រា១៦ វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជ អ្នកបង្កាត់ពូជនោះមិនទទួលបានការការពារក្នុងរយៈពេលនោះឡើយ។

ក្នុងរយៈពេលនៃការការពារនេះ ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំបានទទួលផលប្រយោជន៍ជាច្រើនដូចជា ទទួលបានប្រាក់ចំណូលផ្សេងៗពីដំណាំនោះ និង ការការពារតាមផ្លូវច្បាប់ដែលរារាំងពីការប្រើប្រាស់ពូជដំណាំ ដែលបានស្នើសុំការការពារនោះដោយគ្មានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ។ យ៉ាងណាមិញយើងឃើញថា កំឡុងពេលការពារម្ចាស់សិទ្ធិទទួលបានផលប្រយោជន៍ជាច្រើនពីពូជថ្មីដែលគេរកឃើញនោះ ចុះនៅពេលពូជនោះផុតរយៈពេលការពារវានឹងក្លាយទៅជាយ៉ាងណា?

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ គេបានកំណត់រយៈពេលការពារ២០ឆ្នាំសម្រាប់ពូជថ្មីធម្មតា និង២៥ ឆ្នាំសម្រាប់ដំណាំវល្លិ៍ និងដំណាំឈើ។ បន្ទាប់ពីផុតរយៈពេលការពារនេះ ពូជដំណាំនោះលែងក្លាយជាកម្មសិទ្ធិរបស់អ្នកបង្កាត់ពូជដំណាំទៀតហើយ គឺមានន័យថាពូជនោះត្រូវបានអោយប្រើប្រាស់ជាសាធារណៈ និងក្លាយជាសិទ្ធិរបស់សាធារណជន ហើយអ្នកបង្កាត់ពូជដំណាំនិងបាត់បង់សិទ្ធិជាម្ចាស់នៃពូជដែលការពារ មានន័យថានរណាក៏អាចមានសិទ្ធិធ្វើអាជីវកម្ម ឬប្រើប្រាស់ដោយមិនចាំបាច់សុំការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំនោះឡើយ ហើយអ្នកបង្កាត់នៅតែអាចប្រើប្រាស់ពូជនោះបានដដែល គ្រាន់តែគ្មានសិទ្ធិហាមឃាត់អ្នកដទៃក្នុងការប្រើប្រាស់ ឬទាមទារអោយមានទណ្ឌកម្មណាមួយទៅលើអ្នកប្រើប្រាស់ទេ ច្បាប់បានបញ្ចប់លក្ខណៈសម្បត្តិជាម្ចាស់សិទ្ធិចាប់ពីពេលផុតរយៈពេលនោះមក។ តែទោះបីជាយ៉ាងណាក៏ច្បាប់បានផ្តល់តម្លៃអោយម្ចាស់នៃពូជនោះ ដោយម្ចាស់ពូជអាចធ្វើការសុំការពារទៅលើឈ្មោះនៃដំណាំរបស់ខ្លួនបាន។

## ២.១.២ សិទ្ធិអនុញ្ញាតអោយតតិយជនធ្វើអាជីវកម្ម

### ២.១.២.១ ការធ្វើអាជីវកម្មបានដោយមានការអនុញ្ញាត

តាមច្បាប់ស្តីពីការគ្រប់គ្រងដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំបានកំណត់ថា ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ មានសិទ្ធិលក់ ឬផ្ទេរសិទ្ធិរបស់ខ្លួនបាន។ ការលក់ ឬការផ្ទេរទៅឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ និងត្រូវចុះហត្ថលេខាដោយភាគីពាក់ព័ន្ធ ហើយត្រូវកត់ត្រានៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ ដោយត្រូវជូនដំណឹងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។[21]

[21] មាត្រា១៤ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

អ្នកដាក់ពាក្យស្នើសុំការការពារសិទ្ធិការពារពូជថ្មីនៃដំណាំ ឬម្ចាស់សិទ្ធិពូជថ្មីនៃដំណាំអាចប្រគល់ទៅឲ្យតតិយជនដែលអាចជារូបវន្តបុគ្គល ឬនីតិបុគ្គលនូវអាជ្ញាប័ណ្ណផ្តាច់មុខ ឬអាជ្ញាប័ណ្ណមិនផ្តាច់មុខទាក់ទងនឹងសិទ្ធិទាំងអស់ ឬសិទ្ធិណាមួយដែលច្បាប់ផ្តល់ឲ្យតាមរយៈកិច្ចសន្យាអាជ្ញាប័ណ្ណ។ ក្នុងន័យនេះ បុគ្គលដែលទទួលបានអាជ្ញាប័ណ្ណនោះអាចប្រើប្រាស់សិទ្ធិនោះក្នុងគោលបំណងប្រើប្រាស់ និងអាស្រ័យផលលើពូជដំណាំដែលបានការពារដែលការប្រើប្រាស់ ត្រូវអនុលោមទៅតាមការព្រមព្រៀងទាំងឡាយដែលមានចែងនៅក្នុងកិច្ចសន្យា អាជ្ញាប័ណ្ណ។ ក្នុងករណីដែលអ្នកបង្កាត់ពូជដំណាំជានិយោជិត ការផ្ទេរទៅឲ្យនិយោជករបស់ខ្លួនត្រូវធ្វើឡើងក្នុងរូបភាពជាកិច្ចសន្យាការងារ ហើយរាល់ការអនុវត្តសិទ្ធិ និងកាតព្វកិច្ច ឬ ខសំខាន់ៗផ្សេងៗ គឺអាស្រ័យទៅលើការព្រមព្រៀងរវាងគូភាគីនៃកិច្ចសន្យា។

### ២.១.២.២ ការធ្វើអាជីវកម្មបានដោយមិនចាំបាច់មានការអនុញ្ញាត

រាល់ការប្រើប្រាស់ ឬរំលោភបំពានដោយមិនមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំដែលទទួលបានវិញ្ញាបនបត្របញ្ជាក់ពីសិទ្ធិការពារពូជថ្មីនៃដំណាំពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ត្រូវបានចាត់ទុកថាខុសច្បាប់ ហើយបុគ្គលដែលបានបំពាននោះនឹងត្រូវទទួលខុសត្រូវតាមច្បាប់។ ប៉ុន្តែដោយមិនខុសពីទម្រង់ផ្សេងៗនៃកម្មសិទ្ធិបញ្ញាទេ គ្រប់រូបភាពនានាដែលរដ្ឋជាអ្នកប្រើប្រាស់គឺមិនចាត់ទុកជាការរំលោភបំពានឡើយ។ ដូចនេះ នេះជាការប្រើប្រាស់សិទ្ធិអ្នកបង្កាត់ពូជ ក្នុងការយកពូជនោះទៅធ្វើអាជីវកម្ម ឬទៅប្រើប្រាស់ក្នុងទម្រង់ផ្សេងៗដោយមិនត្រូវការមានការអនុញ្ញាតពីម្ចាស់សិទ្ធិ ឬអ្នកបង្កាត់ពូជដំណាំ។ ជាទូទៅ រដ្ឋមិនលូកដៃនៅក្នុងការងារណាមួយដែលប៉ះពាល់ទៅលើសិទ្ធិបុគ្គលណាម្នាក់ឡើយ ជាពិសេសប្រជារាស្ត្រនៃទឹកដីរបស់ខ្លួន។ ប៉ុន្តែនៅក្នុងហេតុផលដែលវាពិតជាចាំបាច់សម្រាប់សង្គមជាតិទាំងមូល ឬ សម្រាប់ប្រជារាស្ត្រនៃរដ្ឋនោះ រដ្ឋចាំបាច់ត្រូវយកពូជថ្មីនៃដំណាំនោះទៅប្រើប្រាស់ ឬក៏ធ្វើអាជីវកម្មផ្សេងៗ។ ការយកពូជថ្មីនៃដំណាំ ទៅប្រើប្រាស់ជាកម្មសិទ្ធិអាជីវកម្មរបស់រដ្ឋផ្ទាល់ ឬរដ្ឋមិនធ្វើអាជីវកម្មដោយផ្ទាល់ទេ តែឲ្យតតិយជនម្នាក់ទៀត ដែលរដ្ឋផ្តល់សិទ្ធិឲ្យធ្វើអាជីវកម្មទៅលើពូជថ្មីនោះហៅថា ជាតិតូបនីយកម្ម ហើយទោះបីការប្រើប្រាស់នោះមានការយល់ព្រម ឬមិនយល់ព្រមពីអ្នកបង្កាត់ពូជក៏ដោយ ក៏គេមិនចាត់ទុកថាការប្រើប្រាស់នោះរំលោភសិទ្ធិអ្នកបង្កាត់ពូជឡើយ តែគឺជាការធ្វើអាជីវកម្មដោយស្របច្បាប់ ដែលវាផ្ទុយនឹងការយកទៅប្រើប្រាស់របស់បុគ្គលទូទៅ។

ធម្មតាការយកពូជថ្មីនៃដំណាំពីអ្នកបង្កាត់ពូជដំណាំ ទៅអោយរដ្ឋធ្វើអាជីវកម្ម គឺក្នុងគោលបំណងដើម្បីអោយមានការអភិវឌ្ឍបន្ថែមទៀតទៅលើពូជនោះដើម្បីជួយវិស័យកសិកម្មអោយកាន់តែរីកចម្រើន ដោយតាមន័យនេះវាអាចធ្វើអោយមានការនាំចេញទៅក្រៅប្រទេស ដើម្បីបំពេញតម្រូវការមនុស្សជាតិ ដែលហេតុផលទាំងនេះពិតជាបានជួយជាតិទទួលបានប្រាក់ចំណូលជាច្រើនពីពូជនោះ និងបានធ្វើអោយប្រទេសជាតិមានការអភិវឌ្ឍកាន់តែខ្លាំងឡើង និងក្នុងគោលបំណងដូចដែលបានចែងក្នុងមាត្រា១៦ វាក្យខណ្ឌទី២នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។ ប៉ុន្តែការយកទៅធ្វើជាអាជីវកម្មរបស់រដ្ឋបែបនេះ មិនមានន័យថារដ្ឋយកទៅដោយមិនបានគិតគូរទៅលើប្រយោជន៍អ្នកបង្កាត់ពូជឡើយ។ ក្នុងករណីដែលរដ្ឋយកអាជីវកម្មទៅធ្វើខ្លួនឯង រដ្ឋត្រូវចេញសំណងការខូចខាតទៅអោយអ្នកបង្កាត់ពូជ ដោយឡែកបើរដ្ឋប្រគល់អោយតតិយជនជាអ្នកធ្វើសកម្មភាពអាជីវកម្មតាមរយៈការដាក់ពាក្យស្នើសុំមករដ្ឋមន្ត្រីនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ និងរដ្ឋមន្ត្រីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឲ្យផ្តល់អាជ្ញាប័ណ្ណបញ្ជាក្នុង ការប្រើប្រាស់ពូជថ្មីនៃដំណាំដោយផ្អែកលើមូលហេតុនៃភាពចាំបាច់ ដើម្បីការពារផលប្រយោជន៍សាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយក្នុងករណីនេះបុគ្គលដែលទទួលបានអាជ្ញាប័ណ្ណនោះត្រូវបង់ប្រាក់សំណងឲ្យសមស្របទៅអោយម្ចាស់សិទ្ធិពូជថ្មីនៃដំណាំនោះ។[22]

## ២.១.៣ សិទ្ធិហាមឃាត់ធ្វើអាជីវកម្ម

ពូជដំណាំដែលត្រូវបានធ្វើការការពារពីសិទ្ធិគ្រប់គ្រងពូជដំណាំ និងអ្នកបង្កាត់ពូជដំណាំ មិនអនុញ្ញាតអោយមានការប្រើប្រាស់នោះឡើយ ប្រសិនបើវាស្ថិតនៅក្នុងអំឡុងពេលដែលត្រូវបានការពារ។ គ្រប់សកម្មភាពទាំងឡាយណាដែលប៉ះពាល់ដល់សិទ្ធិអ្នកបង្កាត់ពូជដោយពុំមានការអនុញ្ញាតពីម្ចាស់សិទ្ធិ ត្រូវចាត់ទុកជាអំពើខុសច្បាប់ ដែលវារំលោភទៅលើសិទ្ធិគ្រប់គ្រងពូជដំណាំរបស់អ្នកបង្កាត់ពូជដំណាំ។ ទោះបីជាយ៉ាងណាក៏ដោយច្បាប់នឹងមិនធ្វើការហាមឃាត់អោយមានបុគ្គលផ្សេងធ្វើអាជីវកម្មទេ ប្រសិនបើពូជដំណាំអស់សុពលភាពនៃការការពារ។ មានន័យថានៅពេលដែលដំណាំធម្មតាការពារបានរយៈពេល២០ឆ្នាំ ហើយដំណាំឈើ និងដំណាំវល្លិការពារបាន២៥ឆ្នាំ អ្នកបង្កាត់ពូជនោះអស់ភាពជាម្ចាស់នៃពូជថ្មីនោះហើយ។ សម្រាប់ពូជថ្មីនៃដំណាំ អ្នកបង្កាត់ពូជមិនអាចធ្វើការស្នើសុំអោយមានការបន្តការការពារពីក្រសួងដែលចេញវិញ្ញាបនបត្រឡើយ ដូច្នេះបន្ទាប់ពីពូជនោះផុតរយៈពេលការពារ ពូជនោះនឹងត្រូវបានប្រកាសឲ្យសាធារណជនប្រើប្រាស់ជាសាធារណៈ។

[22] មាត្រា៣៥ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

## ២.២ ទោសបញ្ញត្តិ

ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានកំណត់អំពីភ្នាក់ងារអធិការកិច្ច ការងារក្នុងការត្រួតពិនិត្យ ដើម្បីទប់ស្កាត់ និងបង្រ្កាបបទល្មើសរំលោភលើពូជដំណាំថ្មីតាមរយៈការនាំចូលផលិតផលក្លែងបន្លំមកក្នុងទីផ្សារកម្ពុជា។ ការរំលោភបំពានលើពូជដំណាំថ្មីដោយជនណាម្នាក់ក្រៅពីម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ ដែលបានចុះបញ្ជីរួចនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយមិនមានការយល់ព្រមពីម្ចាស់សិទ្ធិ។ ដើម្បីទប់ស្កាត់នូវការរំលោភបំពានសិទ្ធិរបស់ម្ចាស់ពូជដំណាំថ្មីនីមួយៗ ដែលបានចុះបញ្ជីយ៉ាងត្រឹមត្រូវបានកំណត់នោះ ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានកំណត់ឱ្យមានភ្នាក់ងារអធិការកិច្ចពូជដំណាំ វិធានការបណ្តោះអាសន្ន ក៏ដូចជាទណ្ឌកម្មទៅលើជនដែលល្មើសនឹងច្បាប់បានចែងផងដែរ។

### ២.២.១ ភ្នាក់ងារអធិការកិច្ចពូជដំណាំ

ភ្នាក់ងារអធិការកិច្ចពូជដំណាំ គឺត្រូវចាត់តាំងដោយប្រកាសរួមរវាងរដ្ឋមន្រ្តីក្រសួងយុត្តិធម៌ និងរដ្ឋមន្រ្តីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលមានសមត្ថកិច្ចបំពេញតួនាទីជាមន្រ្តី និងភ្នាក់ងារនគរបាលយុត្តិធម៌។[23]

ភ្នាក់ងារអធិការកិច្ចពូជដំណាំ មានភារកិច្ច និងសិទ្ធិដូចជា៖

- តាមដាន និង ត្រួតពិនិត្យជាប្រចាំនូវការធ្វើអាជីវកម្មគ្រប់រូបភាពនិង គ្រប់សកម្មភាពពាក់ព័ន្ធពូជដំណាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ធ្វើអធិការកិច្ចគ្រប់ទីតាំងអាជីវកម្មពូជដំណាំគ្រប់ប្រភេទ ឃ្លាំងស្តុក រោងចក្រ សហគ្រាស រួមទាំងកសិដ្ឋានដែលពាក់ព័ន្ធ ឬ សង្ស័យថាបានប្រព្រឹត្តល្មើសនឹងច្បាប់
- ដកយកសំណាកពូជដំណាំទាំងឡាយណា ដែលបានសង្ស័យថាល្មើសនឹងច្បាប់ ដើម្បីធ្វើការពិសោធន៍
- តម្រូវឱ្យអាជីវករបង្ហាញនូវលិខិតអនុញ្ញាតពាក់ព័ន្ធ ឬ ឯកសារផ្សេងៗពាក់ព័ន្ធ ក្នុងការធ្វើអាជីវកម្មពូជដំណាំ
- ដកហូតជាបណ្តោះអាសន្ននូវរាល់លិខិតអនុញ្ញាតគ្រប់ប្រភេទ ឬ ឯកសារពាក់ព័ន្ធ ក្នុងករណីអ្នកកាន់កាប់លិខិតអនុញ្ញាតនោះប្រព្រឹត្តល្មើសនឹងច្បាប់

[23] មាត្រា៦៤ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

- ក្នុងករណីបទល្មើសជាក់ស្តែង មានសិទ្ធិឃាត់ ឬ បញ្ឈប់មធ្យោបាយដឹកជញ្ជូន ឬ មធ្យោបាយផ្ទុកពូជដំណាំ ដើម្បីត្រួតពិនិត្យ និង ឃាត់ទុកជាបណ្តោះអាសន្ននូវវត្ថុតាងនៃបទល្មើស និង មធ្យោបាយ ដើម្បីធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញា។[24]

បន្ថែមពីនេះទៀតក្នុងករណីដែលមានបទល្មើសកើតឡើង ភ្នាក់ងារអធិការកិច្ចពូជដំណាំអាចធ្វើការស្នើសុំទៅអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ ស្ថាប័នគយ និងរដ្ឋាករ ស្ថាប័នព្រលានយន្តហោះ កំពង់ផែ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត ជួយសហការក្នុងការស្រាវជ្រាវទប់ស្កាត់ និង បង្ក្រាបបទល្មើសពូជដំណាំ ឬ ថែរក្សាវត្ថុតាងបទល្មើសពូជដំណាំជាបណ្តោះអាសន្នផងដែរ។[25]

### ២.២.២ វិធានការបណ្តោះអាសន្ន

វិធានការបណ្តោះអាសន្ន គឺជាវិធានដែលតុលាការបានដាក់ចេញនូវសំណើររបស់ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ ដើម្បីទប់ស្កាត់ការរំលោភបំពាន ដែលការរំលោភបំពាននោះប្រុងនឹងកើតមាន ឬរក្សាទុកនូវភស្តុតាងដែលពាក់ព័ន្ធអំពីការរំលោភកម្មសិទ្ធិបញ្ញារបស់ម្ចាស់ពូជដំណាំថ្មីនីមួយៗ។ នីតិវិធីវិធានការបណ្តោះអាសន្ននេះ ពុំត្រូវបានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំឡើយ មានន័យថា វិធានការបណ្តោះអាសន្នត្រូវអនុវត្តន៍តាមក្រមនីតិវិធីរដ្ឋប្បវេណីទាំងស្រុង។ ក្នុងករណីនេះ តុលាការអាចចេញដីកាបណ្តោះអាសន្ន ដើម្បីហាមឃាត់ការប្រព្រឹត្ត ឬ ការបន្តការប្រព្រឹត្តអំពើរំលោភបំពានលើសិទ្ធិអ្នកបង្កាត់ពូជដំណាំ។[26]

### ២.២.៣ ទណ្ឌកម្មនៃអំពើរំលោភសិទ្ធិនៃពូជដំណាំថ្មី

ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និង សិទ្ធិអ្នកបង្កាត់ពូជដំណាំ ដែលបានអនុម័តនៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៨ គឺបានចែងកំណត់អំពីសំណងផ្នែករដ្ឋប្បវេណី ទោសព្រហ្មទណ្ឌ វិធានការរដ្ឋបាល ក្នុងករណីមានការរំលោភបំពានលើពូជថ្មីនៃដំណាំ។

#### ២.២.៣.១ សំណងរដ្ឋប្បវេណី

---

[24] មាត្រា៦៥ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

[25] មាត្រា៦៧ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

[26] មាត្រា៧០ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

យោងតាមមាត្រា ៧០ នៃច្បាប់ស្ដីពីការគ្រប់គ្រងពូជដំណាំ និងអ្នកបង្កាត់ពូជដំណាំ ឆ្នាំ ២០០៨ គឺម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ អាចប្ដឹងទៅតុលាការមានសមត្ថកិច្ច ដើម្បីហាមឃាត់ការប្រព្រឹត្ត ឬ ការបន្តការប្រព្រឹត្តអំពើរំលោភបំពានសិទ្ធិរបស់ខ្លួន តាមរយៈការស្នើសុំដីការបណ្ដោះអាសន្ន។ ក្រៅពីការសងការខូចខាតជាទឹកប្រាក់ ម្ចាស់សិទ្ធិអាចស្នើសុំការរឹបអូស ឬ ការបំផ្លាញចោលពូជដំណាំ ដែលបានផលិតល្មើសលើសិទ្ធិអ្នកបង្កាត់ពូជដំណាំផងដែរ។

ទាក់ទងនឹងបទល្មើសលើអាជីវកម្មពូជដំណាំ ទណ្ឌកម្មដែលបានកំណត់មានដូចជាៈ ពិន័យអន្តរការណ៍ ការឃាត់ទុកវត្ថុតាង ការរឹបអូសវត្ថុតាង ការបំផ្លាញវត្ថុតាង ការតម្រូវឱ្យជួសជុលការខូចខាត ការដកហូត ឬ ព្យួរលិខិតអនុញាតធ្វើអាជីវកម្ម លិខិតអនុញ្ញាតនាំចូល-នាំចេញពូជដំណាំ និង វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ជាសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបញ្ជូនសំណុំរឿងប្ដឹងទៅតុលាការ ចំពោះបុគ្គលណាដែលល្មើសមិនព្រមអនុវត្តតាមការសម្រេចរបស់សមត្ថកិច្ច។ ចំពោះការរឹបអូស និង បំផ្លាញវត្ថុតាង ការជួសជុលលើការខូចខាត ទោសពិន័យ និងទោសដាក់ពន្ធនាគារ ជាសមត្ថកិច្ចរបស់តុលាការ។[27]

ការទទួលពិន័យអន្តរការណ៍ចាប់ពី ៥០០.០០០ (ប្រាំសែន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ចំពោះបុគ្គលណាដែលបានប្រព្រឹត្តល្មើសនឹងចំណុចណាមួយដូចខាងក្រោមៈ

- មិនធ្វើនិយ័តកម្មស្របតាមច្បាប់នូវពូជដំណាំ ដែលបានចុះបញ្ជីក្រោមបទបញ្ញត្តិនានាក្នុងរយៈពេល ៦ខែ (ប្រាំមួយខែ) ក្រោយច្បាប់ស្ដីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជចូលជាធរមាន
- គ្មានអ្នកបច្ចេកទេសជំនាញក្សេត្រវិទ្យា ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំការនៅមន្ទីរពិសោធន៍ពូជដំណាំរបស់ខ្លួន
- ធ្វើការនាំចេញ នាំចូល ឬដឹកជញ្ជូនពូជដំណាំឆ្លងកាត់ដោយៈ

  ១. មិនធ្វើប្រតិវេទន៍ទំនិញឱ្យបានត្រឹមត្រូវ

  ២. មិនជូនដំណឹងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

  ៣. មិនរាយការណ៍ជាបន្ទាន់មកភ្នាក់ងារភូតគាមអនាម័យក្នុងពេលដឹកជញ្ជូនឆ្លងកាត់មានរបើកស្លាកសុវត្ថិភាព ធ្លុះធ្លាយកុងតឺន័រ ឬ សម្ភារៈវេចខ្ចប់ ដើម្បីចាត់វិធានការសមស្រប

[27] មាត្រា៧៤ នៃច្បាប់ស្ដីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

៤. មិនបានបំពេញលក្ខខណ្ឌភូតគាមអនាម័យ

៥. មិនមានការវេចខ្ចប់ត្រឹមត្រូវ ឬ ខូចខាតសម្ភារៈវេចខ្ចប់ ឬ ស្លាកសញ្ញា។[28]

ប្រសិនបើបុគ្គលដែលប្រព្រឹត្តបទល្មើសមិនរាងចាល គឺនឹងត្រូវទទួលពិន័យអន្តរការណ៍ទ្វេដង ឬ បញ្ជូនសំណុំរឿងទៅតុលាការ។

ចំពោះបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម៖

- ធ្វើអាជីវកម្មពូជដំណាំ ឬ នាំចូលពូជដំណាំដើម្បីធ្វើការសិក្សាពិសោធន៍ដោយគ្មានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ធ្វើអាជីវកម្មពូជដំណាំ ដោយគ្មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ
- យកផលិតផលដែលបាននាំចូល ដើម្បីបម្រើឧស្សាហកម្ម ការប្រើប្រាស់ ឬគោលបំណងផ្សេងៗទៀត ទៅប្រើប្រាស់ជាពូជដំណាំ ឬ កែច្នៃ ដើម្បីប្រើប្រាស់ជាពូជដំណាំ
- ធ្វើការនាំចេញ ឬ នាំចូលពូជដំណាំដោយៈ

  ១. គ្មានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

  ២. គ្មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ។
- ធ្វើការដឹកជញ្ជូនឆ្លងកាត់ ដោយគ្មានវិញ្ញាបនបត្របញ្ជាក់ពីគុណភាពពូជដំណាំចេញដោយសមត្ថកិច្ចនៃប្រទេសនាំចេញ
- ធ្វើអាជីវកម្ម ឬ ចរាចរលើទីផ្សារនូវពូជដំណាំដែលៈ

  ១. ពុំមានគុណភាពទៅតាមពត៌មាន ដែលមានចែងលើសំបកវេចខ្ចប់ ឬ ស្លាកសញ្ញា

  ២. ហួសរយៈពេលកំណត់នៃការប្រើប្រាស់

  ៣. មិនមានស្លាកសញ្ញា ស្របតាមការកំណត់។[29]

ដូចនេះបុគ្គលដែលប្រព្រឹត្តបទល្មើសដូចចែងខាងលើនេះ នឹងត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួន ២(ពីរ) ដង នៃតម្លៃវត្ថុតាងពិតប្រាកដលើទីផ្សារ និង ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ទ្វេដង និងត្រូវ

[28] មាត្រា៧៨ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

[29] មាត្រា៧៩ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

ដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្ម លិខិតអនុញ្ញាតនាំចេញ-នាំចូល ឬ វិញ្ញាបនបត្របញ្ជាក់គុណភាពដំណាំ ឬ បញ្ជូនសំណុំរឿងទៅតុលាការ។

### ២.២.៣.២ ទោសព្រហ្មទណ្ឌ

នៅក្នុងការគ្រប់គ្រងពូជដំណាំ ការផ្តល់នូវព័ត៌មានមិនពិត ការរំលោភបំពានដោយចេតនាលើសិទ្ធិការពារពូជថ្មីនៃដំណាំ គឺសុទ្ធតែជាបទល្មើស។ ក្រៅពីនេះ បទល្មើសលើអាជីវកម្មពូជដំណាំ បទល្មើសដោយមន្ត្រីអនុវត្តច្បាប់ ក៏ត្រូវទទួលទោសតាមច្បាប់កំណត់ផងដែរ។ ដោយទណ្ឌកម្ម ចំពោះបទល្មើសរំលោភបំពានទៅលើពូជដំណាំថ្មីដែលមានចែងដូចខាងក្រោមៈ

- បុគ្គលណាមួយដែលផ្តល់ពត៌មានមិនពិតនៅក្នុងឯកសារ ដែលដាក់សុំការការពារពូជថ្មីនៃដំណាំ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល ទៅ ៥.០០០.០០០ (ប្រាំលាន)រៀល ឬ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ខែ ទៅ ៦ (ប្រាំមួយ)ខែ ឬ ត្រូវផ្តន្ទាទោសទាំងពីរខាងលើ។ ប្រសិនបើបុគ្គលនោះមិនរាងចាល នៅតែប្រព្រឹត្តបទល្មើសដដែល នោះត្រូវផ្តន្ទាទោសទ្វេដង។[30]
- បុគ្គលណាមួយដែលរំលោភដោយចេតនាលើសិទ្ធិការពារពូជថ្មីនៃដំណាំដូច មានចែងក្នុងមាត្រា១៥ នៃច្បាប់ស្តីពីគ្រប់គ្រងពូជដំណាំ និងអ្នកបង្កាត់ពូជដំណាំ ឆ្នាំ ២០០៨ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន)រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន)រៀល ឬ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ឆ្នាំ ទៅ ៥ (ប្រាំ)ឆ្នាំ ឬ ត្រូវផ្តន្ទាទោសទាំងពីរខាងលើ។ ប្រសិនបើបុគ្គលប្រព្រឹត្តបទល្មើសនោះមិនរាងចាលគឺត្រូវផ្តន្ទាទោសទ្វេដង។[31]
- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ ១(មួយ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀល ឬ ត្រូវផ្តន្ទាទោសណាមួយនៃទោសទាំងពីរ និងត្រូវដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ បំផ្លាញចោលវត្ថុតាង ឬ រឹបអូសវត្ថុតាងទាំងអស់មកជាសម្បត្តិរដ្ឋ ចំពោះបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសណាមួយ ដូចខាងក្រោមៈ

[30] មាត្រា៧១ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

[31] មាត្រា៧២ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

១. នាំចូលពូជដំណាំចម្លែងបង្កគ្រោះថ្នាក់មកក្នុងព្រះរាជាណាចក្រកម្ពុជា

២. នាំចេញពូជដំណាំ ដោយបំពានបម្រាមរបស់រដ្ឋនៅពេលដែលព្រះរាជាណាចក្រកម្ពុជាមានតម្រូវការចាំបាច់

៣. ក្លែងបន្លំគុណភាពពូជដំណាំ

ប្រសិនបើក្នុងករណីបុគ្គលដែលប្រព្រឹត្តបទល្មើសនោះមិនរាងចាល នឹងត្រូវផ្តន្ទាទោសទ្វេដង ដោយពុំទាន់គិតពីការទទួលខុសត្រូវរដ្ឋប្បវេណីថែមទៀត ក្នុងករណីមានផលប៉ះពាល់ដល់សុខភាពសាធារណៈ ឬ ខូចខាតក្សេត្របរិស្ថាន។[32]

**២.២.៣.៣ វិធានការរដ្ឋបាល**

ចំពោះបទល្មើសដោយមន្ត្រីអនុវត្តច្បាប់ យោងតាមមាត្រា៨១ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ឆ្នាំ ២០០៨ បានចែងថា "ភ្នាក់ងារអធិការកិច្ច ឬ មន្ត្រីរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬ មិនគោរពបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាល នឹង/ឬចោទប្រកាន់ ចំពោះមុខតុលាការ។

ភ្នាក់ងារអធិការកិច្ច ឬ មន្ត្រីរូបណាដែលសមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬ ជួយសម្រួលដល់ការប្រព្រឹត្តបទល្មើសនេះ ត្រូវផ្តន្ទាទោសដូចចារីដែរ។

## ២.៣ ការបញ្ចប់ មោឃភាព និងការលុបចោល

### ២.៣.១ ការបញ្ចប់

ដោយយោងតាមមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ដែលបានអនុម័តនៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៨ បានចែងថា "សិទ្ធិការពារពូជដំណាំថ្មីនៃនឹងត្រូវបានបញ្ចប់មុនកាលបរិច្ឆេទផុតសុពលភាព ក្នុងករណីដែលម្ចាស់សិទ្ធិបោះបង់ចោលសិទ្ធិ ដោយធ្វើលិខិតជូនដំណឹងជាលាយល័ក្ខណ៍អក្សរជូនមន្ត្រីកាន់កាប់បញ្ជីនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ កាលបរិច្ឆេទនៃការបញ្ចប់ត្រូវបញ្ជាក់ក្នុងលិខិតជូនដំណឹង ឬ បើគ្មានការកំណត់កាលបរិច្ឆេទសុំបញ្ជាក់ច្បាស់លាស់ នៅក្នុងលិខិតជូនដំណឹងនោះទេ ត្រូវយកកាលបរិច្ឆេទដែលមន្ត្រីកាន់កាប់បញ្ជីទទួលបានលិខិតជូនដំណឹងនោះ"។

[32] មាត្រា៨០ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

**២.៣.២ ការមោឃភាព**

មន្ត្រីកាន់កាប់បញ្ជី ត្រូវប្រកាសជាមោឃភាពនូវសិទ្ធិរបស់ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំក្នុងករណីរកឃើញថា៖

- លក្ខខណ្ឌដូចមានចែងនៅក្នុងមាត្រា៧ ឬ មាត្រា៨ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ឆ្នាំ២០០៨ មិនបានបំពេញដូចកាលពីពេលផ្តល់សិទ្ធិ។
- លក្ខខណ្ឌដូចមានចែងនៅក្នុងមាត្រា៩ ឬ មាត្រា១០ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជ មិនបានបំពេញដូចកាលពីពេលផ្តល់សិទ្ធិ ដោយផ្អែកលើព័ត៌មាន និងឯកសារដែលផ្តល់ដោយអ្នកបង្កាត់ពូជដំណាំ។
- សិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំ ត្រូវបានផ្តល់ទៅឱ្យបុគ្គលដែលគ្មានសិទ្ធិទទួល លើកលែងតែសិទ្ធិនេះផ្ទេរទៅឱ្យបុគ្គលដែលមានសិទ្ធិទទួល។[33]

**២.៣.៣ ការលុបចោល**

មន្ត្រីកាន់កាប់បញ្ជី ត្រូវលុបសិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំក្នុងករណីដូចខាងក្រោម៖

- លក្ខខណ្ឌដូចមានចែងក្នុងមាត្រា៩ ឬ មាត្រា១០ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ឆ្នាំ ២០០៨ លែងបំពេញបាន។
- ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ មិនបានអនុវត្តតាមការតម្រូវរបស់មន្ត្រីកាន់កាប់បញ្ជីដោយៈ
    - មិនបានផ្តល់នូវព័ត៌មាន ឯកសារ ឬ ពូជដំណាំ ដែលចាំបាច់សម្រាប់ការផ្ទៀងផ្ទាត់
    - ខកខានមិនបានបង់កម្រៃ ដើម្បីរក្សាសិទ្ធិឱ្យនៅជាធរមាន ឬ
    - មិនបានផ្តល់ឈ្មោះថ្មីសមស្រប បន្ទាប់ពីឈ្មោះពូជដំណាំដែលទទួលបានសិទ្ធិការពារនោះត្រូវបានលុប។[34]

[33] មាត្រា២១ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

[34] មាត្រា២២ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានដាក់ឱ្យប្រើនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨

# ជំពូកទី ៣
# ស្ថាប័នអនុវត្តនៅលើការគ្រប់គ្រងពូជដំណាំថ្មី

# ជំពូកទី ៣
# ស្ថាប័នអនុវត្តទៅលើការគ្រប់គ្រងពូជដំណាំថ្មី

ដើម្បីឱ្យមានដំណើរការបានល្អក្នុងការការពារពូជថ្មីនៃដំណាំគឺត្រូវពឹងផ្អែកទៅលើយន្តការក្នុងការការពារ ប្រសិនបើគ្មានយន្តការនៃការការពារទេ ដំណើរនៃការការពារនឹងមិនអាចមានប្រសិទ្ធិភាពឡើយ។ តើមានយន្តការអ្វីខ្លះ? កើតឡើងយ៉ាងដូចម្តេច? ចំពោះយន្តការនៃការការពារមិនអាចកើតមានឡើងដោយខ្លួនឯងបានទេ គឺទាល់តែមានស្ថាប័នផ្សេងៗជាអ្នកបង្កើតឡើង ស្ថាប័នទាំងនោះរួមមានស្ថាប័នជាតិ និងស្ថាប័នអន្តរជាតិ ព្រមទាំងអង្គការនានាដែលពាក់ព័ន្ធនឹងការការពារពូជដំណាំថ្មី ដែលស្ថាប័នទាំងនោះមានតួនាទីក្នុងការបង្កើតឱ្យមាននូវយន្តការក្នុងការត្រួតពិនិត្យ និងការផ្តល់ជាជំនួយក្នុងការជំរុញដល់ការអនុវត្តយន្តការនៃការការពារ។ ដោយមើលឃើញថាស្ថាប័នទាំងនេះដើរតួនាទីសំខាន់ក្នុងការការពារ យើងនឹងធ្វើការបកស្រាយពីស្ថាប័នទាំង ៣ ដោយលើកយកកថាខណ្ឌ១ បកស្រាយអំពី “ **ស្ថាប័នជាតិ** ” កថាខណ្ឌ២ បកស្រាយអំពី “ **ស្ថាប័នអន្តរជាតិ** ” និង កថាខណ្ឌ៣ បកស្រាយអំពី “ **អង្គការនានាដែលពាក់ព័ន្ធនឹងការការពារពូជដំណាំថ្មី** ” ។

## ៣.១ ស្ថាប័នជាតិ

### ៣.១.១ គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា

រយៈពេល ៨ ឆ្នាំក្រោយពេលកម្ពុជាយើងចូលជាសមាជិក នៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ការត្រៀមខ្លួនអនុវត្តនកិច្ចព្រមព្រៀងកម្មសិទ្ធិបញ្ញាពាក់ព័ន្ធនឹងពាណិជ្ជកម្ម ត្រូវបានពង្រឹង ដែលស្របទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាលគឺ “ ការពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ” ។ ដើម្បីបង្រួមការធ្វើគោលនយោបាយ ការពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា និងជំនួយបច្ចេកទេស រាជរដ្ឋាភិបាល កម្ពុជាបានចេញអនុក្រឹត្យស្តីពី “ **ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា** ” ដែលហៅកាត់ គ.ក.ប ត្រូវបានបង្កើតឡើងដោយអនុក្រឹតលេខ ១៤២ អនក្រ.បក ចុះថ្ងៃទី១៨ ខែ កញ្ញា ឆ្នាំ២០០៨ ដោយមាននាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មជាលេខាធិការដ្ឋាន។ គណៈកម្មាធិការនេះ ទទួលខុសត្រូវបង្កើតគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញាពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួង ឬ ស្ថាប័នផ្សេងៗ ក្នុងគោលបំណងជម្រុញ ធានានូវគោលនយោបាយកម្មសិទ្ធិបញ្ញារបស់ជាតិ និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការរៀបចំផ្សព្វផ្សាយ និងអនុវត្តច្បាប់និងបទប្បញ្ញត្តិកម្មសិទ្ធិបញ្ញាឱ្យមានភាពរលូន ស្របតាមការសន្យារបស់ប្រទេសកម្ពុជា នៅពេលចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំងសហការទទួលនិងប្រើប្រាស់ជំនួយពាក់ព័ន្ធនឹង

វិស័យកម្មសិទ្ធិបញ្ញាពីអង្គការអន្តរជាតិ និងប្រទេសនានាឱ្យមានប្រសិទ្ធិភាពខ្ពស់។[35] ដោយផ្អែកលើភារកិច្ចដែលមានចែងក្នុងអនុក្រឹត្យ នាយកដ្ឋានកម្មសិទ្ធិបញ្ញាដែលជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា បានសហការជាមួយអង្គការ រៀបចំផែនការសកម្មភាពមួយចំនួនក្នុងគោលដៅជាក់លាក់មួយ ដើម្បីបង្កើតប្រព័ន្ធកម្មសិទ្ធិបញ្ញាជាតិដ៏ខ្លាំងមួយ សម្រាប់ការពារកម្មសិទ្ធិបញ្ញា ការគ្រប់គ្រង និងការអនុវត្តច្បាប់ឱ្យស្របទៅនឹងស្តង់ដារកម្មសិទ្ធិបញ្ញាអន្តរជាតិ និងគាំទ្រគោលដៅអភិវឌ្ឍន៍ពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាល។ នាពេលបច្ចុប្បន្ន នាយកដ្ឋានកម្មសិទ្ធិបញ្ញាកំពុងមានទិសដៅទៅមុខបន្ថែមទៀត ដោយធ្វើសេចក្តីព្រាងអនុក្រឹត្យមួយស្តីពីការពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ការអប់រំ និងផ្សព្វផ្សាយ។

គណៈកម្មាធិការគ្រប់គ្រងកម្មសិទ្ធិបញ្ញា មានសមាសភាពដូចខាងក្រោម៖[36]

- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធាន
- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អនុប្រធាន
- រដ្ឋលេខាធិការក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ អនុប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាងក្រសួងមហាផ្ទៃ សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក
- តំណាងក្រសួងព័ត៌មាន សមាជិក
- តំណាងក្រសួងប្រៃសណីយ៍ និង ទូគមនាគមន៍ សមាជិក
- តំណាងក្រសួងសុខាភិបាល សមាជិក
- តំណាងក្រសួងរុក្ខាប្រមាញ់ និង នេសាទ សមាជិក
- តំណាងក្រសួងបរិស្ថាន សមាជិក
- តំណាងក្រសួងយុត្តិធម៌ សមាជិក
- តំណាងក្រសួងអប់រំ យុវជន និង កីឡា សមាជិក
- តំណាងក្រសួងទេសចរណ៍ សមាជិក។

[35] នីតិសៀវភៅនីតិកម្មសិទ្ធិបញ្ញា ឯកឧត្តម ឥន យឿន និងសាស្ត្រាចារ្យ អ៊ុក វណ្ណារ័ត្ន បោះពុម្ពលើកទី១ ឆ្នាំ២០១៣

[36] មាត្រា ៣ អនុក្រឹតលេខ ១៤២ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០០៨

គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា មានភារកិច្ចមួយចំនួនដោយផ្អែកទៅលើអនុក្រឹត្យដែលបានចែងភារកិច្ចនោះមានដូចជាៈ

- ទទួលបន្ទុកជាចំណុចកណ្តាល ក្នុងការសម្របសម្រួលកិច្ចសហប្រតិបត្តិការទ្វេភាគី ឬ ពហុភាគី ក្នុងវិស័យកម្មសិទ្ធិបញ្ញាជាមួយបណ្តាប្រទេស និងអង្គការអន្តរជាតិនានា។
- សម្របសម្រួលឱ្យមានភាពរលូនលើរាល់ការងារដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា និងក្រសួងស្ថាប័នពាក់ព័ន្ធ
- សហការជម្រុញ រៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធទៅនឹងកម្មសិទ្ធិបញ្ញា និងការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិនានា។
- ទទួល និង ប្រើប្រាស់ជំនួយបច្ចេកទេសពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញាពីបណ្តាប្រទេស និង អង្គការអន្តរជាតិ។
- សហការជាមួយក្រសួងពាក់ព័ន្ធផ្សព្វផ្សាយច្បាប់ និង បទប្បញ្ញត្តិនានា ព្រមទាំងចំណេះដឹងផ្នែកកម្មសិទ្ធិបញ្ញាដល់មហាជន មន្ត្រីអនុវត្តច្បាប់ និងសិស្សនិស្សិតតាមគ្រឹះស្ថានអប់រំសិក្សា។
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនានា ស្ថាប័នតុលាការ ដើម្បីទប់ស្កាត់ និងបញ្ឈប់ការរំលោភបំពានកម្មសិទ្ធិបញ្ញា។
- សហការសិក្សាស្រាវជ្រាវកិច្ចព្រមព្រៀង និង អនុសញ្ញាអន្តរជាតិនានា ដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា ដើម្បីពិចារណាអំពីអត្ថប្រយោជន៍ ចំណុចខ្លាំង ចំណុចខ្សោយ មុននឹងរាយការណ៍សុំការយល់ព្រមចូលជាសមាជិកពីប្រមុខរាជរដ្ឋាភិបាល។
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនរាជរដ្ឋាភិបាលយ៉ាងតិចមួយឆ្នាំម្តង និងតាមដំណាក់កាលនីមួយៗ។[37]

### ៣.១.២ ក្រសួងពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្ម គឺជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងនោះដែរ ក្រសួងពាណិជ្ជកម្មក៏ជាលេខាធិការដ្ឋាន ដែលមានតួនាទីជាប្រធាន និងមានអនុប្រធានពីរទៀត គឺក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងកសិកម្ម។ ក្នុងការគ្រប់គ្រង និងដឹកនាំវិស័យពាណិជ្ជកម្មនៅទូទាំង

[37] មាត្រា ៤ អនុក្រឹតលេខ ១៤២ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០០៨

ព្រះរាជាណាចក្រកម្ពុជា។ ក្រសួងពាណិជ្ជកម្ម ឬស្ថាប័នគ្រប់គ្រងការធ្វើពាណិជ្ជកម្ម បានបង្កើតឡើងស្ទើរគ្រប់សម័យកាលរបស់កម្ពុជាដោយឡែកចំពោះរចនាសម្ព័ន្ធនៃស្ថាប័ននេះ ត្រូវបានធ្វើការកែប្រែ ជាបន្តបន្ទាប់អាស្រ័យលើការវិវត្តនៃវិស័យពាណិជ្ជកម្ម ហើយត្រូវបានធ្វើបច្ចុប្បន្នភាពចុងក្រោយនៅឆ្នាំ២០១៤។ បន្ទាប់ពីរួចផុតពីរបបកម្ពុជាប្រជាធិបតេយ្យ រាជរដ្ឋាភិបាលថ្មីនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៨៩) ក្នុងនោះក្រសួងពាណិជ្ជកម្មដែលមានឈ្មោះថា ក្រសួងពាណិជ្ជកម្មក្នុងស្រុក និង ក្រៅស្រុក ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យច្បាប់លេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ១៩៨២។ ក្នុងសម័យកាលនោះ ការចុះបញ្ជីបង្កើតក្រុមហ៊ុន ឬ ការចុះបញ្ជីកម្មសិទ្ធិបញ្ញាពុំទាន់ត្រូវបានបង្កើតឡើងនៅឡើយទេ ពោលគឺក្រសួងពាណិជ្ជកម្ម ក្នុងស្រុក និងក្រៅស្រុក ពេលនោះគឺទទួលបន្ទុកពាក់ព័ន្ធតែទៅលើការប្រតិបត្តិការទិញលក់ ការនាំចេញ-នាំចូល ទំនិញក្នុង និងក្រៅស្រុក ការផ្គត់ផ្គង់សម្ភារៈជាអាទិ៍។

មកដល់ឆ្នាំ ១៩៩៣ ដោយមានការជួយជ្រោមជ្រែងពីភ្នាក់ងារអង្គការសហប្រជាជាតិ ហៅកាត់ថា អ៊ុនតាក់ ព្រះរាជាណាចក្រកម្ពុជាទី២ បានលេចរូបរាងឡើង ជ្រកក្រោមដំបូល នៃរបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ដែលបានអនុវត្តនូវប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី។ បន្ទាប់ពីបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី១រួចមក រាជរដ្ឋាភិបាលបានចាប់ផ្តើមរៀបចំរចនាសម្ព័ន្ធរបស់ខ្លួន ហើយរដ្ឋាភិបាលបណ្តោះអាសន្នត្រូវបានបង្កើតឡើង តាមអនុក្រឹត្យ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៣ ដែលក្នុងនោះមានឯកឧត្តម **វ៉ារ ហួត** និងឯកឧត្តម **លូ ឡាយស្រេង** ជាសហរដ្ឋមន្ត្រី។ រហូតមកដល់ឆ្នាំ ១៩៩៦ ទើបក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតឡើងជាផ្លូវការ តាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម ដែលត្រូវដឹកនាំឱ្យរដ្ឋមន្ត្រីមួយរូប អមដោយរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមួយរូប ឬច្រើនរូប តាមការចាំបាច់។ ដោយឡែកចំពោះការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម ត្រូវកំណត់ដោយអនុក្រឹត្យដំបូង លេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ក្នុងនោះមាននាយកដ្ឋានកម្មសិទ្ធិបញ្ញា ប៉ុន្តែពុំមាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មទេ ស្ថិតក្រោមអគ្គនាយកដ្ឋានបច្ចេកទេស។ ក្រោយមកអនុក្រឹត្យ លេខ៩១ អនក្រ.បក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៧ បាននិរាករណ៍អនុក្រឹត្យ លេខ៥៤ និងបានបង្កើតនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ព្រមទាំងនាយកដ្ឋានកម្មសិទ្ធិបញ្ញា ស្ថិតក្រោមអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងស្រុក ហើយជាថ្មីម្តងទៀត អនុក្រឹត្យ លេខ៩១ នេះត្រូវបានជំនួសដោយ អនុក្រឹត្យ លេខ១៣២ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ ដែលដាក់នាយកដ្ឋានទាំងពីរនេះ នៅក្រោមអគ្គនាយកដ្ឋានថ្មីមួយ គឺ អគ្គនាយកដ្ឋាន សេវាពាណិជ្ជកម្ម រហូតមកដល់បច្ចុប្បន្ននេះ។ យ៉ាងណាមិញគួរកត់សម្គាល់ថា រាជរដ្ឋាភិបាល

ក្នុងនីតិកាលទី២ទី៣ និងទី៤ ក្រសួងពាណិជ្ជកម្ម ត្រូវបានដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធិ ដោយឡែកក្នុងនីតិកាលទី៥ ត្រូវបានដឹកនាំដោយ ឯកឧត្តម ប៉ាន សូរស័ក្តិ ជារដ្ឋមន្ត្រីរហូតមកដល់បច្ចុប្បន្ន។[38]

## ៣.២ ស្ថាប័នអន្តរជាតិ

បន្ទាប់ពីបានសិក្សាស្វែងយល់អំពីបណ្តាស្ថាប័នជាតិ ដែលមានគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា និងក្រសួងពាណិជ្ជកម្ម ដែលជាស្ថាប័នដែលពាក់ព័ន្ធនឹងការការពារពូជដំណាំថ្មីរួចហើយ ដូចនេះយើងនឹងលើកយកនូវស្ថាប័នអន្តរជាតិ ដែលមានសមត្ថកិច្ចក្នុងការបង្កើតឱ្យមានការពារពូជដំណាំថ្មី មកធ្វើការសិក្សាបន្ថែមទៀត ព្រោះថាការអនុវត្តនូវកិច្ចការពារពូជដំណាំថ្មីនេះបានដោយរលូន និងមានប្រសិទ្ធិភាព ក៏ត្រូវទាមទារឱ្យមានការចូលរួមបន្ថែមពីស្ថាប័នអន្តរជាតិផងដែរ នៅក្នុងកថាខណ្ឌនេះយើងនឹងលើកពីរចំណុចមកសិក្សា ទីមួយគឺ សហភាពអន្តរជាតិសម្រាប់ការការពារពូជដំណាំថ្មី UPOV និងទីពីរគឺ វេទិកាការពារការបង្កាត់ពូជដំណាំអាស៊ីបូព៌ា (EAPVP) ។

### ៣.២.១ សហភាពអន្តរជាតិសម្រាប់ការការពារពូជដំណាំថ្មី (UPOV)

#### ៣.២.១.១ សញ្ញាណទូទៅនៃសហភាពអន្តរជាតិសម្រាប់ការការពារពូជដំណាំថ្មី

សហភាពអន្តរជាតិសម្រាប់ការការពាររុក្ខជាតិថ្មី ដែលហៅកាត់ថា យូប៉ូវ UPOV គឺជាអង្គការអន្តររដ្ឋាភិបាល ដែលមានទីស្នាក់ការកណ្តាលនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។ យូប៉ូវ UPOV ត្រូវបានបង្កើតឡើងដោយអនុសញ្ញាអន្តរជាតិសម្រាប់ការការពារពូជដំណាំថ្មី ហើយអនុសញ្ញានេះត្រូវបានអនុម័តបង្កើតនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៦១ នៅទីក្រុងប៉ារីស ប្រទេសបារាំង ក្រោយមកអនុសញ្ញានេះត្រូវបានកែសម្រួលជាបន្តបន្ទាប់នៅឆ្នាំ ១៩៧២ ១៨៨៧ និង ១៩៩១។[39] យូប៉ូវ UPOV ត្រូវបានធ្វើបច្ចុប្បន្នភាពជាច្រើនដងនេះ ក៏ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរបច្ចេកវិទ្យា និងបង្កើនការយល់ដឹងអំពីច្បាប់កម្មសិទ្ធិ ទាក់ទងនឹងពូជដំណាំថ្មីឱ្យកាន់តែច្បាស់។

បេសកកម្មដ៏សំខាន់របស់យូប៉ូវ UPOV គឺផ្តល់នូវប្រព័ន្ធការពារពូជដំណាំប្រកបដោយប្រសិទ្ធភាព ដោយលើកកម្ពស់កិច្ចអភិវឌ្ឍន៍ប្រព័ន្ធប្រសិទ្ធភាពនៃការការពារពូជរុក្ខជាតិ ដោយមានគោលបំណងជំរុញឱ្យមានការអភិវឌ្ឍនូវរុក្ខជាតិថ្មីៗ ដើម្បីជាប្រយោជន៍ដល់សង្គម។ លើសពីនេះទៅទៀតចំនួនសមាជិករបស់ UPOV បាន

[38] https://drive.google.com/file/d/0B2BhecGG1FSecVVyd2t0bUR5bkU/view?resourcekey=0-6NXJ6aw5IAPk38wsHIeE7A (កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២១)

[39] https://www.upov.int/portal/index.html.en (កាលបរិច្ឆេទចូលមើល ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១)

កើនឡើងជាបន្តបន្ទាប់ចាប់ពីពេលដែលបានបង្កើតឡើងរហូតមកទល់បច្ចុប្បន្ននេះ ដែលបានបញ្ជាក់យ៉ាងច្បាស់ថាពិភពលោកកំពុងតែមានការចាប់អារម្មណ៍ និងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការការពារពូជថ្មីនៃដំណាំ។

អនុសញ្ញា យូប៉ូវ UPOV ផ្តល់នូវមូលដ្ឋានសម្រាប់សមាជិក UPOV ដើម្បីលើកទឹកចិត្តដល់ការបង្កាត់ពូជដំណាំដោយផ្តល់នូវកម្មសិទ្ធិដល់អ្នកបង្កាត់ពូជដំណាំថ្មី តាមរយៈការដាក់ពាក្យសុំតាមរយៈអាជ្ញាធរនៃសមាជិករបស់យូប៉ូវ UPOV ។ បើគិតពីថ្ងៃចាប់ផ្តើមរហូតមកដល់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ យូប៉ូវ UPOV មានសមាជិកចំនួន ៧៧ ប្រទេស[40] ដោយឡែក កម្ពុជាគឺជាប្រទេសសង្កេតការណ៍មួយនៃយូប៉ូវ UPOV ពេលកម្ពុជាពុំទាន់ក្លាយជាសមាជិករបស់យូប៉ូវ UPOV នៅឡើយទេ បន្ថែមពីនេះ ប្រទេសដែលជាសមាជិកនៃអាស៊ានទាំង១០ គឺមានតែ ពីរ ប្រទេសប៉ុណ្ណោះដែលបានក្លាយជាសមាជិកពេញសិទ្ធិរបស់យូប៉ូវ UPOV គឺមានប្រទេសសឹង្ហបុរី និងប្រទេសវៀតណាម។

ខាងក្រោមនេះជាតារាងបង្ហាញអំពីចំនួនសមាជិករបស់យូប៉ូវ UPOV ចាប់តាំងពីឆ្នាំ១៩៦៨ រហូតមកដល់បច្ចុប្បន្ននេះ[41] ៖

| ឆ្នាំ | ចំនួនប្រទេស |
|---|---|
| ១៩៦០ - ១៩៦៩ | ៤ |
| ១៩៧០ - ១៩៧៩ | ៧ |
| ១៩៨០ - ១៩៨៩ | ៨ |
| ១៩៩០ - ១៩៩៩ | ២៥ |
| ២០០០ - ២០០៩ | ២៤ |
| ២០១០ - ២០២១ | ៩ |
| **សរុប** | **៧៧** |

[40] https://www.upov.int/edocs/pubdocs/en/upov_pub_437.pdf (កាលបរិច្ឆេទចូលមើល ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១)

[41] https://www.upov.int/edocs/pubdocs/en/upov_pub_423.pdf (កាលបរិច្ឆេទចូលមើល ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១)

ប្រទេសដែលចូលជាសមាជិកចុងក្រោយគេគឺ Saint Vincent and the Grenadines គឺនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១។[42]

### ៣.២.១.២ រចនាសម្ព័ន្ធរបស់សហភាពអន្តរជាតិសម្រាប់ការការពារពូជដំណាំថ្មី

❖ **ក្រុមប្រឹក្សា ( The Council )**

ក្រុមប្រឹក្សា និងការិយាល័យរបស់សហភាព គឺជាស្ថាប័នអចិន្ត្រៃយ៍នៃសហភាព ( មាត្រា ២៥ នៃអនុសញ្ញាយូប៉ូវ UPOV ឆ្នាំ១៩៩១)[43] ក្រុមប្រឹក្សាត្រូវមានតំណាងសមាជិកទាំងឡាយនៃសហភាព។ សមាជិកនីមួយៗនៃសហភាពត្រូវចាត់តំណាងមួយរូបប្រចាំនៅក្រុមប្រឹក្សា និងអ្នកជំនួសមួយរូប អ្នកតំណាង ឬអ្នកជំនួសអាចអមដោយជំនួយការ ឬទីប្រឹក្សាមួយចំនួនផងដែរ។

ភារកិច្ចរបស់ក្រុមប្រឹក្សារួមមាន៖

- សិក្សាទៅលើវិធានការណ៍ដែលសមស្របដើម្បីការពារផលប្រយោជន៍ និងដើម្បីជំរុញឱ្យមានការអភិវឌ្ឍរបស់សហភាព។
- តែងតាំងអគ្គលេខាធិការ ហើយក្នុងករណីចាំបាច់មានការតែងតាំងអគ្គលេខាធិការរង និងការកំណត់អាណត្តិនៃការតែងតាំងនីមួយៗ ។
- ត្រួតពិនិត្យរបាយការណ៍ប្រចាំឆ្នាំលើសកម្មភាពរបស់សហភាព និងដាក់ចេញនូវកម្មវិធីនយោបាយសម្រាប់ការងារទៅថ្ងៃអនាគតរបស់ខ្លួន។
- ផ្តល់ឱ្យអគ្គលេខាធិការនូវសេចក្តីបង្គាប់សំខាន់ៗទាំងអស់ សម្រាប់ការសម្រេចបាននូវសមិទ្ធផលនៃភារកិច្ចរបស់សហភាព។
- ត្រួតពិនិត្យ និងអនុម័តយល់ព្រមថវិការបស់សហភាព និងកំណត់ការចូលរួមវិភាគទាននៃសមាជិកនីមួយៗរបស់សហភាព។
- ត្រួតពិនិត្យ និងអនុម័តយល់ព្រមលើគណនីដែលបង្ហាញដោយអគ្គលេខាធិការ។
- កំណត់កាលបរិច្ឆេទ និងទីកន្លែងសន្និសិទដែលយោងទៅតាមមាត្រា៣៦ និងចាត់វិធានការណ៍ចាំបាច់សម្រាប់រៀបចំ។

[42] https://internationalipcooperation.eu/en/caripi/news/saint-vincent-and-grenadines-accedes-international-convention-protection-new-varieties (កាលបរិច្ឆេទចូលមើល ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១)

[43] Article 21 (INTERNATIONAL CONVENTION FOR THE PROTECTION OF NEW VARIETIES OF PLANTS)

- ចេញសេចក្តីសម្រេចចាំបាច់ទាំងអស់ ដើម្បីធានាការប្រព្រឹត្តទៅដ៏មានប្រសិទ្ធិភាពរបស់សហភាព។[44]

❖ **គណៈកម្មាធិការពិគ្រោះយោបល់**

នៅថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ១៩៦៨ ក្រុមប្រឹក្សាបានចេញសេចក្តីសម្រេចបង្កើតគណៈកម្មាធិការសម្រាប់ការងារពិគ្រោះយោបល់នៅកិច្ចប្រជុំដំបូងរបស់ខ្លួន ដែលក្រោយមក គណៈកម្មាធិការនេះបានផ្លាស់ប្តូរឈ្មោះរបស់ខ្លួនទៅជាគណៈកម្មាធិការពិគ្រោះយោបល់វិញ ដែលទទួលបន្ទុកក្នុងការរៀបចំកិច្ចប្រជុំ ផ្សេងៗរបស់ក្រុមប្រឹក្សា។

❖ **គណៈកម្មាធិការរដ្ឋបាល និងនីតិកម្ម**

នៅថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ១៩៧៧ នៅក្នុងសម័យប្រជុំលើកទី១៦ របស់គណៈកម្មាធិការពិគ្រោះយោបល់បានសម្រេចឱ្យបង្កើតគណៈកម្មាធិការរដ្ឋបាល និងនីតិកម្ម ស្របពេលនោះដែល គណៈកម្មាធិការនេះបានពិភាក្សាគ្នាអស់រយៈពេលយ៉ាងយូរទៅលើបញ្ជីគណៈកម្មាធិការនានា និងស្ថាប័នដទៃទៀតរបស់យូប៉ូវ(UPOV)។ នៅចុងបញ្ចប់ គណៈកម្មាធិការនេះបានសម្រេចក្នុងការស្នើឱ្យមានការរៀបចំឡើងវិញនូវសកម្មភាពរបស់ស្ថាប័ននានារបស់យូប៉ូវ UPOV នៅក្នុងបែបបទដូចខាងក្រោម៖

- ក្រុមប្រឹក្សា និងគណៈកម្មាធិការពិគ្រោះយោបល់ដែលត្រូវបានបង្កើតឡើងដោយអនុសញ្ញាយូប៉ូវ UPOV នោះនឹងបន្តសកម្មភាពរបស់ខ្លួនដដែល។
- កិច្ចការនានាដែលទាក់ទងនឹងលក្ខណៈបច្ចេកទេសត្រូវបានដោះស្រាយ ដោយគណៈកម្មាធិការអចិន្ត្រៃយ៍បច្ចេកទេស ដែលក្រោយមកត្រូវបានប្តូរឈ្មោះទៅជាគណៈកម្មាធិការបច្ចេកទេសដោយសារតែការពង្រីកសកម្មភាពរបស់ខ្លួន និងមានការចូលរួមចំណែកពីក្រុមការងារបច្ចេកទេសដែលស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យនៃគណៈកម្មាធិការបច្ចេកទេស។
- សម្រាប់កិច្ចការនានាដែលទាក់ទងនឹងលក្ខណៈរដ្ឋបាល និងនីតិកម្ម ព្រមទាំងកិច្ចការងារមួយចំនួន ដែលទាក់ទងនឹងកិច្ចការហិរញ្ញវត្ថុ និងគោលនយោបាយត្រូវដោះស្រាយដោយ

[44] សារណា "ការការពារពូជដំណាំនៅកម្ពុជា" ឈ្មោះនិស្សិត ក.ជា សុវណ្ណរតនៈ និង ក.ឃី លីហួ ឆ្នាំសរសេរសារណា ២០២០ ទំព័រ៦

គណៈកម្មាធិការរដ្ឋបាល និងនីតិកម្មដែលមានសេរីភាពពេញលេញក្នុងការបង្កើតអនុក្រុមនានាសម្រាប់ពិចារណាលើបញ្ហាពិសេសនានា។[45]

❖ **ក្រុមប្រឹក្សាអមគណៈកម្មាធិការរដ្ឋបាល និងនីតិកម្ម ( CAJ-AG )**[46]

នៅក្នុងសម័យប្រជុំលើកទី៥២ ដែលបានប្រារព្ធធ្វើឡើងនៅឯទីក្រុងហ្សឺណែវ ប្រទេសស្វីស នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ គណៈកម្មាធិការរដ្ឋបាល និងនីតិកម្ម CAJ បានយល់ព្រមលើមធ្យោបាយសម្រាប់ការរៀបចំសម្ភារៈព័ត៌មាននានាដែលទាក់ទងនឹងអនុសញ្ញាយូប៉ូវ UPOV និងការបង្កើតឱ្យមាននូវក្រុមប្រឹក្សាអម គណៈកម្មាធិការរដ្ឋបាល និងនីតិកម្មដើម្បីជួយក្នុងការរៀបចំឯកសារ ដែលពាក់ព័ន្ធនឹងសម្ភារៈទាំងអស់។

❖ **គណៈកម្មាធិការបច្ចេកទេស ( Technical Committee )**

នៅក្នុងសម័យប្រជុំលើកទី៥ របស់ខ្លួន ដែលបានប្រារព្ធឡើងនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៧១ ក្រុមប្រឹក្សាបានអនុម័តយល់ព្រមឱ្យបង្កើតគណៈកម្មាធិការគ្រប់គ្រងបច្ចេកទេស (Technical Steering Committee)។ នៅសម័យប្រជុំលើកទី១៦ របស់គណៈកម្មាធិការពិគ្រោះយោបល់ដែលបានប្រារព្ធឡើងនៅទីក្រុងហ្សឺណែវ នៅថ្ងៃទី០៥ ដល់ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៧៧ គណៈកម្មាធិការពិគ្រោះយោបល់បានបើកនូវកិច្ចពិភាក្សារយៈពេលវែងមួយទៅលើបញ្ជីគណៈកម្មាធិការ និងបណ្តាស្ថាប័នទាំងអស់នោះ ក្នុងនោះគណៈកម្មាធិការពិគ្រោះយោបល់យល់ឃើញថា ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនខាងបច្ចេកវិទ្យា គណៈកម្មាធិការពិគ្រោះយោបល់បានស្នើសុំឱ្យមានការផ្លាស់ប្តូរឈ្មោះពីគណៈកម្មាធិការគ្រប់គ្រងបច្ចេកទេស ទៅជាគណៈកម្មាធិការបច្ចេកទេសវិញដោយពង្រីកសកម្មភាពបន្ថែមលើសកម្មភាពដែលធ្លាប់បំពេញពីមុនមក។ សំណើរនោះ ត្រូវបានក្រុមប្រឹក្សាអនុម័តយល់ព្រមនៅសម័យប្រជុំលើកទី១១ នាថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៧៧។ គណៈកម្មាធិការបច្ចេកទេសមានសមាជិកនៃបណ្តារដ្ឋសមាជិករបស់យូប៉ូវ UPOV ទាំងអស់ដែលរដ្ឋនីមួយៗត្រូវតែងតាំងអ្នកតំណាងម្នាក់។ ចំពោះប្រធានបទនៃគណៈកម្មាធិការនេះត្រូវតែងតាំងដោយក្រុមប្រឹក្សាមានរយៈពេល ៣ឆ្នាំ ហើយគាត់បំពេញការងារតំណាងឱ្យគណៈកម្មាធិការទាំងមូលដែលពាក់ព័ន្ធនឹងការងារបច្ចេកទេសលើពូជដំណាំ ការសម្របសម្រួលជាមួយក្រុមការងារបច្ចេកទេស និងការធានាដំណើរការងារឱ្យស្របទៅនឹងគោលនយោបាយរបស់ក្រុមប្រឹក្សា។

**៣.២.១.៣ គោលការណ៍ទូទៅដើម្បីក្លាយជាសមាជិករបស់យូប៉ូវ** (UPOV)

[45] សារណា “ការការពារពូជដំណាំនៅកម្ពុជា” ឈ្មោះនិស្សិត ក.ជា សុវណ្ណរតនៈ និង ក.ឃី លីហួ ឆ្នាំសរសេរសារណា ២០២០ ទំព័រ៧

[46] https://www.upov.int/meetings/en/topic.jsp?group_id=253 (កាលបរិច្ឆេទចូលមើល ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១)

គោលការណ៍ដើម្បីក្លាយជាសមាជិកនៃសហភាពសហព័ន្ធអន្តរជាតិការពារការបង្កាត់ពូជដំណាំរុក្ខជាតិថ្មីរបស់យូប៉ូវ (UPOV) គឺបណ្តារដ្ឋ ឬ អង្គការអន្តរជាតិនានា ចាំបាច់ត្រូវមានលក្ខណៈដូចខាងក្រោម៖

❖ **ការអភិវឌ្ឍន៍វិធានច្បាប់ទាក់ទងនឹងការការពារពូជថ្មីនៃដំណាំដោយអនុលោមតាមអនុសញ្ញាយូប៉ូវ (UPOV) ឆ្នាំ១៩៩១**

រដ្ឋ ឬ អង្គការអន្តររដ្ឋាភិបាលនានាត្រូវបានគេផ្តល់លទ្ធភាពឱ្យទាក់ទងទៅការិយាល័យ នៃសហភាពអន្តរជាតិការពារពូជថ្មីនៃដំណាំយូប៉ូវ UPOV នៅដំណាក់កាលដំបូងបង្អស់សម្រាប់ជំនួយក្នុងការអភិវឌ្ឍន៍បណ្តាវិធានច្បាប់នានាដោយអនុលោមតាមអនុសញ្ញាយូប៉ូវ UPOV ឆ្នាំ១៩៩១ ដើម្បីក្លាយជាសមាជិករបស់អង្គការ យូប៉ូវ UPOV ។ សេចក្តីណែនាំអំពីការអភិវឌ្ឍន៍នៃបណ្តាវិធានច្បាប់ដោយអនុលោមទៅតាមអនុសញ្ញាយូប៉ូវ UPOV អាចរកបាននៅក្នុងឯកសារដែលមានចំណងជើងថា “ សេចក្តីណែនាំសម្រាប់ការរៀបចំច្បាប់ ដោយអនុលោមតាមអនុសញ្ញា UPOV ឆ្នាំ១៩៩១ (Guidance for the Preparation of Law Based on the 1991 Act of the UPOV Convention) ” ដែលឯកសារនេះ មានជាភាសាអង់គ្លេស អារ៉ាប់ ចិន បារាំង អាល្លឺម៉ង់ រុស្ស៊ី និងភាសា អេស្ប៉ាញ។

❖ **ការផ្តល់អនុសាសន៍របស់ក្រុមប្រឹក្សានៃយូប៉ូវ UPOV**[47]

ឯកសារនៃការវិភាគ និងច្បាប់ទាំងឡាយត្រូវបានដាក់បង្ហោះនៅក្នុងគេហទំព័ររបស់ UPOV មុនពេលសម័យប្រជុំរបស់ក្រុមប្រឹក្សា ដែលច្បាប់នោះនឹងត្រូវត្រួតពិនិត្យដើម្បីជួយបណ្តាសមាជិក និងអ្នកសង្កេតការណ៍ចំពោះការពិចារណាទៅលើច្បាប់នោះ។ ស្របពេលជាមួយគ្នានោះដែរ ដំណាក់កាលនេះ ក៏ជាឱកាសមួយសម្រាប់ការទទួលបាននូវមតិយោបល់នានាពីបណ្តាសមាជិក ក៏ដូចជាអ្នកសង្កេតការនៅមុនការត្រួតពិនិត្យដោយក្រុមប្រឹក្សា។ មតិយោបល់ដែលបានទទួលនឹងត្រូវផ្តល់ទៅឱ្យរដ្ឋ ឬ អង្គការអន្តររដ្ឋាភិបាលដែលស្នើសុំការត្រួតពិនិត្យច្បាប់ និងទៅសមាជិកទាំងអស់របស់សហភាព។ ម្យ៉ាងវិញទៀត មតិយោបល់ដែលបានផ្តល់ ដោយបណ្តាសមាជិក និងអ្នកសង្កេតការនោះនឹងត្រូវបានបង្ហោះចូល ទៅក្នុងគេហទំព័ររបស់យូប៉ូវ UPOV ។

❖ **ការអនុវត្តអនុសញ្ញា**

ក្រោយពេលដែលដាក់តម្កល់លិខិតូបករណ៍នៃការចូលជាសមាជិកនៃអនុសញ្ញាយូប៉ូវ UPOV ហើយរដ្ឋឬអង្គការអន្តររដ្ឋាភិបាលត្រូវប្រកាន់ជំហរមួយនៅក្រោមច្បាប់ជាតិរបស់ខ្លួន ដោយអនុលោមតាមអនុសញ្ញាយូប៉ូវ

[47] មាត្រា ៣៤ នៃអនុសញ្ញាអន្តរជាតិ ស្តីពី កិច្ចការពារពូជថ្មីនៃដំណាំ ឆ្នាំ១៩៩១

UPOV។ ជាពិសេសដើម្បីទទួលបាននូវការការពារលើការបង្កាត់ពូជថ្មីនៃដំណាំនោះ អ្នកបង្កាត់ពូជដំណាំត្រូវដាក់ពាក្យស្នើសុំការការពារដើម្បីទទួលបានសិទ្ធិអ្នកបង្កាត់ពូជដំណាំដោយអនុលោមតាមយូប៉ូវ UPOV ។ ម្យ៉ាងវិញទៀតរដ្ឋ ឬ អង្គការអន្តររដ្ឋាភិបាល ត្រូវធានាឱ្យមានវិធានការតាមផ្លូវច្បាប់ដើម្បីធានាការអនុវត្តការការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំប្រកបដោយប្រសិទ្ធិភាព។

### ❖ ការដាក់តម្កល់លិខិតូបករណ៍នៃការចូលជាសមាជិក

ការដាក់តម្កល់លិខិតូបករណ៍នៃការចូលជាសមាជិកតម្រូវឱ្យមានដូចខាងក្រោម៖

➢ <u>លិខិតូបករណ៍នៃការចូលជាសមាជិក</u>[48]

លិខិតូបករណ៍នៃការចូលជាសមាជិកត្រូវធ្វើឡើងដោយមានការចុះហត្ថលេខារបស់ប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល ឬរដ្ឋមន្ត្រីការបរទេស ឬចំពោះអង្គការអន្តររដ្ឋាភិបាល គឺត្រូវធ្វើឡើងដោយអាជ្ញាធរ ដែលមានសមត្ថភាពសម្រាប់ទំនាក់ទំនងក្រៅប្រទេសរបស់អង្គការ ហើយលិខិតនេះត្រូវផ្ញើមកអគ្គលេខាធិការរបស់យូប៉ូវ UPOV។

➢ <u>ច្បាប់ដែលគ្រប់គ្រងលើសិទ្ធិរបស់អ្នកបង្កាត់ពូជដំណាំ</u>[49]

ច្បាប់ដែលបានអនុម័តរួចហើយ គឺតម្រូវឱ្យមាននៅខណៈពេលនៃការដាក់តម្កល់លិខិតូបករណ៍ក្រោមទិដ្ឋភាព ២យ៉ាងគឺ៖

- ច្បាប់ដែលអនុម័តហើយដែលទទួលស្គាល់ដោយសេចក្ដីសម្រេចវិជ្ជមានរបស់ក្រុមប្រឹក្សា ក្នុងការចូលជាសមាជិកនៃអនុសញ្ញាយូប៉ូវ UPOV
- សេចក្ដីព្រាង ដែលទទួលស្គាល់ដោយសេចក្ដីសម្រេចវិជ្ជមានរបស់ក្រុមប្រឹក្សាក្នុងការចូលជាសមាជិកនៃអនុសញ្ញាយូប៉ូវ UPOV។

➢ <u>សេចក្ដីប្រកាសពីចំនួនឯកតានៃការចូលរួមវិភាគទាន</u>[50]

នៅក្នុងការចូលរួមនៅក្នុងសហភាពសហព័ន្ធមួយនេះ អនុសញ្ញាយូប៉ូវ UPOV តម្រូវឱ្យរដ្ឋ និងអង្គការអន្តរដ្ឋាភិបាលធ្វើការបញ្ជាក់ពីចំនួនឯកតានៃការចូលរួមវិភាគទាននៅក្នុងសេចក្ដីប្រកាសមួយ ដែលផ្ញើរទៅ

[48] មាត្រា ៣៤ នៃអនុសញ្ញាអន្តរជាតិ ស្ដីពី កិច្ចការពារពូជថ្មីនៃដំណាំ ឆ្នាំ១៩៩១

[49] មាត្រា ៣៦ នៃអនុសញ្ញាអន្តរជាតិ ស្ដីពី កិច្ចការពារពូជថ្មីនៃដំណាំ ឆ្នាំ១៩៩១

[50] មាត្រា ២៩ នៃអនុសញ្ញាអន្តរជាតិ ស្ដីពី កិច្ចការពារពូជថ្មីនៃដំណាំ ឆ្នាំ១៩៩១

អគ្គលេខាធិការរបស់យូប៉ូវ UPOV ។ អនុសញ្ញាយូប៉ូវ UPOV ក៏បានកំណត់ពីចំនួនឯកតានៃវិភាគទាននោះដែរ ដែលឯកតានោះអាចជាចំនួនគត់ ឬ ជាប្រភាគ ដែលចំនួនប្រភាគនោះមិនត្រូវតូចជាង ១/៥ ឡើយ។ តម្លៃមួយឯកតា គឺ ៥៣,៦៤១ ហ្វ្រង់ស្វីស។

➢ <u>សេចក្តីប្រកាសពីប្រភេទពូជដំណាំដែលត្រូវការពារ</u>

លិខិតុបករណ៍នៃការចូលជាសមាជិកត្រូវភ្ជាប់មកជាមួយនឹងសេចក្តីប្រកាសពីប្រភេទពូជដំណាំ ដែលត្រូវការពារផងដែរ។ សេចក្តីប្រកាសទាំងពីរអំពីចំនួនឯកតានៃការចូលរួមវិភាគទាន និងប្រភេទពូជដំណាំដែលត្រូវការពារគឺអាចធ្វើឡើងដោយលិខិតរបស់រដ្ឋមន្ត្រីការបរទេស ឬ លិខិតពីអ្នកតំណាងអចិន្ត្រៃយ៍ ឬ កំណត់លិខិត (Note) ពីបេសកម្មអចិន្ត្រៃយ៍នៅក្នុងទីក្រុងហ្សឺណែវ (Geneva)។

❖ **ការប្រកាសជូនដំណឹងដល់ក្រុមប្រឹក្សាអំពីអ្នកតំណាង និងការផ្លាស់ប្តូរវេនគ្នា**[51]

សមាជិករបស់យូប៉ូវ UPOV គឺតម្រូវឱ្យសមាជិករបស់ខ្លួនធ្វើការជូនដំណឹងដល់ការិយាល័យរបស់សហព័ន្ធពីឈ្មោះ ឋានៈតួនាទី ព័ត៌មានលម្អិតនានាសម្រាប់ការទំនាក់ទំនងរបស់អ្នកតំណាង និងការផ្លាស់ប្តូរវេនគ្នាប្រចាំក្រុមប្រឹក្សាយូប៉ូវ UPOV ។

❖ **ការចូលជាធរមាននៃអនុសញ្ញាយូប៉ូវ UPOV**

រដ្ឋ ឬអង្គការអន្តររដ្ឋាភិបាលនឹងក្លាយជាសមាជិកនៃអនុសញ្ញាយូប៉ូវ UPOV នៅរយៈពេល ១ខែក្រោយពីការដាក់តម្កល់លិខិតូករណ៍នៃការចូលជាសមាជិកប្រកបដោយជោគជ័យ ហើយពេលនោះ រដ្ឋ និងអង្គការអន្តររដ្ឋាភិបាលនោះនឹងត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងឋានៈជាសមាជិកយ៉ាងពេញសិទ្ធិមួយរបស់យូប៉ូវ UPOV ។

❖ **របបហិរញ្ញវត្ថុ**

នៅពេលក្លាយជាសមាជិករបស់អង្គការយូប៉ូវ UPOV ហើយរដ្ឋ និងអង្គការអន្តររដ្ឋាភិបាលត្រូវមានកាតព្វកិច្ចផ្តល់មូលនិធិទៅមូលនិធិរបស់យូប៉ូវ UPOV ដែលគេហៅថា **មូលនិធិមូលធនការងារ ( Working Capital Fund )** និងវិភាគទានប្រចាំឆ្នាំលើកទី១ របស់ខ្លួននៅក្នុងខែមករា បន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាសមាជិកភាពរបស់យូប៉ូវ UPOV។

### ៣.២.២ ទេតិកាការពារការបង្កាត់ពូជដំណាំអាស៊ីអាគ្នេយ៍ (EAPVP)

[51] មាត្រា ២៩ នៃអនុសញ្ញាអន្តរជាតិ ស្តីពី កិច្ចការពារពូជថ្មីនៃដំណាំ ឆ្នាំ១៩៩១

វេទិកាការពារការបង្កាត់ពូជដំណាំ (EAPVP Forum) គឺជាអង្គការថ្នាក់តំបន់មួយនៅក្នុងតំបន់អាស៊ីប៉ូព៌ា ដែលដើរតួនាទីជាស្ថាប័នកណ្តាលទទួលខុសត្រូវ លើការជម្រុញការអនុវត្តការការពារការបង្កាត់ពូជដំណាំនៅក្នុងបណ្តាប្រទេសជាសមាជិក។ អង្គការថ្នាក់តំបន់មួយនេះបានបង្កើតប្រព័ន្ធ PVP ប្រកបដោយប្រសិទ្ធភាពស្របនឹងអនុសញ្ញាយូប៉ូវ UPOV ក្នុងចំណោមសមាជិកវេទិកាឆ្ពោះទៅរកការសម្រេចសមាជិកភាពរបស់ យូប៉ូវ UPOV ទាំងអស់របស់វេទិកាជាមូលដ្ឋានសម្រាប់ការធ្វើសុខដុមនីយកម្មនិងកិច្ចសហប្រតិបត្តិការ PVP បន្ថែមទៀតនៅក្នុងតំបន់ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍កសិកម្មប្រកបដោយចីរភាព និងការទទួលបានសន្តិសុខស្បៀងជាពិសេសការការពារការបង្កាត់ពូជដំណាំផងដែរ។

គោលការណ៍ណែនាំសម្រាប់ប្រតិបត្តិការវេទិកាការពាររុក្ខជាតិនៅអាស៊ីប៉ូព៌ា ដែលត្រូវបានអនុម័តដោយកិច្ចប្រជុំលើកទី០១ នៅថ្ងៃទី ២៣ ខែកក្កដាឆ្នាំ ២០០៨ ផ្តល់ជូននូវសារតាគោលបំណងសកម្មភាពនិងក្របខ័ណ្ឌនៃពូជរុក្ខជាតិអាស៊ីប៉ូព៌ា។ ដើម្បីលើកកម្ពស់ការការពារពូជរុក្ខជាតិស្របតាមអនុសញ្ញាយូប៉ូវ UPOV ក្នុងវេទិកាផ្អែកលើផែនការយុទ្ធសាស្ត្រ ១០ ឆ្នាំនិងកំណត់ទិសដៅ និងសកម្មភាពនានា ក៏ដូចជានីតិវិធីរដ្ឋបាលដើម្បីដំណើរការវេទិកា។ សកម្មភាពសហប្រតិបត្តិការរបស់វេទិកាដែលស្នើឡើងដោយសមាជិកជារៀងរាល់ឆ្នាំដែលត្រូវការការគាំទ្រ ផ្នែកហិរញ្ញវត្ថុជាពិសេសគឺត្រូវស្របនឹងទិសដៅរួមនៃផែនការយុទ្ធសាស្ត្រ ១០ ឆ្នាំដោយមានគោលបំណងដើម្បីពង្រឹងសកម្មភាពកិច្ចសហប្រតិបត្តិការរបស់វេទិកាឆ្ពោះទៅរកការចុះសម្រុងគ្នានៃប្រព័ន្ធ PVP នៅតំបន់អាស៊ីប៉ូព៌ា។

បច្ចុប្បន្នវេទិកាការពារការបង្កាត់ពូជដំណាំ មានសមាជិកចំនួន ១៣ ប្រទេស ដែលរួមមានបណ្តាប្រទេសអាស៊ានទាំង ១០ ដែលរួមមាន ប្រទេសប្រ៊ុយណេ កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ថៃ ហ្វីលីពីន សឹង្ហបុរី និងប្រទេសវៀតណាម រួមទាំងបណ្តាប្រទេសដែលមានសេដ្ឋកិច្ចខ្លាំងក្លា ៣ទៀតនៅអាស៊ី គឺប្រទេសចិន ជប៉ុន និងប្រទេសកូរ៉េខាងត្បូង។[52] ជារៀងរាល់ឆ្នាំ វេទិកានេះតែងតែប្រារព្ធធ្វើឡើងនូវកិច្ចប្រជុំប្រចាំឆ្នាំរបស់ខ្លួនដើម្បីពិភាក្សាលើកិច្ចសហប្រតិបត្តិការរវាងបណ្តាសមាជិកទាំងអស់ សកម្មភាពនៃការធ្វើឱ្យទៅជាប្រព័ន្ធតែមួយនៃការការពារពូជដំណាំ និងការអភិវឌ្ឍន៍ថ្មីៗលើប្រព័ន្ធនៃការការពារពូជថ្មីនៃដំណាំនៅបណ្តាប្រទេសជាសមាជិក និងប្រទេសដទៃទៀត។ វេទិកានេះ ធ្លាប់បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំរបស់ខ្លួនចំនួន ១៣លើក រួចមកហើយ ស្របពេលនោះដែលប្រទេសកម្ពុជាមានកិត្តិយសធ្វើជាម្ចាស់ផ្ទះក្នុងកិច្ចប្រជុំលើកទី៥ ដែលប្រារព្ធធ្វើឡើងនៅរាជធានី

[52] http://eapvp.org/member/ (កាលបរិច្ឆេទចូលមើល ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១)

ភ្នំពេញ នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ចំណែកឯកិច្ចប្រជុំលើកទី១៣ ប្រារព្ធធ្វើឡើងនៅប្រទេសវៀតណាម នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ តាមរយៈប្រព័ន្ធអ៊ីនធើណេត ដោយសារវិបត្តិនៃការរីករាលដាលនៃជម្ងឺកូវីដ១៩។[53]

## ៣.៣ ៖ អង្គការនានាដែលពាក់ព័ន្ធនឹងការការពារពូជដំណាំថ្មី

### ៣.៣.១ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO)

#### ៣.៣.១.១ ប្រវត្តិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក

អង្គការកម្មសិទ្ធិបញ្ញាពិភពលោក WIPO គឺជាភ្នាក់ងារជំនាញមួយនៃបណ្តាញប្រព័ន្ធអង្គការរបស់ អង្គការសហប្រជាជាតិ និងត្រូវបានបង្កើតឡើងដោយអនុសញ្ញាទីក្រុង Stockholm ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៦៧ ហើយចូលជាធរមាននៅក្នុងឆ្នាំ១៩៧០។ អង្គការកម្មសិទ្ធិបញ្ញាមានដើមកំណើតមកពីអនុសញ្ញា២គឺ អនុសញ្ញាទីក្រុងប៉ារីសឆ្នាំ១៨៨៣ និងអនុសញ្ញាទីក្រុងប៊ែន១៨៨៦។ យោងតាមការអនុម័តអនុសញ្ញាទាំងពីរ គេបានបង្កើតបាននូវលេខាធិការដ្ឋានអន្តរជាតិចំនួនពីរ ដើម្បីដំណើរការកិច្ចការរដ្ឋបាលនៃអនុសញ្ញានោះ ហើយត្រូវដាក់ក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលសហព័ន្ធរបស់ប្រទេសស្វីស។ លេខាធិការដ្ឋានទាំងពីរត្រូវ បានគេបែងចែកតួនាទីផ្សេងពីគ្នា ដែលមួយទទួលបន្ទុកផ្នែកឧស្សាហកម្ម និងលេខាធិការដ្ឋានមួយទៀត សម្រាប់ទទួលបន្ទុកផ្នែកកម្មសិទ្ធិអ្នកនិពន្ធ។ ក្រោយមកលេខាធិការដ្ឋានទាំងពីរត្រូវបានរួមបញ្ចូលគ្នាក្លាយទៅ ជាការិយាល័យរួមអន្តរជាតិសម្រាប់ការពារកម្មសិទ្ធិបញ្ញា **BIRPI** នៅក្នុងឆ្នាំ១៨៩៣ បន្ទាប់មកទៀតក៏ក្លាយជា អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។[54] នៅឆ្នាំ១៩៦០ BIRPI ត្រូវបានផ្លាស់ពីទីក្រុងប៊ែន មកកាន់ទីក្រុងហ្សឺណែវ ក្នុងប្រទេសស្វីស។

នៅក្នុងឆ្នាំ១៩៦៧ សន្និសិទមួយត្រូវបានរៀបចំធ្វើឡើងនៅទីក្រុង Stockholm ដែលជាពេលដែល អង្គការកម្មសិទ្ធិបញ្ញាពិភពលោកត្រូវបានបង្កើតឡើង ហើយរាល់កិច្ចការគ្រប់គ្រងផ្នែករដ្ឋបាល និងបទបញ្ញត្តិនៃអនុសញ្ញាពហុភាគីទាំងឡាយដែលនៅជាធរមាននិងធ្លាប់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់BIRPI ត្រូវបានផ្លាស់ប្តូរ និងធ្វើការកែប្រែ។ អង្គការអន្តរជាតិភាគច្រើន សព្វថ្ងៃនេះគឺជាទីភ្នាក់ងារជំនាញរបស់អង្គការសហប្រជាជាតិ គឺពុំមានវត្តមានទេ ក្រោយពីសង្គ្រាមលោកលើកទី១ត្រូវបានបញ្ចប់។ ប៉ុន្តែក៏មានអង្គការអន្តរជាតិមួយចំនួននៅ

[53] http://eapvp.org/report-data/vietnam/the-13th-eapvp-forum-meeting/ (កាលបរិច្ឆេទចូលមើល ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១)

[54] https://en.wikipedia.org/wiki/United_International_Bureaux_for_the_Protection_of_Intellectual_Property (កាលបរិច្ឆេទចូលមើល ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១)

រស់រានមានជីវិតផងដែរ។ ឧទាហរណ៍៖ **BIRPI** គឺជាអង្គការពហុជាតិមួយដែលទទួលបន្ទុកផ្នែកកម្មសិទ្ធិបញ្ញា តាំងពីមុនសង្គ្រាមលោក។ WIPO គឺជាអ្នកស្នងមរតកពីការិយាល័យរួមអន្តរជាតិសម្រាប់ការពារកម្មសិទ្ធិបញ្ញា BIRPI។ អង្គការកម្មសិទ្ធិបញ្ញាពិភពលោកបានក្លាយជាភ្នាក់ងារជំនាញរបស់អង្គការសហប្រជាជាតិតាមរយៈកិច្ចព្រមព្រៀងចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៤។[55]

នៅក្នុងឆ្នាំ២០០៤ WIPO មានរដ្ឋជាសមាជិកចំនួន១៨១ប្រទេស នៅក្នុងឆ្នាំ២០១៤ WIPO មានរដ្ឋសមាជិកចំនួន១៨៧ប្រទេស ហើយគិតត្រឹមថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ មានសមាជិកចំនួន១៨៩ប្រទេស និងបច្ចុប្បន្នមានចំនួនសមាជិកសរុប១៩៣ប្រទេស ដែលក្នុងនោះ១៩០ប្រទេសជាប្រទេសសមាជិកនៃអង្គការសហប្រជាជាតិ។[56] យ៉ាងណាមិញព្រះរាជាណាចក្រកម្ពុជាក៏បានក្លាយជាប្រទេសសមាជិកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោកផងដែលកាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ១៩៩៥។

### ៣.៣.១.២ គោលបំណងរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក

បេសកម្មរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក WIPO គឺជួយលើកស្ទួយតាមរយៈការបង្កើតកិច្ច សហប្រតិបត្តិការជាអន្តរជាតិ ផ្សព្វផ្សាយ ប្រើប្រាស់ និងជាពិសេសការការពារនូវស្នាដៃដែលកើតចេញ ពីសកម្មភាពបញ្ញារបស់មនុស្ស ដើម្បីភាពរីកចម្រើន ជឿនលឿនផ្នែកសេដ្ឋកិច្ច វប្បធម៌ និងសង្គមរបស់មនុស្ស ជាតិ។

ឧទាហរណ៍មួយដ៏លេចធ្លោរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក គឺសកម្មភាពនៃការចុះបញ្ជីស្នាដៃដែលជាកម្មសិទ្ធិបញ្ញា ហើយគេសង្កេតឃើញថាវាមានការកើនឡើងជាលំដាប់នៃការប្រើប្រាស់សន្ធិសញ្ញា អន្តរជាតិក្នុងវិស័យកម្មសិទ្ធិបញ្ញា ដែលជាមធ្យោបាយដ៏ងាយស្រួលក្នុងការអនុវត្ត ពោលគឺអនុវត្តនូវនីតិវិធីតែ មួយគត់ក្នុងការដាក់ពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម ម៉ាក និងគំនូរឧស្សាហកម្មជាអាទិ៍។ ការចុះបញ្ជីនេះមានអានុភាពគ្រប់ប្រទេសដែលជាសមាជិកនៃសន្ធិសញ្ញាអន្តរជាតិទាំងអស់នោះ ដូចជាសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម Paten Cooperation Treaty (PCT) កិច្ចព្រមព្រៀង និងពិធិសារ ទីក្រុងម៉ាទ្រីឌ (Madrid Agreement and Madrid Protocol) និងកិច្ចព្រមព្រៀងទីក្រុងឡាអេ (Hague Agreement) ។ តាមរយៈសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម នៅក្នុងឆ្នាំ២០០០ មានការចុះ បញ្ជីចំនួន

[55] សៀវភៅមេរៀនសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ និងរដ្ឋបាលសាធារណៈ មុខវិជ្ជា នីតិកម្មសិទ្ធិបញ្ញា ដោយសាស្ត្រាចារ្យ ឃឹម គីរី

[56] https://www.wipo.int/members/en/ (កាលបរិច្ឆេទចូលមើលគេហទំព័រ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១)

៩០៩២៨ប្រកាសនីយបត្រតក្កកម្ម នៅឆ្នាំ២០០៨មានចំនួន១លាន នៅឆ្នាំ២០១១ មានចំនួន២លាន និងគិតត្រឹមថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧ មានពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មចំនួន៣លាន។[57]

អង្គការកម្មសិទ្ធិបញ្ញាពិភពលោកធ្វើសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍជាអន្តរជាតិ និងជាដៃគូយ៉ាងជិតស្និតជាមួយនឹងរដ្ឋាភិបាល អង្គការអន្តររដ្ឋាភិបាលដែលរាប់បញ្ចូលទាំងកិច្ចព្រមព្រៀងរវាង WIPO និង WTO ដោយជួយប្រទេសកំពុងអភិវឌ្ឍដែលជាសមាជិកទាំងអស់ ក្នុងការអនុវត្តនូវកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាព ពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា Agreement on Trade-Related Aspect of Intellectual Property (TRIPS) ។

អង្គការកម្មសិទ្ធិបញ្ញាពិភពលោកបានជួយធ្វើការដោះស្រាយវិវាទរវាងបុគ្គលឯកជន និងក្រុមហ៊ុន តាមរយៈនៃការប្រើប្រាស់នូវយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដូចជា មជ្ឈត្តកម្ម និងសន្ធានកម្មរបស់ខ្លួន ហើយក៏បានជួយដោះស្រាយបញ្ហាដែលទាក់ទងនឹងការប្រើប្រាស់នូវ Domain Name នៅក្នុងប្រព័ន្ធអ៊ីនធើណេតផងដែរ។ មិនតែប៉ុណ្ណោះ អង្គការកម្មសិទ្ធិបញ្ញាពិភពលោកក៏បានចូលរួមចែកផ្សាយនូវព័ត៌មានសំខាន់ៗដែលមានប្រយោជន៍ខាងកម្មសិទ្ធិបញ្ញាទៅដល់រដ្ឋទូទាំងពិភពលោក និងបានបង្កើតនូវគម្រោងមួយដែលត្រូវបានគេដាក់ឲ្យប្រតិបត្តិចាប់តាំងពីឆ្នាំ១៩៩៩ ដែលមានឈ្មោះថា WIPO NET ដើម្បីបង្កើតឲ្យមានការជឿជាក់ទៅលើការភ្ជាប់នូវបណ្តាញព័ត៌មាន រវាងបណ្តាការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសជាសមាជិកទាំងអស់ក្នុងការផ្លាស់ប្តូរព័ត៌មាន និងផ្តល់នូវភាពងាយស្រួលក្នុងការចូលរួម។

អង្គការកម្មសិទ្ធិបញ្ញាពិភពលោកមិនត្រឹមតែដើរតួនាទីការពារកម្មសិទ្ធិបញ្ញាប៉ុណ្ណោះទេ តែបានចូលរួមយ៉ាងសកម្មជាមួយរដ្ឋជាសមាជិកនៅក្នុងវិស័យជាច្រើនដូចជា ច្បាប់ ឧស្សាហកម្ម វប្បធម៌ រួមទាំងផ្នែកផ្សេងទៀតដែលរួមបញ្ចូលទាំងការធ្វើសហប្រតិបត្តិការជាមួយសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល សហគ្រាសធុនតូច និងប្រជាកសិករដែលពាក់ព័ន្ធនឹងបញ្ហាសុខភាពសាធារណៈការបង្កើតថ្មីក៏ដូចជាដើម្បីផលប្រយោជន៍ដល់សាធារណៈជនទូទៅ និងតួនាទីសំខាន់ៗដូចជា៖

- ធ្វើឲ្យមានការរីកចម្រើនក្នុងការរៀបចំតាក់តែងច្បាប់ និងនីតិវិធីផ្សេងៗ ដែលទាក់ទងនឹងច្បាប់កម្មសិទ្ធិបញ្ញាជាតិនៃរដ្ឋជាសមាជិក
- ផ្តល់នូវសេវាកម្មសម្រាប់ការអនុវត្តជាអន្តរជាតិនូវសិទ្ធិកម្មសិទ្ធិឧស្សាហកម្ម
- ផ្លាស់ប្តូរពត៌មានក្នុងវិស័យកម្មសិទ្ធិបញ្ញា

[57] សៀវភៅមេរៀនសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ និងរដ្ឋបាលសាធារណៈ មុខវិជ្ជា នីតិកម្មសិទ្ធិបញ្ញា ដោយសាស្ត្រាចារ្យ ឃឹម គីរី

- ផ្តល់ជំនួយបច្ចេកទេសខាងផ្នែកច្បាប់ និងសម្រាប់ការអភិវឌ្ឍន៍
- សម្របសម្រួល និងជួយដោះស្រាយនូវវិវាទកម្មសិទ្ធិបញ្ញា
- ជាភ្នាក់ងារត្រួតពិនិត្យខាងផ្នែកពត៌មានវិទ្យា ព្រមទាំងជាឧបករណ៍សម្រាប់ការរក្សាទុក ការចូលរួម និងប្រើប្រាស់នូវពត៌មានដែលមានតម្លៃខាងកម្មសិទ្ធិបញ្ញា។[58]

### ៣.៣.១.៣ រចនាសម្ព័ន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក

ធម្មនុញ្ញរបស់ WIPO គឺជាឯកសារជាមូលដ្ឋានក្នុងដំណើរការ និងការប្រព្រឹត្តទៅរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដែលត្រូវបានបង្កើតឡើងដោយអនុសញ្ញា Stockholm ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៦៧។

រចនាសម្ព័ន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកមានចំនួន០៤សំខាន់ៗគឺៈ

- មហាសន្និបាត
- សន្និសិទ
- គណៈកម្មាធិការសម្របសម្រួល
- ការិយាល័យអន្តរជាតិ ឬលេខាធិការដ្ឋាន។

❖ **មហាសន្និបាត** (General Assembly)

មហាសន្និបាត គឺជាអង្គការចាត់តាំងដ៏សំខាន់ជាងគេ សម្រាប់តែងតាំងអគ្គនាយកដែលត្រូវបានជ្រើសតាំងដោយគណៈកម្មាធិការសម្របសម្រួល។ មហាសន្និបាតទទួលខុសត្រូវក្នុងការត្រួតពិនិត្យមើល និងសម្រេចទៅលើរបាយការណ៍និងសកម្មភាពរបស់គណៈកម្មាធិការសម្របសម្រួលក៏ដូចជាត្រួតពិនិត្យរបាយការណ៍របស់អគ្គនាយកដែលទាក់ទងទៅនឹងការងាររបស់ WIPO ហើយមហាសន្និបាតក៏មានភារៈកិច្ចក្នុងការអនុម័ត បទបញ្ញាស្តីពីថវិការសម្រាប់ WIPO និងថវិការរបស់សហគមន៍សម្រាប់រយៈពេលពីរឆ្នាំ ជាពិសេសទៅទៀតគឺការអនុម័តវិធានការក្នុងការគ្រប់គ្រងដែលទាក់ទងនឹងកិច្ចព្រមព្រៀងអន្តរជាតិ ដែលបានដាក់ស្នើដោយអគ្គនាយកក្នុងគោលបំណងលើកតម្កើង និងការពារកម្មសិទ្ធិបញ្ញា ហើយមហាសន្និបាតក៏ជាអ្នកសម្រេចពីភាសាការងាររបស់លេខាធិការដ្ឋានព្រមជាមួយគ្នានេះផងដែរក៏សម្រេចតើប្រទេសណាមួយអាចចូលជាសមាជិក ឬមិនអាចចូលជាសមាជិករបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ សមាជិករបស់មហាសន្និបាត គឺជារដ្ឋដែលជាសមាជិកនៃអនុសញ្ញានានាដែលកើតឡើងពីមហាសន្និបាតផ្ទាល់។ រដ្ឋាភិបាលនៃរដ្ឋសមាជិកនីមួយៗត្រូវជ្រើស

[58] សៀវភៅមេរៀនសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ និងរដ្ឋបាលសាធារណៈ មុខវិជ្ជា នីតិកម្មសិទ្ធិបញ្ញា ដោយសាស្ត្រាចារ្យ ឃឹម គីរី

រើសដោយគណៈប្រតិភូមួយរូបដែលជាជំនួយដោយគណៈប្រតិភូជាច្រើនរូប អ្នកប្រឹក្សាច្រើនរូប និងអ្នកជំនាញការជាច្រើន រូប។ រដ្ឋនីមួយៗដែលជាសមាជិកមួយ ឬច្រើនរបស់សហគមន៍ណាមួយត្រូវមានសិទ្ធិបោះឆ្នោតមួយសម្លេងនៅក្នុងមហាសន្និបាតដូចគ្នា។ ចំនួនកូរ៉ុមរបស់មហាសន្និបាត ជាចំនួនពាក់កណ្តាលនៃមហាសន្និបាត។ ករណីបើការប្រជុំរបស់រដ្ឋជាសមាជិកដែលចូលរួមមានចំនួនតិចជាងពាក់កណ្តាល មានន័យថាវាខុសពី បទបញ្ញត្តិ ប៉ុន្តែប្រសិនបើស្មើ ឬច្រើនជាង១/៣ នៃរដ្ឋជាសមាជិកទាំងអស់ក្នុងមហាសន្និបាត មហាសន្និបាតអាច ធ្វើសេចក្តីសម្រេចបាន ប៉ុន្តែធ្វើបានតែសេចក្តីសម្រេចណាដែលពាក់ព័ន្ធនឹងនីតិវិធីផ្ទាល់តែប៉ុណ្ណោះ ហើយមានអានុភាពត្រឹមលក្ខខណ្ឌដែលត្រូវបំពេញ។ ដោយឡែក នៅពេលដែលអវត្តមានការប្រជុំរបស់រដ្ឋណាមួយការិយាល័យអន្តរជាតិនឹងធ្វើការទំនាក់ទំនងទៅរដ្ឋនោះដើម្បីអោយពួកគេសរសេរបញ្ជាក់នូវសន្លឹកឆ្នោតនោះ ឬអនុប្បវាទក្នុងរយៈពេល៣ខែគិតចាប់ពីថ្ងៃដែលបានទំនាក់ទំនង។ បើផុតរយៈពេលកំណត់ រដ្ឋដែលបានបញ្ជាក់សម្លេងឆ្នោត និងធ្វើការអនុប្បវាទសម្រេចថាចំនួនរដ្ឋខ្វះការសម្រេចចំពោះកូរ៉ុមនៃការប្រជុំ។ ដូច្នេះ ការសម្រេចនេះនឹងមានអានុភាពដូចដែលផ្តល់ឲ្យតាមលក្ខខណ្ឌភាគច្រើន។

មហាសន្និបាតធ្វើការប្រជុំរៀងរាល់២ឆ្នាំម្តង ដោយការកោះអញ្ជើញរបស់អគ្គនាយករបស់ការិយាល័យអន្តរជាតិដែលការប្រជុំនេះហៅថាសម័យប្រជុំសាមញ្ញ។ យ៉ាងណាមិញមហាសន្និបាតក៏អាចធ្វើការប្រជុំជាវិសាមញ្ញបានដែរ ដោយការកោះប្រជុំពីសំណាក់អគ្គនាយក ឬតាមសំណើរពីសមាជិក១/៤ នៃសមាជិកសន្និបាត ឬដោយសំណើរជាផ្លូវការរបស់គណៈកម្មារសម្របសម្រួល។ រៀងរាល់ការប្រជុំនីមួយៗរបស់មហាសន្និបាត រដ្ឋដែលមិនមែនជាសមាជិកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោកក៏អាចចូលរួមក្នុងការប្រជុំនោះបានដែរ ក្នុងនាមជាអ្នកសង្កេតការ។

❖ **សន្និសិទ** (Conference)

សន្និសិទរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក គឺបង្កើតឡើងដោយរដ្ឋជាសមាជិកទាំងអស់នៃ អង្គការនេះ។ ការធ្វើសន្និសិទនេះភាគច្រើនគឺធ្វើឡើងនៅក្នុងពេលតែមួយ និងក្នុងបន្ទប់ប្រជុំតែមួយជាមួយនឹង មហាសន្និបាត ហើយលក្ខណៈខុសគ្នានៃដំណើរការប្រជុំនោះគឺអធិបតេយ្យប្រធាននៃអង្គប្រជុំ។ នៅពេលមាន សន្និសិទត្រូវមានសមាសភាពរដ្ឋជាសមាជិកនៃអនុសញ្ញាWIPO ទោះបីរដ្ឋនោះមិនមែនជាសមាជិកអង្គការ ក៏ដោយ។

សន្និសិទរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ធ្វើការទៅលើការពិភាក្សាអំពីបញ្ហាដូចខាងក្រោមៈ

- ពិភាក្សារាល់បញ្ហាទូទៅពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងបរិបទកម្មសិទ្ធិបញ្ញា និងការអនុម័តរាល់ បទបញ្ញានានាទាក់ទងនឹងបញ្ហាកម្មសិទ្ធិបញ្ញា ពិនិត្យនូវរាល់សមត្ថកិច្ច និងស្វ័យភាពរបស់អង្គការ

- អនុម័តថវិកា២ឆ្នាំរបស់សន្និសិទ
- កំណត់នូវការចំណាយរបស់សន្និសិទ និងបង្កើតវិធីជំនួយការបច្ចេកទេសច្បាប់
- ធ្វើវិសោធនកម្មនូវអនុសញ្ញានេះដូចដែលមានចែងក្នុងមាត្រា១៧នៃអនុសញ្ញានេះ
- ជាអ្នកកំណត់ថា តើរដ្ឋណាមួយជាសមាជិកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ហើយអង្គការអន្តរជាតិណាមួយដែលត្រូវអនុញ្ញាតអោយចូលរួមប្រជុំក្នុងនាមជាអ្នកសង្កេតការ
- អនុវត្តនូវតួនាទីដែលផ្តល់ឲ្យដោយអនុសញ្ញាបង្កើតអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

លក្ខណៈខុសគ្នារវាងមហាសន្និបាត និងសន្និសិទ គឺខុសគ្នានៅត្រង់អវត្តមានការចូលរួមរបស់រដ្ឋជាសមាជិក មានន័យថាការខកខានមិនបានចូលរួមសន្និសិទ ត្រូវចាត់ទុកថាមិនបានបោះឆ្នោតនោះទេ។

❖ គណៈកម្មាការសម្របសម្រួល (Coordination Committee)

សមាសភាពគណៈកម្មាការសម្របសម្រួលរួមមាន រដ្ឋជាសមាជិកទាំងអស់នៃអនុសញ្ញាបង្កើតអង្គការកម្មសិទ្ធិបញ្ញា ឬជាសមាជិកទាំងអស់នៃគណៈកម្មាធិការប្រតិបត្តិនៃសន្ធិសញ្ញាទីក្រុងប៉ារីស ឬគណៈកម្មាធិការប្រតិបត្តិនៃសន្ធិសញ្ញាទីក្រុងប៊ែន។ ជាធម្មតា គណៈកម្មាការសម្របសម្រួល ធ្វើការប្រជុំសាមញ្ញជារៀងរាល់ឆ្នាំ ដោយការកោះប្រជុំរបស់អគ្គនាយកដែលប្រព្រឹត្តិទៅនៅស្នាក់ការរបស់អង្គការ។ ដោយឡែកការប្រជុំវិសាមញ្ញ ធ្វើឡើងដោយតាមការកោះប្រជុំរបស់ប្រធានដោយផ្ទាល់ ឬតាមសំណើររបស់ប្រធានប្រជុំ ឬតាមសំណើររបស់ រដ្ឋជាសមាជិកដោយសម្លេង១/៤នៃចំនួនសមាជិកសរុប។ ការបោះឆ្នោត និងផ្តល់យោបល់របស់គណៈកម្មាការសម្របសម្រួលត្រូវធ្វើឡើងដោយសម្លេងភាគច្រើនធម្មតា ហើយប្រសិនបើសម្លេងនោះត្រូវបានអនុម័ត សមាជិកនីមួយៗអាចចាប់ផ្តើមបាន ក្រោយពីបោះឆ្នោតរួចដោយរបៀបពីរយ៉ាងគឺ បែងចែកបញ្ជីបោះឆ្នោតជាពីរដែលមានឈ្មោះរបស់រដ្ឋសមាជិកនៃគណៈកម្មាការប្រតិបត្តិនៃសន្ធិសញ្ញាទីក្រុងប៉ារីស និងបញ្ជីមួយទៀតមានឈ្មោះរបស់សមាជិកនៃគណៈកម្មាធិការប្រតិបត្តិនៃសន្ធិសញ្ញាទីក្រុងប៊ែន។ នៅក្នុងដំណើរការប្រជុំរបស់គណៈកម្មាការសម្របសម្រួល រដ្ឋដែលមិនមែនជាសមាជិកនៃអង្គការនេះអាចចូលរួមពិភាក្សាបាន ប៉ុន្តែមិនអនុញ្ញាតឲ្យបោះឆ្នោតឡើយ។

ជាទូទៅ គណៈកម្មាការសម្របសម្រួលមានភារកិច្ចៈ

- ផ្តល់យោបល់ដល់មហាសន្និបាត សន្និសិទ និងអគ្គនាយកនៅលើការងាររដ្ឋបាល ហិរញ្ញវត្ថុ និងបញ្ហាផលប្រយោជន៍ទូទៅមួយ ឬច្រើនដល់សហភាពអង្គការផ្សេងៗទៀត ជាពិសេស ពាក់ព័ន្ធនឹងបញ្ហាការចំណាយថវិកាជាទូទៅ

- រៀបចំសេចក្តីព្រាងនៃរបៀបវារៈរបស់មហាសន្និបាត និងសន្និបាត
- នៅពេលដែលអាណត្តិរបស់អគ្គនាយកត្រូវបានបញ្ចប់ ឬនៅពេលដែលមានការជ្រើសរើសមុខនាទីក្នុងនាមជាអគ្គនាយក ការតែងតាំងបេក្ខជនសម្រាប់តំណាងនេះដោយមហាសន្និបាត ប្រសិនបើ មហាសន្និបាតមិនបានតែងតាំងតំណែងនេះបាន គណៈកម្មាការសម្របសម្រួលនឹងតែងតាំងបេក្ខភាព ផ្សេងទៀតរហូតដល់បុគ្គលដែលត្រូវតែងតាំងត្រូវបានតែងតាំងដោយមហាសន្និបាត
- អនុវត្តមុខងារដែលបានកំណត់ដោយអនុសញ្ញាបង្កើតអង្គការកម្មសិទ្ធិបញ្ញា។[59]

❖ **ការិយាល័យអន្តរជាតិ ឬ លេខាធិការដ្ឋាន** (International Bureau or Secretariat)

ការិយាល័យអន្តរជាតិ ឬលេខាធិការដ្ឋាន ជាស្ថាប័នមួយចំនុះនឹងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ ស្ថាប័ននេះ គឺត្រូវដឹកនាំដោយអគ្គនាយកមួយរូប និងអគ្គនាយករងមួយចំនួនជាជំនួយតាមការចាំបាច់ និងត្រូវទទួលបន្ទុកក្នុងការជ្រើសរើសបុគ្គលិកធ្វើការងារជាប្រចាំ និងបុគ្គលិកផ្សេងៗទៀតតាមការចាំបាច់ និងតាមគោលការណ៍ស្មើភាពគ្នា។

អគ្គនាយក គឺជាប្រធានប្រតិបត្តិនៃស្ថាប័ននេះដែលនៅក្នុងនោះគាត់មានតួនាទីជា៖

- អ្នកតំណាងឲ្យអង្គការ
- រាយការណ៍ និងអនុលោមតាមការណែនាំរបស់មហាសន្និបាតទាំងកិច្ចការខាងក្នុង និងខាងក្រៅរបស់អង្គការ
- រៀបចំសេចក្តីព្រាងកម្មវិធី ថវិកា និងរាយការណ៍នូវសកម្មភាពជាច្រើន
- បញ្ជូនកម្មវិធីទាំងអស់នេះទៅរដ្ឋាភិបាលដែលមានចំណាប់អារម្មណ៍នឹងការចំណាយរបស់អង្គការ
- តែងតាំងបុគ្គលិកដែលសំខាន់ៗសម្រាប់ប្រសិទ្ធិភាពការងាររបស់ការិយាល័យអន្តរជាតិ។[60]

**៣.៣.២ ក្រុមប្រឹក្សា** TRIPS

សមាជិកអង្គការពាណិជ្ជកម្មពិភពលោកទាំងអស់ គឺជាក្រុមប្រឹក្សានៃ TRIPS ។ ក្រុមប្រឹក្សានេះទទួលខុសត្រូវសម្រាប់ការត្រួតពិនិត្យទៅលើប្រតិបត្តិការរបស់កិច្ចព្រមព្រៀង TRIPS ហើយជាពិសេស គឺជារបៀបដែលសមាជិកត្រូវអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀងនេះ។ វិវាទទាំងឡាយណាដែលកើតមាន

---

[59] សារណា "ការការពារពូជដំណាំនៅកម្ពុជា" ឈ្មោះនិស្សិត ក.ជា សុវណ្ណរតនៈ និង ក.ឃី លីហួ ឆ្នាំសរសេរសារណា ២០២០ ទំព័រ១៨

[60] សារណា "ការការពារពូជដំណាំនៅកម្ពុជា" ឈ្មោះនិស្សិត ក.ជា សុវណ្ណរតនៈ និង ក.ឃី លីហួ ឆ្នាំសរសេរសារណា ២០២០ ទំព័រ១៨

ដោយសារមិនបានអនុវត្តកាតព្វកិច្ចនៃកិច្ចព្រមព្រៀងនេះ វាត្រូវស្ថិតនៅក្រោមការដោះស្រាយរបស់អង្គការពាណិជ្ជកម្មពិភពលោក។ ក្រុមប្រឹក្សា TRIPS បានចូលរួមដោះស្រាយ និងបំពេញមុខងារជាច្រើនជាមួយនឹងការធ្វើពាណិជ្ជកម្មដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញាដូចជា៖

**៣.៣.២.១ តួនាទីក្នុងការត្រួតពិនិត្យ និងពិគ្រោះយោបល់**

ក្រុមប្រឹក្សានេះត្រួតពិនិត្យទៅលើច្បាប់របស់ប្រទេសជាសមាជិក ដោយប្រាកដថាច្បាប់នោះបានបំពេញនូវកាតព្វកិច្ចនានាដែលយោងតាមអ្វីដែលបានចែងនៅក្នុងកិច្ចព្រមព្រៀង TRIPS ។ ច្បាប់ទាំងនោះត្រូវដាក់ជូនក្រុមប្រឹក្សា TRIPS ត្រួតពិនិត្យ និងអនុញ្ញាតឲ្យសមាជិកធ្វើការត្រួតពិនិត្យឡើងវិញនូវច្បាប់របស់ខ្លួនក្នុងករណីដែលច្បាប់ដែលបានដាក់ជូនមិនស្ថិតនៅក្រោមការកំណត់នៃកិច្ចព្រមព្រៀង។

មិនត្រឹមតែត្រួតពិនិត្យទេ តែក្រុមប្រឹក្សានេះមានតួនាទីក្នុងការពិគ្រោះយោបល់ស្តីពីបញ្ហា TRIPS ផងដែរ។ ក្រុមប្រឹក្សានេះជាវេទិកាសាធារណៈមួយដែលអាចឲ្យប្រទេសនានាប្រើប្រាស់ដើម្បីពិគ្រោះយោបល់គ្នាទៅ វិញទៅមកលើបញ្ហានានាដែលពួកគេអាចមានជាមួយគ្នាក្នុងការអនុវត្តកិច្ចព្រមព្រៀង។ ការធ្វើបែបនេះ វានាំឲ្យមានភាពច្បាស់លាស់នូវការបកស្រាយច្បាប់ និងបទបញ្ញត្តិនានារបស់កិច្ចព្រមព្រៀង TRIPS ។

**៣.៣.២.២ ការពិនិត្យឡើងវិញ និងការចរចារស្តីពីកម្មវត្ថុជាក់លាក់**

អង្គការពាណិជ្ជកម្មពិភពលោក គឺជាវេទិកាមួយសម្រាប់ការចរចារ លើសពីនេះទៅទៀតសម្តៅដល់ការធ្វើអោយប្រសើរឡើងដល់ការប្តេជ្ញានៅក្នុងវិស័យនៃកម្មសិទ្ធិបញ្ញា និងនៅក្នុងវិស័យផ្សេងៗទៀតដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក។ កិច្ចព្រមព្រៀង TRIPS តម្រូវឲ្យមានការ ការពារបន្ថែមទៀតនៅក្នុងវិស័យដែលត្រូវបានបញ្ជាក់រួមមាន៖

- ការពិនិត្យឡើងវិញនៃការអនុវត្តបទបញ្ញត្តិនានាស្តីពីការការពារសម្គាល់ទីតាំងភូមិសាស្ត្រ
- ការពិនិត្យឡើងវិញបន្ទាប់ពីរយៈពេល៤ឆ្នាំ នូវជម្រើសក្នុងការផ្តល់ការការពារបង្កាត់ពូជថ្មីនៃដំណាំ តាមរយៈប្រព័ន្ធដាច់ដោយឡែក ឬតាមរយៈការការពារប្រកាសនីយបត្រតក្កកម្ម
- ការពិនិត្យលើភាពអាចអនុវត្តបានចំពោះ TRIPS នូវបណ្តឹងទាក់ទងនឹងការបំពាននានា។

**៣.៣.២.៣ សហប្រតិបត្តិការបច្ចេកទេស**

ក្រុមប្រឹក្សា TRIPS មានតួនាទីធ្វើសហប្រតិបត្តិការខាងបច្ចេកទេស និងត្រួតពិនិត្យទៅលើការបំពេញកាតព្វកិច្ចដោយយោង តាមមាត្រា៦៧ នៃកិច្ចព្រមព្រៀង។ មាត្រានេះតម្រូវឲ្យប្រទេសអភិវឌ្ឍធ្វើការ និងប្តេជ្ញាពី

ការធ្វើសហប្រតិបត្តិការ។ កម្មវិធីការងារត្រូវធានាថា ប្រទេសកំពុងអភិវឌ្ឍអាចមានពត៌មានគ្រប់គ្រាន់ និងអាចធានាបានផងដែលនូវអ្វីគួរ ឬមិនគួរបំពេញ។[61]

[61] https://www.wto.org/english/docs_e/legal_e/ursum_e.htm#nAgreement (កាលបរិច្ឆេទចូលមើលគេហទំព័រ ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០២១)

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការស្រាវជ្រាវ និងការបកស្រាយទៅលើប្រធានបទ "ការគ្រប់គ្រង និងការការពារពូជថ្មីនៃដំណាំ" រួចមក អាចសបញ្ជាក់អោយយើងឃើញថា ប្រធានបទមួយនេះបានបង្ហាញអំពីការជះឥទ្ធិពលនៃច្បាប់កម្មសិទ្ធិបញ្ញាទៅលើបណ្តាប្រទេសជាច្រើននៅក្នុងសកលលោក និងរួមទាំងព្រះរាជាណាចក្រកម្ពុជាផងដែរ។ ប្រទេសទាំងនោះបានចាប់ផ្តើមបង្កើតច្បាប់នេះឡើង ដើម្បីចៀសវាងពីជម្លោះ និងបញ្ហាដែលទាក់ទងទៅនឹងការធ្វើអាជីវកម្ម និងជាដំណោះស្រាយនៅពេលបញ្ហាកម្មសិទ្ធិបញ្ញាបានកើតឡើង។

នាពេលបច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់កម្មសិទ្ធិបញ្ញាចំនួន៤ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញារបស់ក្រសួងពាណិជ្ជកម្មដែលមានដូចជា ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់ (ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២) ច្បាប់ស្តីពីការប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម (ចុះថ្ងៃទី២២ មករា ឆ្នាំ២០០៣) ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិអ្នកប្រហាក់ប្រហែល (ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣) និងចុងក្រោយគឺច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ (ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨)។ ដោយឡែកការទទួលយក និងព្រមទាំងអនុម័តទៅលើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ពីព្រោះតែប្រទេសកម្ពុជាជាប្រទេសមួយដែលពឹងផ្អែកទៅលើវិស័យកសិកម្មជាធំដោយការនាំចេញ ការនាំចូលផលិតផលកសិកម្មជាមួយប្រទេសជិតខាងជាដើម ហើយម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលបានជំរុញអភិវឌ្ឍសេដ្ឋកិច្ចតាមការចាប់ផ្តើមធ្វើសមាហរណកម្មសេដ្ឋកិច្ចពិភពលោក ដោយតាមរយៈការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងបានចុះហត្ថលេខានៅលើកិច្ចព្រមព្រៀង TRIPS ។ ការធ្វើសមាហរណកម្មសេដ្ឋកិច្ច គឺដើម្បីឲ្យផលិតផលកម្ពុជាបានចូលរួមប្រកួតប្រជែងលើទីផ្សារអន្តរជាតិ ហើយប្រជាជនមានការងារធ្វើ និងជីវភាពកាន់តែប្រសើរជាងមុន។

ការដាក់ចេញនូវច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងអ្នកបង្កាត់ពូជដំណាំ ដោយបានពឹងផ្អែកទៅលើយន្តការរបស់សហភាព UPOV និងបទដ្ឋានគតិយុត្តមួយចំនួនទៀត។ ការចូលរួមរបស់សហភាព UPOV ជាចំណែកមួយដែលធ្វើអោយច្បាប់នេះដំណើរការដោយមានប្រសិទ្ធិភាព និងមានតម្លាភាព ហើយក្នុងនោះអ្វីដែលជាការចូលរួមក្នុងការតាក់តែងសំខាន់បំផុត និងជាច្បាប់គោលសម្រាប់អោយកម្ពុជាយកមកបង្កើតច្បាប់ដោយខ្លួនឯងនោះគឺ ខ្លឹមសារនិងអត្ថន័យនៃសៀវភៅ "មគ្គុទេសក៍សម្រាប់ការរៀបចំច្បាប់ផ្អែកលើច្បាប់ ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ" ។ ទោះបីបច្ចុប្បន្ននេះ កម្ពុជាមិនទាន់ក្លាយជាសមាជិកពេញសិទ្ធិនៃសហភាព UPOV ក្តី ប៉ុន្តែ

កម្ពុជាកំពុងតែត្រៀមក្លាយខ្លួនជាសមាជិកនៃអនុសញ្ញានេះ ដោយតាមរយៈការស្នើសុំពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដោយឡែកក្នុងកំឡុងឆ្នាំ២០០៨ ប្រទេសកម្ពុជាបានអនុម័តនូវច្បាប់មួយស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំដែលជាច្បាប់មួយបង្កើតឡើងក្នុងការចងចំណងគតិយុត្តសម្រាប់អ្នកបង្កាត់ពូជដំណាំ ឬម្ចាស់សិទ្ធិនៃពូជថ្មីដែលរកឃើញ។ ក្នុងនោះ ច្បាប់បានកំណត់ពីប្រភេទនៃពូជដែលអាចចាត់ទុកជាពូជថ្មីដែលបានរកឃើញ លក្ខខណ្ឌដើម្បីការការពារពូជថ្មី សិទ្ធិដែលអ្នកត្រូវបានការការពារទទួលបាន ការដាក់ពិន័យទៅលើអ្នកដែលបំពាន នីតិវិធីសម្រាប់ដោះស្រាយក្នុងការរំលោភបំពានតាមផ្លូវច្បាប់ និងអានុភាពនៃការចុះបញ្ជីក្នុងការការពារពូជថ្មីនៃដំណាំ។ ច្បាប់នេះបានអនុម័តហើយក្តី ប៉ុន្តែយើងនៅមិនទាន់ឃើញមានម្ចាស់ តក្កករណាមកសុំចុះបញ្ជីនៅឡើយទេ ហើយសង្ឃឹមថាតាមរយៈច្បាប់នេះ និងមានអ្នកមានធនធាន ឬអ្នកមានជំនាញក្នុងការបង្កាត់ពូជ ធ្វើការស្រាវជ្រាវនូវពូជថ្មីៗបន្ថែមទៀត ដើម្បីលើកកម្ពស់វិស័យកម្មសិទ្ធិបញ្ញា លើកទឹកចិត្តដល់តក្កករដែលបានរកឃើញដោយផ្តល់ការការពារតាមច្បាប់ និងការអភិវឌ្ឍពូជដំណាំដោយនិរន្តភាព។ យើងឃើញថាសម្រាប់ប្រទេសកម្ពុជាទទួលបានផលប្រយោជន៍ពីការអនុម័តច្បាប់នេះ គឺប្រជាពលរដ្ឋ ឬម្ចាស់តក្កករណាដែលបង្កើតស្នាដៃថ្មីទទួលបានការការពារពូជថ្មីដែលរកឃើញ ហើយពូជថ្មីអាចបំពេញតម្រូវការ អ្នកប្រើប្រាស់ ទាក់ទាញអ្នកវិនិយោគមកបោះទុនធ្វើអាជីវកម្ម ឬឧស្សាហកម្មជាមួយនឹងពូជថ្មី និងបង្កើនការងារចូលរួមកាត់បន្ថយភាពក្រីក្រជាដើម។

សរុបសេចក្តីមកយើងសន្និដ្ឋានបានថា វិស័យនេះជាចំណែកមួយនៃការធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍលើវិស័យកសិកម្មសម្រាប់ប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍ និងការរស់នៅរបស់ប្រជាជនពឹងផ្អែកទៅលើការរំពឹងផលពីកសិកម្មជាធំ។ ការរីកចម្រើនក្នុងវិស័យនេះផងដែរ មានន័យថាអ្នកបានបំពេញនូវតម្រូវការរបស់អ្នកប្រើប្រាស់ដែលត្រូវការអ្វីដែលថ្មី និងអាចផ្គត់ផ្គង់បានគ្រប់គ្រាន់សម្រាប់ការនាំចេញ-នាំចូលទៅក្រៅប្រទេស ការចែកចាយ និងបានរួមចំណែកក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ព្រះរាជាណាចក្រយើងផងដែរ។ សម្រាប់ធនធានមនុស្សដែលមានគំនិតច្នៃប្រឌិត ឬអ្នកដែលយល់ដឹងពីកសិកម្មក្នុងប្រទេសកម្ពុជា គឺមាន ចំនួនច្រើនដោយសារតែវិស័យបានចិញ្ចឹមប្រជាកសិករជាច្រើនលាននាក់ ប៉ុន្តែជាក់ស្តែងកម្ពុជាមិនសូវមាន ឧបករណ៍ល្អៗទំនើបៗសម្រាប់ធ្វើការលើរឿងនេះទេ។ ជារួម គឺយើងរំពឹងថាយន្តការនៃការការពារពូជថ្មីនៃដំណាំរបស់ប្រទេសកម្ពុជា អនុវត្តបានដោយមានគុណភាព និងប្រសិទ្ធភាពខ្ពស់ ហើយនិងឈានទៅរកការអភិវឌ្ឍជានិរន្តរ៍។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីធ្វើការស្រាវជ្រាវ លើប្រធានបទ “ **ការគ្រប់គ្រង និងការពារពូជដំណាំថ្មីនៅកម្ពុជា** ” រួចមក ការផ្តល់អនុសាសន៍មួយចំនួនជាចក្ខុវិស័យ និងយុទ្ធសាស្ត្រទៅថ្ងៃអនាគតដែលជាលទ្ធផលនៃការស្រាវជ្រាវមួយនេះ។

ប្រទេសកម្ពុជា ក៏ដូចជាបណ្តាលប្រទេសផ្សេងទៀតជាច្រើនលើពិភពលោក សុទ្ធសឹងតែជួបនូវផលវិបាកទាក់ទងនឹងការរំលោភបំពានទៅលើកម្មសិទ្ធិ ដែលជាហេតុនាំឱ្យចាំបាច់ត្រូវរកដំណោះស្រាយតាមរយៈការលុបបំបាត់ ឬក៏ទប់ស្កាត់នូវឬសគល់បញ្ហាដែលកំពុងកើតមានឡើង។ ជាការពិតណាស់ ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលកំពុងតែអភិវឌ្ឍន៍ ដូចនេះបញ្ហាដែលប្រឈមគឺមានច្រើន និងដើម្បីឱ្យការអនុវត្តនូវនីតិវិធីនៃការការពារកាន់តែមានប្រសិទ្ធិ និងប្រព្រឹត្តទៅដោយរលូន នោះគឺចាំបាច់ត្រូវ៖

- រាជរដ្ឋាភិបាលគួរតែផ្សព្វផ្សាយ ចែករំលែកនូវយន្តការទាក់ទងនឹងការការពារពូជដំណាំថ្មីទៅកាន់ប្រជាពលរដ្ឋអោយបានកាន់តែច្បាស់ និងទូលំទូលាយ ដោយសារតែប្រជាពលរដ្ឋយើងនូវមានកម្រិតចេះដឹង ដូចនេះពួកគាត់អាចនឹងប្រឈមនឹងការពុំទទួលបាននូវការយល់ដឹងគ្រប់គ្រាន់។
- ត្រូវបង្កើននូវប្រសិទ្ធិភាពក្នុងការផ្តល់នូវយន្តការក្នុងការការពារពូជដំណាំថ្មី ដោយរាជរដ្ឋាភិបាលគប្បីធ្វើការកាត់បន្ថយនូវស្ថាប័នមួយចំនួន ដែលក្នុងនោះច្បាប់បានចែងថា នីតិវិធីក្នុងការទទួលបាននូវការគ្រប់គ្រង និងការពារពូជដំណាំថ្មីគឺស្ថិតនៅលើក្រសួង២ គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ ដោយមកធ្វើការដាក់ស្នើសុំត្រឹមតែក្រសួងកសិកម្ម វិញតែមួយប៉ុណ្ណោះ ដើម្បីឱ្យពេលវេលានៃការរៀបចំនីតិវិធីផ្តល់លិខិតស្នើសុំកាន់តែមានពេលច្រើនគ្រប់គ្រាន់។
- បណ្តុះបណ្តាលនូវធនធានមនុស្ស ដោយផ្តល់ឱកាសដល់ពួកគាត់បានធ្វើការសិក្សាបន្ថែមនិងចែករំលែកចំណេះដឹងរវាងបណ្តាលប្រទេសផ្សេងៗដែលមានបច្ចេកវិទ្យាជឿនលឿន តាមរយៈការជម្រុញឱ្យមាននូវកិច្ចសហប្រតិបត្តិការអន្តរជាតិឱ្យបានច្រើនទាក់ទងនឹងយន្តការការពារពូជដំណាំថ្មី និងទាមទារឱ្យមានអ្នកជំនេញពីបរទេសមកធ្វើការបណ្តុះបណ្តាលបន្ថែមដល់មន្ត្រីទទួលបន្ទុកផងដែរ។
- ម្យ៉ាងវិញទៀត គួរលើកទឹកចិត្ត និងធ្វើយ៉ាងណាពង្រឹងវិស័យកម្មសិទ្ធិបញ្ញាថ្នាក់ជាតិឱ្យបានរឹងមាំ ដើម្បីអាចការពារកម្មសិទ្ធិបញ្ញាបានល្អប្រសើរទៅតាមការដាក់ពាក្យស្នើសុំ ហើយជៀសវាងនូវការរំលោភបំពានសិទ្ធិលើកម្មសិទ្ធិបញ្ញា ក៏ដូចជាទប់ស្កាត់នូវអំពើពុករលួយ ដែលជាសកម្មភាពមួយដែលបានបង្ហាញ ពីការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងដំណើរការកែទម្រង់ទៅលើស្ថាប័ន

រដ្ឋបាលថ្នាក់ជាតិ ដើម្បីស្របតាមគោលនយោបាយចតុកោណ របស់រាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្ន ។

- ទៅថ្ងៃអនាគត យើងសង្ឃឹមថាស្ថាប័នដែលពាក់ព័ន្ធនឹងបន្តខិតខំធ្វើយ៉ាងឱ្យប្រទេសកម្ពុជានឹងក្លាយជាសមាជិកពេញសិទ្ធិនៃសហភាពអន្តរជាតិការការពារពូជថ្មីនៃដំណាំ ដោយសារបច្ចុប្បន្ននេះ ប្រទេសកម្ពុជាគ្រាន់តែជាសមាជិកសង្កេតការប្រចាំនៅក្នុងក្រុមប្រឹក្សានៃអង្គការនេះតែប៉ុណ្ណោះ ។

# ឯកសារយោង

# ឯកសារយោង

## ក. ច្បាប់ជាតិ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ២០០៣
- អនុក្រឹតលេខ ១៤២ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០០៨
- អនុក្រឹតលេខ ៣៥ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០០៧
- ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២០
- ឯកសាររបស់សមាគមន៍ជាតិនៃរុក្ខជាតិបង្កាត់ពូជ National Association of Plant Breeders

## ខ. ច្បាប់អន្តរជាតិ

- អនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារពូជថ្មីនៃដំណាំ ឆ្នាំ១៩៩១ (International Convention for the Protection of New Varieties of Plants 1991)
- អនុសញ្ញាទីក្រុងប៉ារីសស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម (Paris Convention for the Protection of Industrial Property)
- កិច្ចព្រមព្រៀងស្តីពិទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (Agreement on Trade Related Aspect of Intellectual Property Right " TRIPS " 1994
- អនុសញ្ញាសហាព័ន្ធអន្តរជាតិស្តីពីកិច្ចការពារពូជថ្មីនៃដំណាំ ឆ្នាំ១៩៦១ (International Convention for the Protection of New Varieties of Plants 1961)
- អនុសញ្ញាសហាព័ន្ធអន្តរជាតិស្តីពីកិច្ចការពារពូជថ្មីនៃដំណាំ ឆ្នាំ១៩៧២ (International Convention for the Protection of New Varieties of Plants 1972)
- អនុសញ្ញាសហាព័ន្ធអន្តរជាតិស្តីពីកិច្ចការពារពូជថ្មីនៃដំណាំ ឆ្នាំ១៩៧៨ (International Convention for the Protection of New Varieties of Plants 1978)
- អនុសញ្ញាស្តីពីភាពខុសប្លែកគ្នានៃជីវសាស្រ្ត (Convention on Biological Diversity)

**គ. ប្រភពពីសៀវភៅ**

- សៀវភៅមេរៀនសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ និងរដ្ឋបាលសាធារណៈ មុខវិជ្ជា នីតិកម្មសិទ្ធិបញ្ញា ដោយសាស្ត្រាចារ្យ ឃឹម គិរី
- នីតិសៀវភៅនីតិកម្មសិទ្ធិបញ្ញា ឯកឧត្តម ឥន យឿន និងសាស្ត្រាចារ្យ អ៊ុក វណ្ណារ័ត្ន បោះពុម្ពលើកទី១ ឆ្នាំ ២០១៣
- មគ្គុទេសក៏សម្រាប់ការរៀបចំច្បាប់ផ្អែកលើច្បាប់ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ

**ឃ. ប្រភពពីគេហទំព័រ**

- https://www.plantbreeding.org/ (កាលបរិច្ឆេទចូលមើលថ្ងៃទី០១ ខែ ឧសភា ឆ្នាំ២០២១)
- https://www.cambodiaip.gov.kh/TemplateTwo.aspx?parentId=45&menuid=291&childMasterMenuId=291(កាលបរិច្ឆេទចូលមើលថ្ងៃទី០១ ខែ ឧសភា ឆ្នាំ២០២១)
- https://www.upov.int/edocs/mdocs/upov/en/upov_trainer_en_16/upov_trainer_en_16_world_cafe_1.pdf (កាលបរិច្ឆេទចូលមើលថ្ងៃទី០១ ខែ ឧសភា ឆ្នាំ២០២១)
- https://drive.google.com/file/d/0B2BhecGG1FSecVVyd2t0bUR5bkU/view?resourcekey=0-6NXJ6aw5IAPk38wsHIeE7A (កាលបរិច្ឆេទចូលមើលគេហទំព័រ : ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២១)
- https://www.upov.int/portal/index.html.en (កាលបរិច្ឆេទចូលមើល ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១)
- https://www.upov.int/edocs/pubdocs/en/upov_pub_437.pdf (កាលបរិច្ឆេទចូលមើល ថ្ងៃទី១៨ ខែ ឧសភា ឆ្នាំ២០២១)
- https://www.upov.int/edocs/pubdocs/en/upov_pub_423.pdf (កាលបរិច្ឆេទចូលមើល ថ្ងៃទី១៨ ខែ ឧសភា ឆ្នាំ២០២១)
- https://internationalipcooperation.eu/en/caripi/news/saint-vincent-and-grenadines-accedes-international-convention-protection-new-varieties (កាលបរិច្ឆេទចូលមើល ថ្ងៃទី១៨ ខែ ឧសភា ឆ្នាំ២០២១)
- Article 21 (INTERNATIONAL CONVENTION FOR THE PROTECTION OF NEW VARIETIES OF PLANTS)
- https://www.upov.int/meetings/en/topic.jsp?group_id=253 (កាលបរិច្ឆេទចូលមើល ថ្ងៃទី១៩ ខែ ឧសភា ឆ្នាំ២០២១)

- https://en.wikipedia.org/wiki/United_International_Bureaux_for_the_Protection_of_Intellectual_Property (កាលបរិច្ឆេទចូលមើល ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១)
- http://eapvp.org/member/ (កាលបរិច្ឆេទចូលមើល ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១)
- http://eapvp.org/report-data/vietnam/the-13th-eapvp-forum-meeting/ (កាលបរិច្ឆេទចូលមើល ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១)
- https://www.wipo.int/members/en/ (កាលបរិច្ឆេទចូលមើលគេហទំព័រ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១)
- https://www.wto.org/english/docs_e/legal_e/ursum_e.htm#nAgreement (កាលបរិច្ឆេទចូលមើលគេហទំព័រ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១) ។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

១. ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

២. អនុសញ្ញាអន្តរជាតិ ស្តីពី កិច្ចការពារពូជថ្មីនៃដំណាំ

៣. Agreement on Trade-related aspects of Intellectual Property Rights (TRIPS)

# ឧបសម្ព័ន្ធទី១
# ច្បាប់ស្ដីពីការគ្រប់គ្រងពូជដំណាំ និង
# សិទ្ធិបង្កាត់ពូជដំណាំ

នស/រកម/០៥០៨/០១៥

# ព្រះរាជក្រម

## យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្ដីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានអនុម័ត កាលពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយដែលមានសេចក្ដីទាំងស្រុងដូចភ្ជាប់ទៅនេះ :

# ច្បាប់

## ស្តីពី

# ការគ្រប់គ្រងពូជដំណាំ

## និង

# សិទ្ធិអ្នកបង្កាត់ពូជដំណាំ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះ មានគោលដៅ គ្រប់គ្រង និងត្រួតពិនិត្យលើការបង្កាត់ ការបញ្ចេញឱ្យប្រើ ការផលិត ការកែច្នៃ ការចុះបញ្ជី ការចែកចាយ ការនាំចូល នាំចេញពូជដំណាំ និង ការការពារពូជថ្មីនៃដំណាំ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.–**

ច្បាប់នេះមានគោលបំណង ធានានូវការគ្រប់គ្រង ការលើកទឹកចិត្ត និង ការអភិវឌ្ឍពូជដំណាំដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និង បរិស្ថាន ។

**មាត្រា ៣.–**

ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់ពូជដំណាំ រួមទាំងពូជដំណាំដែលមានស្រាប់ និង ពូជថ្មីនៃដំណាំ លើកលែងតែការគ្រប់គ្រង ដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា ៤.–**

ការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ការគ្រប់គ្រងពូជដំណាំគ្រប់ប្រភេទ ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥.–**

វាក្យស័ព្ទសំខាន់ៗ ដែលប្រើប្រាស់ក្នុងច្បាប់នេះ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ ។

## ជំពូកទី ២
## ការការពារពូជថ្មីនៃដំណាំ

### ផ្នែកទី ១
### លក្ខខណ្ឌសម្រាប់ការផ្តល់សិទ្ធិដល់អ្នកបង្កាត់ពូជដំណាំ

**មាត្រា ៦.–**

ពូជថ្មីនៃដំណាំដែលទទួលបាននូវសិទ្ធិការពារត្រូវមានលក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម៖

-ភាពថ្មី

-ភាពខុសប្លែក

-ឯកសណ្ឋានភាព

-ស្ថេរភាព ។

**មាត្រា ៧.–**

ពូជដំណាំ ដែលអាចចាត់ទុកថាថ្មី លុះត្រាតែពុំទាន់បានដាក់លក់ ឬ ចរាចរលើទីផ្សារកន្លងមក ប៉ុន្តែដោយមានការឯកភាពពីអ្នកបង្កាត់ពូជ ពូជថ្មីនៃដំណាំនោះត្រូវបានដាក់លក់ ឬ ចរាចរលើទីផ្សារ ក្នុងរយៈពេលមិនលើសពី ១ (មួយ)ឆ្នាំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង មិនលើសពី ៦(ប្រាំមួយ)ឆ្នាំ ចំពោះដំណាំវល្លិ និងដំណាំឈើ និងមិនលើសពី ៤(បួន) ឆ្នាំ ចំពោះគ្រប់ដំណាំផ្សេងៗទៀត នៅក្រៅព្រះរាជាណាចក្រកម្ពុជា ដោយគិតមកដល់ថ្ងៃដាក់ពាក្យស្នើសុំសិទ្ធិការពារ ។

**មាត្រា ៨.–**

ពូជដំណាំដែលចាត់ទុកថាមានភាពខុសប្លែកពីគេ លុះត្រាតែមានភាពខុសគ្នាដាច់ស្រឡះពីពូជឯទៀត ដែលគេស្គាល់ជាទូទៅ ត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំសិទ្ធិ ឬ កាលបរិច្ឆេទសិទ្ធិអាទិភាព ។

ROYAUME DU CAMBODGE

មាត្រា ៩.-

ពូជដំណាំ ដែលចាត់ទុកថាមានឯកសណ្ឋានភាព លុះត្រាតែអាចរក្សាឯកសណ្ឋានភាពគ្រប់គ្រាន់នូវចរិតលក្ខណៈពាក់ព័ន្ធរបស់ពូជ ទោះបីពូជដំណាំនោះ ត្រូវបានផលិតតាមរយៈភេទ ឬ អភេទក្តី ។

មាត្រា ១០.-

ពូជដំណាំ ដែលចាត់ទុកថាមានស្ថេរភាព លុះត្រាតែចរិតលក្ខណៈចាំបាច់របស់វាគ្មានការប្រែប្រួលនៅគ្រប់ដំណាក់កាលនៃវដ្តលូតលាស់ និងជំនាន់នីមួយៗ ។

## ផ្នែកទី ២
## វិសាលភាព និងសុពលភាពនៃសិទ្ធិអ្នកបង្កាត់ពូជដំណាំ

មាត្រា ១១.-

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានបង្កាត់ ឬ រកឃើញ និង អភិវឌ្ឍពូជថ្មីនៃដំណាំ ហើយមានបំណងការពារកម្មសិទ្ធិបញ្ញាលើពូជថ្មីនោះ ត្រូវដាក់ពាក្យស្នើសុំនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវបញ្ជូនឯកសារនោះទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីសិក្សាវាយតម្លៃអំពីលទ្ធផលបច្ចេកទេស ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់នេះ ។

វិញ្ញាបនបត្របញ្ជាក់សិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវផ្តល់ដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រោយពីទទួលបានលិខិតបញ្ជាក់លទ្ធផលនៃការសិក្សាវាយតម្លៃលក្ខណៈបច្ចេកទេសពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ១២.-

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលជាស្ថាប័នទទួលខុសត្រូវក្នុងការចុះបញ្ជីការពារពូជថ្មីនៃដំណាំ មានតួនាទីដូចខាងក្រោម :

១-ផ្តល់ការការពារសិទ្ធិអ្នកបង្កាត់ពូជថ្មីនៃដំណាំ

២-ផ្ទាស់ប្តូរម្ចាស់កម្មសិទ្ធិ

៣-ប្រកាសមោឃភាព ឬ លុបចោល

៤-ទទួលពាក្យចុះបញ្ជី ផ្លាស់ប្តូរ ឬ លុបចោលឈ្មោះពូជថ្មីនៃដំណាំ

៥-ចេញអាជ្ញាប័ណ្ណបញ្ជា និង

៦-កត់ត្រាកិច្ចសន្យាអាជ្ញាប័ណ្ណ ។

**មាត្រា ១៣.-**

អ្នកដាក់ពាក្យស្នើសុំការពារពូជថ្មីនៃដំណាំ ត្រូវ :

ក-មានសញ្ជាតិជាខ្មែរ ឬ សញ្ជាតិបរទេស ប៉ុន្តែត្រូវមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ

ខ-មានទីលំនៅអចិន្ត្រៃយ៍នៅរដ្ឋជាភាគីហត្ថលេខីនៃអនុសញ្ញាសហព័ន្ធអន្តរជាតិការពារពូជថ្មីនៃដំណាំ ឬ នៅរដ្ឋណាមួយ ដែលមានបដិការយោគយល់គ្នាទៅវិញទៅមកជាមួយព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៤.-**

ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំមានសិទ្ធិលក់ ឬ ផ្ទេរសិទ្ធិរបស់ខ្លួនបាន ។ ការលក់ ឬ ការផ្ទេរទៅឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គល ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ និងត្រូវចុះហត្ថលេខាដោយភាគីពាក់ព័ន្ធ ហើយត្រូវកត់ត្រានៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដោយត្រូវជូនដំណឹងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ១៥.-**

ការយកពូជ ឬ បំណែកពូជ ដែលបានការពារទៅប្រើប្រាស់ក្នុងសកម្មភាព ការផលិត ឬ ការផលិតឡើងវិញ ការកំណត់លក្ខខណ្ឌក្នុងគោលបំណងពង្រីកពូជ ការផ្គត់ផ្គង់សម្រាប់លក់ ការលក់ ឬ ការចែកចាយនៅលើទីផ្សារ ការនាំចេញ ការនាំចូល និង ការធ្វើសន្និធិ ត្រូវសុំការអនុញ្ញាតពីម្ចាស់សិទ្ធិ ។

ម្ចាស់សិទ្ធិ អាចផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់ពូជដំណាំរបស់ខ្លួន ដោយភ្ជាប់នូវលក្ខខណ្ឌ ឬ ការកំណត់ផ្សេងៗ ។

ការធ្វើអាជីវកម្ម និង ប្រើប្រាស់ ដូចមានចែងក្នុងវាក្យខណ្ឌទី ១ នៃមាត្រានេះនូវផលិតផលដែលប្រមូលបានពីការដាំដុះពូជថ្មីនៃដំណាំ ដោយពុំមានការអនុញ្ញាត ត្រូវសុំ

ការអនុញ្ញាតពីម្ចាស់សិទ្ធិ ។ ម្ចាស់សិទ្ធិមានឱកាសសមស្របក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន ។ នៅពេលម្ចាស់សិទ្ធិបានដឹងពីការប្រើប្រាស់ និង ធ្វើអាជីវកម្ម ដោយពុំមានការអនុញ្ញាត តែមិនបានប្រើប្រាស់សិទ្ធិរបស់ខ្លួន ម្ចាស់សិទ្ធិនឹងបាត់សិទ្ធិប្តឹងតវ៉ា ។

សិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំក៏មានវិសាលភាពគ្របដណ្តប់ផងដែរទៅលើពូជ :

-ដែលបានបង្កើតថ្មី ដោយយកលក្ខណៈពិសេសសំខាន់ៗចេញពីពូជបានការពារ

-ដែលពុំមានភាពខុសគ្នាដាច់ស្រឡះ ពីពូជបានការពារ

-ដែលផលិតកម្មរបស់វាត្រូវការប្រើប្រាស់ឡើងវិញនូវពូជដែលបានការពារ ។

**មាត្រា ១៦.-**

សិទ្ធិការពារពូជថ្មីនៃដំណាំ ពុំមានវិសាលភាពគ្របដណ្តប់ចំពោះករណីដូចខាងក្រោម :

១-ការប្រើប្រាស់ក្នុងគោលបំណងពិសោធន៍

២-ការដាំសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន និងគ្មានបំណងធ្វើពាណិជ្ជកម្ម

៣-ការប្រើប្រាស់ក្នុងគោលបំណងបង្កាត់ពូជដំណាំថ្មីផ្សេងទៀត លើកលែងតែវាក្យខណ្ឌទី ៤ មាត្រា ១៥ នៃច្បាប់នេះ ។

ដោយផ្អែកលើការការពារផលប្រយោជន៍ស្របច្បាប់ និង ព្រំដែនសិទ្ធិរបស់ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចដាក់ចេញនូវបទប្បញ្ញត្តិដែលកម្រិតសិទ្ធិរបស់ម្ចាស់សិទ្ធិការពារពូជថ្មីនៃដំណាំនានា ដើម្បីអនុញ្ញាតឱ្យកសិករផលិត និង ប្រើប្រាស់ជាសម្បត្តិផ្ទាល់ខ្លួននូវផលិតផលដែលប្រមូលផលបានពីការដាំដុះពូជថ្មីនៃដំណាំ ដែលបានការពារក្នុងគោលបំណងយកទៅដាំដុះបន្ត ។

**មាត្រា ១៧.-**

ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ ត្រូវបាត់បង់សិទ្ធិចំពោះបំណែកពូជនៃពូជដែលទទួលបានការការពារ ឬ ពូជដំណាំដូចមានចែងក្នុងវាក្យខណ្ឌទី ៤ នៃមាត្រា ១៥ ដែលត្រូវបានដាក់លក់ ឬ ចរាចរនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់សិទ្ធិ ឬ មានការយល់

ព្រមពីម្ចាស់សិទ្ធិ ។ សិទ្ធិខាងលើនឹងមិនបាត់បង់ទេ ក្នុងករណីពូជ ឬ បំណែកពូជដែលយកចេញពីពូជដែលបានការពារ ត្រូវបានយកទៅពង្រីកពូជបន្ត ឬ នាំចេញទៅពង្រីកពូជក្នុងប្រទេសដែលមិនផ្តល់ការការពារ លើកលែងតែក្នុងគោលបំណងយកទៅប្រើប្រាស់ចុងក្រោយ ។

**មាត្រា ១៨.–**

ក្នុងរយៈពេលអនុវត្តសិទ្ធិ ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំមានកាតព្វកិច្ចផ្តល់សំណាកពូជដែលអាចដុះបាន ហើយមានចរិតលក្ខណៈដូចបានបញ្ជាក់ក្នុងសំណុំលិខិតស្នើសុំសិទ្ធិការពារ តាមតម្រូវការរបស់អង្គភាពមានសមត្ថកិច្ច ។

ក្នុងគោលបំណងថែរក្សាពូជថ្មីនៃដំណាំ ម្ចាស់សិទ្ធិក៏មានកាតព្វកិច្ចផ្តល់ព័ត៌មាននានាដែលពាក់ព័ន្ធនឹងពូជថ្មីនៃដំណាំ និង បង្កភាពងាយស្រួលក្នុងការត្រួតពិនិត្យដល់អង្គភាពមានសមត្ថកិច្ច ។

**មាត្រា ១៩.–**

សុពលភាពសិទ្ធិការពារលើពូជថ្មីនៃដំណាំមានរយៈពេល ២០ (ម្ភៃ) ឆ្នាំ លើកលែងតែដំណាំដែលមានលក្ខណៈពិសេសដូចជាដំណាំវល្លិ និងដំណាំឈើ ដែលត្រូវមានរយៈពេល ២៥ (ម្ភៃប្រាំ) ឆ្នាំ ក្រោយពីទទួលបានសិទ្ធិការពារលើពូជថ្មីនៃដំណាំនោះ ។

## ផ្នែកទី ៣
## ការបញ្ចប់ មោឃភាព និងការលុបចោល

**មាត្រា ២០.–**

សិទ្ធិការពារពូជថ្មីនៃដំណាំនឹងត្រូវបានបញ្ចប់មុនកាលបរិច្ឆេទផុតសុពលភាព ក្នុងករណីដែលម្ចាស់សិទ្ធិបោះបង់ចោលសិទ្ធិ ដោយធ្វើលិខិតជូនដំណឹងជាលាយល័ក្ខណ៍អក្សរជូនមន្ត្រីកាន់កាប់បញ្ជីនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

កាលបរិច្ឆេទនៃការបញ្ចប់ ត្រូវបញ្ជាក់ក្នុងលិខិតជូនដំណឹង ឬ បើគ្មានការកំណត់កាលបរិច្ឆេទសុំបញ្ចប់ច្បាស់លាស់ នៅក្នុងលិខិតជូនដំណឹងនោះទេ ត្រូវយកកាលបរិច្ឆេទដែលមន្ត្រីកាន់កាប់បញ្ជីទទួលបានលិខិតជូនដំណឹងនោះ ។

**មាត្រា ២១.-**

មន្ត្រីកាន់កាប់បញ្ជី ត្រូវប្រកាសជាមោឃភាពនូវសិទ្ធិរបស់ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ ក្នុងករណីរកឃើញថា :

១-លក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៧ ឬ មាត្រា ៨ នៃច្បាប់នេះមិនបាន បំពេញដូចកាលពីពេលផ្តល់សិទ្ធិ

២-លក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៩ ឬ មាត្រា ១០ នៃច្បាប់នេះ មិនបាន បំពេញដូចកាលពីពេលផ្តល់សិទ្ធិ ដោយផ្អែកលើព័ត៌មាន និង ឯកសារដែលផ្តល់ដោយអ្នក បង្កាត់ពូជដំណាំ

៣-សិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំ ត្រូវបានផ្តល់ទៅឱ្យបុគ្គលដែលគ្មានសិទ្ធិទទួល ។

**មាត្រា ២២.-**

មន្ត្រីកាន់កាប់បញ្ជី ត្រូវលុបសិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំ ក្នុងករណីដូចខាងក្រោម :

១-លក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៩ ឬ មាត្រា ១០ នៃច្បាប់នេះ លែងបំពេញ បាន

២-ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ មិនបានអនុវត្តតាមការតម្រូវរបស់មន្ត្រីកាន់កាប់ បញ្ជី ដោយ :

ក-មិនបានផ្តល់នូវព័ត៌មាន ឯកសារ ឬ ពូជដំណាំ ដែលចាំបាច់សម្រាប់ ការផ្ទៀងផ្ទាត់

ខ-ខកខានមិនបានបង់កម្រៃ ដើម្បីរក្សាសិទ្ធិឱ្យនៅជាធរមាន ឬ

គ-មិនបានផ្តល់ឈ្មោះថ្មីសមស្រប បន្ទាប់ពីឈ្មោះពូជដំណាំដែល ទទួលបានសិទ្ធិការពារនោះ ត្រូវបានលុប ។

## ជំពូកទី ៤

## ការដាក់ពាក្យ និង សិទ្ធិអាទិភាព

**មាត្រា ២៣.-**

អ្នកដាក់ពាក្យសុំការពារពូជថ្មីនៃដំណាំ ត្រូវដាក់ពាក្យជូនមន្ត្រីកាន់កាប់បញ្ជីតាមគំរូ ពាក្យសុំដែលបានកំណត់ ។

៦

អ្នកដាក់ពាក្យសុំ ត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់ ឯកសារ ឬ ពូជដំណាំ តាមកាលបរិច្ឆេទ និង ទីកន្លែង ដែលកំណត់ដោយមន្ត្រីកាន់កាប់បញ្ជី ។

មន្ត្រីកាន់កាប់បញ្ជី ត្រូវចុះកាលបរិច្ឆេទទទួលពាក្យសុំ បន្ទាប់ពីបានបង់កម្រៃរួច ។

គំរូពាក្យសុំ ឯកសារ ឬ ពូជដំណាំនឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ២៤.-**

អ្នកដាក់ពាក្យសុំ អាចប្រើប្រាស់សិទ្ធិអាទិភាពនៃពាក្យសុំលើកដំបូងនៅបរទេស សម្រាប់ពូជដំណាំដូចគ្នានៅប្រទេសណាមួយដែលជាភាគីហត្ថលេខីនៃអនុសញ្ញាសហព័ន្ធអន្តរជាតិការពារពូជថ្មីនៃដំណាំ ។

ក្នុងករណីមានពាក្យសុំច្រើននៅច្រើនប្រទេស សិទ្ធិអាទិភាពនឹងត្រូវផ្តល់ចំពោះតែការដាក់ពាក្យសុំលើកដំបូងបង្អស់ ។

អ្នកដាក់ពាក្យសុំ ត្រូវបញ្ជាក់សិទ្ធិអាទិភាពឱ្យបានច្បាស់លាស់ក្នុងពាក្យសុំដែលបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ហើយសិទ្ធិអាទិភាពត្រូវមានរយៈពេល ១២(ដប់ពីរ)ខែ គិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យលើកដំបូងបង្អស់ ។

**មាត្រា ២៥.-**

ដើម្បីប្រើប្រាស់សិទ្ធិអាទិភាពរបស់ខ្លួនបាន អ្នកដាក់ពាក្យសុំត្រូវប្រគល់ឯកសារចម្លងនៃសំណុំលិខិតស្នើសុំដែលបានដាក់ដំបូងបង្អស់ចំនួនមួយច្បាប់ និង ត្រូវមានការបញ្ជាក់ថា ត្រឹមត្រូវតាមច្បាប់ដើម ដោយការិយាល័យដែលបានទទួលសំណុំលិខិតស្នើសុំដំបូងបង្អស់ក្នុងរយៈពេល ៣(បី)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យសុំនៅព្រះរាជាណាចក្រកម្ពុជា ។

មន្ត្រីកាន់កាប់បញ្ជី អាចផ្តល់ពេលវេលាសមស្របបន្ថែម សម្រាប់ការផ្តល់ព័ត៌មាន ឯកសារ ឬ ពូជដំណាំ តាមការស្នើសុំ ។

ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា លក្ខខណ្ឌតម្រូវក្នុងវាក្យខណ្ឌទី ១ នៃមាត្រានេះមិនបានបំពេញត្រឹមត្រូវទេនោះ ការទាមទារសិទ្ធិអាទិភាពត្រូវចាត់ទុកថាមិនបានទេឡើយ ។

ROYAUME DU CAMBODGE

## ផ្នែកទី ៥
## ការដាក់ឈ្មោះពូជដំណាំ និងការប្រើប្រាស់

**មាត្រា ២៦.–**

អ្នកដាក់ពាក្យសុំ ត្រូវដាក់ឈ្មោះពូជដំណាំស្របទៅតាមបទប្បញ្ញត្តិនៃផ្នែកនេះ ។

ឈ្មោះពូជថ្មីនៃដំណាំ ត្រូវចាត់ទុកថាមិនសមស្រប ក្នុងករណីដូចខាងក្រោម :

ក-មិនអាចសម្គាល់ពូជដំណាំបាន

ខ-មានសញ្ញាតែមួយ លើកលែងតែសញ្ញានោះ អាចសម្គាល់ពូជដំណាំបាន

គ-នាំឱ្យសាធារណជនយល់ខុស ឬ បណ្តាលឱ្យភ័ន្តច្រឡំទៅនឹងចរិតលក្ខណៈ ឬ តម្លៃ ឬ អត្តសញ្ញាណនៃពូជដំណាំ ឬ អត្តសញ្ញាណរបស់អ្នកបង្កាត់ពូជ

ឃ-ដូចទៅនឹងឈ្មោះពូជដំណាំ ដែលមានរួចហើយក្នុងប្រភេទដំណាំតែមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ រដ្ឋជាភាគីហត្ថលេខី

ង-ដូចទៅនឹងឈ្មោះពូជដំណាំ ដែលទទួលបានសិទ្ធិមុន ។

មានតែឈ្មោះដែលបានប្រើក្នុងការស្នើសុំ ឬ ចុះបញ្ជី នៅរដ្ឋជាភាគីហត្ថលេខីទេ ដែលត្រូវប្រើសម្រាប់ការស្នើសុំ ឬ ចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា លើកលែងតែឈ្មោះដែលមានន័យមិនសមស្របតាមប្រពៃណីវប្បធម៌របស់ព្រះរាជាណាចក្រកម្ពុជា អ្នកកាន់កាប់បញ្ជីអាចតម្រូវឱ្យផ្តល់ឈ្មោះថ្មីបាន ។

**មាត្រា ២៧.–**

បុគ្គលធ្វើអាជីវកម្មពូជថ្មីនៃដំណាំ ដែលទទួលបានសិទ្ធិការពារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រើប្រាស់ឈ្មោះពូជដំណាំដែលបានចុះបញ្ជី ទោះបីជាសិទ្ធិការពារផុតសុពលភាពក៏ដោយ លើកលែងតែសិទ្ធិដែលទទួលបានមុនណាមួយរារាំងដល់ការប្រើប្រាស់បែបនេះ ។

ពាណិជ្ជសញ្ញា ពាណិជ្ជនាម ឬ ការបញ្ជាក់ប្រហាក់ប្រហែលផ្សេងទៀត អាចភ្ជាប់ជាមួយឈ្មោះពូជថ្មីនៃដំណាំដែលបានការពារនៅពេលដែលពូជនោះត្រូវបានធ្វើអាជីវកម្ម ។

ROYAUME DU CAMBODGE

**មាត្រា ២៨.-**

មន្ត្រីកាន់កាប់បញ្ជីត្រូវលុបឈ្មោះពូជដំណាំដែលបានចុះបញ្ជីរួចហើយ ប្រសិនបើឈ្មោះនោះមិនគួរត្រូវបានចុះបញ្ជី ។ ករណីនេះ ម្ចាស់សិទ្ធិត្រូវស្នើឈ្មោះថ្មីសមស្រប ដើម្បីចុះបញ្ជី ។

**មាត្រា ២៩.-**

ត្រូវបានហាមឃាត់ :

-ធ្វើអាជីវកម្មពូជថ្មីនៃដំណាំ ដែលទទួលបានសិទ្ធិការពារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រើប្រាស់ឈ្មោះដែលបានចុះបញ្ជី ដោយចេតនា

-ធ្វើអាជីវកម្មពូជថ្មីនៃដំណាំ ដែលទទួលបានសិទ្ធិការពារក្នុងព្រះរាជាណាចក្រកម្ពុជាលើពូជផ្សេងទៀតនៃដំណាំក្នុងប្រភេទដំណាំតែមួយ ដោយចេតនា ។

## ផ្នែកទី ៦
## ការពិនិត្យពាក្យស្នើសុំ និងការបោះពុម្ពផ្សាយ

**មាត្រា ៣០.-**

មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យពាក្យសុំដើម្បីកំណត់ថា បានបំពេញនូវលក្ខខណ្ឌនៃភាពថ្មី ភាពខុសប្លែក ឯកសណ្ឋានភាព និង ស្ថេរភាព ។ នៅពេលដែលលក្ខខណ្ឌទាំងនោះមិនត្រូវបានបំពេញ មន្ត្រីកាន់កាប់បញ្ជីត្រូវបដិសេធពាក្យស្នើសុំ ។

ក្នុងគោលបំណងកំណត់ភាពខុសប្លែក ឯកសណ្ឋានភាព និង ស្ថេរភាព មន្ត្រីកាន់កាប់បញ្ជីត្រូវបញ្ជូនសំណុំឯកសារទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសិក្សាវាយតម្លៃអំពីលទ្ធផលបច្ចេកទេស ។

នៅពេលការសិក្សាវាយតម្លៃលទ្ធផលបច្ចេកទេស បង្ហាញលទ្ធផលវិជ្ជមាន និងការស្នើដាក់ឈ្មោះពូជដំណាំអាចចុះបញ្ជីបាន មន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តល់វិញ្ញាបនបត្របញ្ជាក់សិទ្ធិការពារពូជថ្មីនៃដំណាំ ហើយត្រូវបោះពុម្ពវិញ្ញាបនបត្របញ្ជាក់សិទ្ធិនោះនៅក្នុងព្រឹត្តិបត្រផ្លូវការ ។

ROYAUME DU CAMBODGE

នៅពេលដែលការត្រួតពិនិត្យបង្ហាញថា ការស្នើសុំដាក់ឈ្មោះពូជដំណាំមិនអាចចុះបញ្ជីបាន មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើឱ្យអ្នកដាក់ពាក្យផ្តល់ឈ្មោះផ្សេងទៀតក្នុងរយៈពេលមិនលើសពី៣(បី)ខែ ។ ក្នុងករណីអ្នកដាក់ពាក្យខកខានមិនបានបំពេញតាមលក្ខខណ្ឌនេះទេ ត្រូវបដិសេធពាក្យសុំនោះ ។

នៅពេលដែលវិញ្ញាបនបត្របញ្ជាក់សិទ្ធការពារពូជថ្មីនៃដំណាំត្រូវបានផ្តល់ ម្ចាស់សិទ្ធិមានសិទ្ធិទាមទារសំណងសមស្រប ចំពោះសកម្មភាពទាំងឡាយណាដូចមានចែងក្នុងវាក្យខណ្ឌទី ១ មាត្រា ១៥ នៃច្បាប់នេះ ក្នុងចន្លោះពេលពីការបោះពុម្ពផ្សាយនៃពាក្យស្នើសុំរហូតដល់ការផ្តល់សិទ្ធិ ។

**មាត្រា ៣១.–**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបោះពុម្ពផ្សាយព័ត៌មានចាំបាច់ពាក់ព័ន្ធទៅនឹងការការពារពូជថ្មីនៃដំណាំនៅក្នុងព្រឹត្តិបត្រផ្លូវការ ។

## ផ្នែកទី ៧
## បណ្តឹងជំទាស់ និង បណ្តឹងឧទ្ធរណ៍

**មាត្រា ៣២.–**

បុគ្គលដែលពាក់ព័ន្ធអាចដាក់ពាក្យប្តឹងជំទាស់ ចំពោះការការពារពូជថ្មីនៃដំណាំទៅកាន់មន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល ៣(បី)ខែ បន្ទាប់ពីលទ្ធផលនៃការពិនិត្យ ត្រូវបានបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ ។

**មាត្រា ៣៣.–**

បុគ្គលណាដែលមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជីក្នុងការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំ អាចធ្វើបណ្តឹងឧទ្ធរណ៍ចំពោះការសម្រេចនោះ ទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

CAMBODGE PALAIS ROYAL

## ផ្នែកទី ៨
## អាជ្ញាប័ណ្ណ និង អាជ្ញាប័ណ្ណបញ្ជា

**មាត្រា ៣៤.–**

អ្នកដាក់ពាក្យសុំការពារសិទ្ធិ ឬ ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ អាចប្រគល់ទៅឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គលផ្សេងទៀតនូវអាជ្ញាប័ណ្ណផ្តាច់មុខ ឬ អាជ្ញាប័ណ្ណមិនផ្តាច់មុខ ទាក់ទងទៅនឹងសិទ្ធិទាំងអស់ ឬ សិទ្ធិណាមួយ ដែលបានផ្តល់ជូនតាមច្បាប់នេះ ។

**មាត្រា ៣៥.–**

រូបវន្តបុគ្គល ឬ នីតិបុគ្គល អាចដាក់ពាក្យស្នើសុំមករដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យផ្តល់អាជ្ញាប័ណ្ណបញ្ជាក្នុងការប្រើប្រាស់ពូជថ្មីនៃដំណាំ ដោយផ្អែកលើមូលហេតុនៃភាពចាំបាច់ ដើម្បីការពារផលប្រយោជន៍សាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ អ្នកទទួលបានអាជ្ញាប័ណ្ណបញ្ជាស្របតាមមាត្រានេះ ត្រូវបង់ប្រាក់សំណងសមស្របទៅឱ្យម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ ។

## ផ្នែកទី ៩
## បទបញ្ជា និងការបង់កម្រៃ

**មាត្រា ៣៦.–**

បទបញ្ជានៃការអនុវត្តជំពូកទី ២ នៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣៧.–**

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលដាក់ពាក្យស្នើសុំវិញ្ញាបនបត្រសិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវបង់កម្រៃរដ្ឋបាលនៃការចុះបញ្ជី និងកម្រៃរក្សាសុពលភាពប្រចាំឆ្នាំនៃសិទ្ធិការ-ពារពូជថ្មីនៃដំណាំ នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលស្នើសុំការសិក្សាវាយតម្លៃលក្ខណៈបច្ចេកទេសពូជថ្មីនៃដំណាំ ត្រូវបង់កម្រៃសេវាកម្មបច្ចេកទេស នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

...ME du CAMBODGE • ...

កម្រៃរដ្ឋបាលពាក់ព័ន្ធក្នុងការចុះបញ្ជី កម្រៃរក្សាសុពលភាពប្រចាំឆ្នាំនៃសិទ្ធិការពារពូជថ្មីនៃដំណាំ និងកម្រៃសេវាកម្មបច្ចេកទេស ដែលមានចែងនៅក្នុងវាក្យខណ្ឌទី ១ និងវាក្យខណ្ឌទី ២ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ផ្នែកទី ១០
## ភ្នាក់ងារ

**មាត្រា ៣៨.-**

អ្នកបង្កាត់ពូជដំណាំ អាចដាក់ពាក្យស្នើសុំដោយខ្លួនឯង ឬ ភ្នាក់ងារ តំណាងមកដាក់ពាក្យស្នើសុំជំនួសខ្លួនបាន ។

ក្នុងករណីដែលមានទីលំនៅអចិន្ត្រៃយ៍ ឬ ទីតាំងប្រកបអាជីវកម្មរបស់អ្នកស្នើសុំស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជា អ្នកស្នើសុំនោះ ត្រូវមានភ្នាក់ងារតំណាងដែលមានទីលំនៅអចិន្ត្រៃយ៍ ឬ កំពុងប្រកបវិជ្ជាជីវៈ នៅព្រះរាជាណាចក្រកម្ពុជា ។

ភ្នាក់ងារតំណាង ដែលដាក់ពាក្យស្នើសុំចុះបញ្ជីពូជថ្មីនៃដំណាំក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងបំពេញបានលក្ខខណ្ឌ ដូចមានចែងក្នុងប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

## ជំពូកទី ៣
## ការគ្រប់គ្រងពូជដំណាំ
## ផ្នែកទី ១
## បញ្ជីពូជដំណាំរបស់ជាតិ

**មាត្រា ៣៩.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំឱ្យមានបញ្ជីពូជដំណាំរបស់ជាតិ ដែលមានទាំងពូជដែលមានស្រាប់ និងពូជថ្មីនៃដំណាំ ។

ROYAUME DU CAMBODGE

**មាត្រា ៤០.-**

ពូជដំណាំដែលមានស្រាប់ អាចចុះក្នុងបញ្ជីពូជដំណាំរបស់ជាតិបាន ត្រូវផ្អែកលើលក្ខខណ្ឌជាអាទិ៍ ដូចខាងក្រោម :

១-មានឈ្មោះសម្គាល់ជាក់លាក់ ដោយបង្ការកុំឱ្យភាន់ច្រឡំជាមួយប្រភេទពូជដំណាំមួយផ្សេងទៀតដែលបានចុះបញ្ជីរួចហើយ ឬ បង្ការកុំឱ្យយល់ខុសចំពោះចរិតលក្ខណៈនៃពូជដំណាំនោះ

២-រក្សាទុកឈ្មោះដើមរបស់ពូជដំណាំ ក្នុងករណីជាពូជនាំចូលពីបរទេស

៣-មានភាពខុសគ្នាពីពូជដំណាំ ដែលបានចុះបញ្ជីរួចហើយ

៤-មានឯកសណ្ឋានភាពគ្រប់គ្រាន់ខាងចរិតលក្ខណៈប្រកបដោយស្ថេរភាព និងអាចធ្វើអត្តសញ្ញាណកម្មពូជបាន

៥-មានទិន្នន័យសាកល្បងច្បាស់លាស់ ធានាដោយមន្ទីរពិសោធន៍អង្គភាពជំនាញ គ្រឹះស្ថានស្រាវជ្រាវសាធារណៈ ឬ ផ្នែកឯកជនធ្វើសេវាកម្មបច្ចេកទេសពូជដំណាំដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ផ្នែកទី ២
## វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ

**មាត្រា ៤១.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងផលិតពូជដំណាំសម្រាប់ផ្គត់ផ្គង់លក់ ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

គំរូពាក្យស្នើសុំ និង នីតិវិធីនៃការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាព ពូជដំណាំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

កម្រៃសេវាកម្មក្នុងការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ROYAUME DU CAMBODGE

## ផ្នែកទី ៣
## អាជីវកម្មពូជដំណាំ

**មាត្រា ៤២.-**

ការធ្វើអាជីវកម្មពូជដំណាំ ត្រូវមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការផ្ទេរសិទ្ធិទៅឱ្យបុគ្គលដទៃនូវលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មពូជដំណាំ ត្រូវមានការយល់ព្រមពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤៣.-**

មន្ទីរពិសោធន៍ពូជដំណាំ ដែលស្ថិតក្រោមកម្មវត្ថុធ្វើអាជីវកម្មពូជដំណាំ ត្រូវមានអ្នកបច្ចេកទេសជំនាញកសិក្រវិទ្យា ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤៤.-**

ហាមឃាត់ការចរាចរណ៍លើទីផ្សារនូវពូជដំណាំទាំងឡាយណាដែល :

១-មិនមានការវេចខ្ចប់ ការវេចខ្ចប់មិនបានត្រឹមត្រូវ ឬ ក្លែងបន្លំសំបកវេចខ្ចប់

២-ហួសរយៈពេលកំណត់នៃការប្រើប្រាស់

៣-មិនបានបំពេញត្រឹមត្រូវនូវព័ត៌មានបញ្ជាក់លើសំបកវេចខ្ចប់ ឬ ស្លាកសញ្ញា

៤-មិនមានស្លាកសញ្ញាស្របតាមការកំណត់ក្លែងបន្លំស្លាកសញ្ញា ឬ ខូចខាតស្លាកសញ្ញា ។

ព័ត៌មានបញ្ជាក់លើសំបកវេចខ្ចប់ ឬ ស្លាកសញ្ញា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ROYAUME DU CAMBODGE

## ផ្នែកទី ៤
## ការត្រួតពិនិត្យគុណភាពពូជដំណាំ

**មាត្រា ៤៥.-**

ពូជដំណាំ ដែលអនុញ្ញាតឱ្យធ្វើអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន ត្រូវតែជាពូជដំណាំមានគុណភាព និង ត្រូវឆ្លងកាត់ការធ្វើពិសោធន៍ ឬ ការដាំសាកល្បងដោយអង្គភាពជំនាញគ្រឹះស្ថានស្រាវជ្រាវសាធារណៈ ឬ ផ្នែកឯកជនធ្វើសេវាកម្មបច្ចេកទេសពូជដំណាំ ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤៦.-**

ការសិក្សាសាកល្បង ការយកសំណាក ការចាត់ថ្នាក់ ការកំណត់ស្តង់ដារគុណភាពពូជដំណាំ និង នីតិវិធីនៃការត្រួតពិនិត្យលើគុណភាពពូជដំណាំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤៧.-**

លទ្ធផលនៃការសាកល្បងពូជដំណាំណាដែលមិនបានបំពេញតាមលក្ខខណ្ឌនៃស្តង់ដារគុណភាពពូជដំណាំ ត្រូវធ្វើចំណាត់ថ្នាក់ជាថ្មីក្រោមការត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ពូជដំណាំនោះមិនអាចដាក់តាំងលក់ជាពូជបានឡើយ ។

**មាត្រា ៤៨.-**

អ្នកផលិតពូជដំណាំ និងអ្នកលក់ពូជដំណាំ ត្រូវទទួលខុសត្រូវចំពោះអ្នកប្រើប្រាស់នូវគុណភាពពូជដំណាំរបស់ខ្លួនទៅតាមព័ត៌មានដែលមានបញ្ជាក់លើសំបកវេចខ្ចប់ ឬស្លាកសញ្ញា ។

**មាត្រា ៤៩.-**

ក្នុងករណីអ្នកប្រើប្រាស់ពូជដំណាំមានមន្ទិលសង្ស័យពីការក្លែងបន្លំគុណភាពពូជដំណាំដែលបានទិញ អ្នកប្រើប្រាស់អាចស្នើសុំបញ្ជាក់ជាលាយល័ក្ខណ៍អក្សរពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការតវ៉ា ដែលទាក់ទងនឹងគុណភាពពូជដំណាំ ត្រូវធ្វើឡើងក្នុងរយៈពេល៣០(សាមសិប)ថ្ងៃក្រោយពេលទិញ តែមុនពេលយកទៅសាប បណ្ដុះ ឬ ដាំ ។ ការតវ៉ាទាក់ទងនឹងចរិតលក្ខណៈ ឬ ការប្រែប្រួលពន្ធុ ត្រូវធ្វើឡើងចាប់ពីពេលទិញរហូតដល់មុនពេលប្រមូលផល ។

នីតិវិធីដោះស្រាយការតវ៉ា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥០.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិព្យួរ ដកហូត ឬ លុបចោលលិខិតអនុញ្ញាតធ្វើអាជីវកម្ម និង វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ក្នុងករណីជាអាទិ៍ដូចខាងក្រោម :

១-លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញពីផលប៉ះពាល់ធ្ងន់ធ្ងរជាយថាហេតុដល់សុខភាពមនុស្ស សត្វ និង បរិស្ថាន បណ្ដាលមកពីឥទ្ធិពលនៃការប្រើប្រាស់ពូជដំណាំនោះ

២-ពូជដំណាំ ដែលបានធ្វើអាជីវកម្មមានគុណភាពខុសពីពូជដំណាំដែលបានបញ្ជាក់ក្នុងវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ឬ លើសំបកវេចខ្ចប់ ឬ ស្លាកសញ្ញា

៣-អ្នកកាន់លិខិតអនុញ្ញាតធ្វើអាជីវកម្ម និង វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំមិនគោរពតាមលក្ខខណ្ឌដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី ៤
## អាហរណកម្ម និហរណកម្ម និងការដឹកជញ្ជូនឆ្លងកាត់

### ផ្នែកទី ១
### អាហរណកម្ម និង និហរណកម្ម

**មាត្រា ៥១.-**

ការនាំចេញ នាំចូលពូជដំណាំ រួមទាំងការសាកល្បង ការសិក្សា និងការពិសោធត្រូវ

មានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការផ្ទេរសិទ្ធិទៅឱ្យបុគ្គលដទៃនូវលិខិតអនុញ្ញាតនាំចេញ នាំចូលពូជដំណាំ ត្រូវមានការយល់ព្រមជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥២.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលនាំចូលពូជដំណាំ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម :

១-ធ្វើប្រតិវេទន៍ទំនិញឱ្យបានត្រឹមត្រូវ

២-មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ចេញដោយសមត្ថកិច្ចនៃប្រទេសនាំចេញ

៣-មានលិខិតអនុញ្ញាតឱ្យនាំចូលពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៤-ជូនដំណឹងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យ៉ាងតិច ១០ (ដប់)ថ្ងៃនៃថ្ងៃធ្វើការ មុនពេលពូជដំណាំមកដល់ច្រកទ្វារនាំចូលនៃព្រំដែនព្រះរាជាណាចក្រកម្ពុជា

៥-បំពេញលក្ខខណ្ឌភូតគាមអនាម័យនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥៣.-**

ការនាំចូលពូជដំណាំដែលបង្កគ្រោះថ្នាក់ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវហាមឃាត់ដាច់ខាត ។

បញ្ជីឈ្មោះពូជដំណាំដែលបង្កគ្រោះថ្នាក់ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥៤.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវដកហូតលិខិតអនុញ្ញាត និង បញ្ឈប់ការនាំចេញ នាំចូលពូជដំណាំ ក្នុងករណីរកឃើញថាពូជដំណាំនោះមិនស្របតាមស្តង់ដារគុណភាពពូជដំណាំ ។

ROYAUME DU CAMBODGE

**មាត្រា ៥៥.-**

ផលិតផលដំណាំដែលបាននាំចូល ដើម្បីបម្រើឧស្សាហកម្ម ការប្រើប្រាស់ ឬ គោលបំណងផ្សេងៗទៀត មិនអនុញ្ញាតឱ្យយកទៅប្រើប្រាស់ជាពូជដំណាំបានឡើយ ។

**មាត្រា ៥៦.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលនាំចេញពូជដំណាំ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ៖

១-ធ្វើប្រតិវេទន៍ទំនិញឱ្យបានត្រឹមត្រូវ

២-ត្រូវមានលិខិតអនុញ្ញាតឱ្យនាំចេញពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

៣-ត្រូវជូនដំណឹងមកភ្នាក់ងារភូតគាមអនាម័យដែលនៅជិតបំផុត យ៉ាងតិច ១(មួយ)ថ្ងៃនៃថ្ងៃធ្វើការ មុនពេលពូជដំណាំមកដល់ច្រកទ្វារនាំចេញនៃព្រះរាជាណាចក្រកម្ពុជា

៤-មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ

៥-បំពេញលក្ខខណ្ឌភូតគាមអនាម័យនៃប្រទេសនាំចូល ។

**មាត្រា ៥៧.-**

ក្នុងករណីមានការចាំបាច់ ដើម្បីផលប្រយោជន៍ជាតិ ឬ សាធារណៈ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិអំណាចផ្អាកជាបណ្ដោះអាសន្ន ឬ ស្ថាពរ នូវការនាំចេញពូជដំណាំពីព្រះរាជាណាចក្រកម្ពុជា ។

## ផ្នែកទី ២
## ការដឹកជញ្ជូនឆ្លងកាត់

**មាត្រា ៥៨.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលដឹកជញ្ជូនពូជដំណាំឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ៖

១-ធ្វើប្រតិវេទន៍ទំនិញឱ្យបានត្រឹមត្រូវ

២-មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំចេញដោយសមត្ថកិច្ចនៃ

ប្រទេសនាំចេញ

៣-ត្រូវជូនដំណឹងយ៉ាងតិច ៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ មុនពេលពូជដំណាំមកដល់ច្រកទ្វារនាំចូល ដោយបញ្ជាក់កាលបរិច្ឆេទ និង ច្រកទ្វារនាំចេញមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៤-ធានាគុណភាពសុវត្ថិភាពនៃសំបកវេចខ្ចប់ មធ្យោបាយផ្ទុកពូជដំណាំ និងអនាម័យនៃមធ្យោបាយដឹកជញ្ជូន

៥-ពុំមានចម្លងមកជាមួយនូវសមាសភាពចង្រៃភូតគាមអនាម័យ និងបណ្តាសមាសភាពចង្រៃបង្កគ្រោះថ្នាក់ដទៃទៀតដែលអាចឆ្លងរាលដាលនៅតាមផ្លូវដឹកជញ្ជូនឆ្លងកាត់ ។

**មាត្រា ៥៩.-**

ក្នុងពេលដឹកជញ្ជូនឆ្លងកាត់ ប្រសិនបើមានរបើកស្លាកសុវត្ថិភាព ធ្លុះធ្លាយកុងតឺន័រ ឬ សម្ភារៈវេចខ្ចប់ ម្ចាស់ពូជដំណាំ ឬ អ្នកតំណាងទទួលខុសត្រូវ ត្រូវរាយការណ៍ជាបន្ទាន់មកភ្នាក់ងារភូតគាមអនាម័យដែលនៅជិតបំផុត និងសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចាត់វិធានការសមស្រប ។

**មាត្រា ៦០.-**

ភ្នាក់ងារភូតគាមអនាម័យ ត្រូវធ្វើការត្រួតពិនិត្យអនាម័យនៃមធ្យោបាយដឹកជញ្ជូន រួមទាំងផ្ទៃខាងក្រៅនៃមធ្យោបាយផ្ទុកទំនិញ និង វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំរបស់ប្រទេសនាំចេញ ព្រមទាំងលិខិតពាក់ព័ន្ធនានា ហើយត្រូវសម្រួលឱ្យការដឹកជញ្ជូនបន្តបានឆាប់រហ័ស ។

## ជំពូកទី ៥

## មូលនិធិជាតិអភិវឌ្ឍពូជដំណាំ

**មាត្រា ៦១.-**

រាជរដ្ឋាភិបាលអាចបង្កើតមូលនិធិមួយហៅថា " **មូលនិធិជាតិអភិវឌ្ឍពូជដំណាំ** " ដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីទ្រទ្រង់ដល់ការស្រាវជ្រាវ និងអភិវឌ្ឍពូជដំណាំក្នុង

ROYAUME du CAMBODGE

គោលដៅលើកកម្ពស់ផលិតភាពកសិកម្ម។

មូលនិធិជាតិអភិវឌ្ឍពូជដំណាំ ត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៦២.-**

មូលនិធិជាតិអភិវឌ្ឍពូជដំណាំ មានប្រភពចំណូលពី :

១-ថវិកាអំណោយ ឬវិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាលសម្រាប់គោលបំណងស្រាវជ្រាវ និង អភិវឌ្ឍពូជដំណាំ

២-អំណោយពីសប្បុរសជន សមាគម អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានា

៣-ប្រាក់ពិន័យអន្តរការណ៍លើបទល្មើសពូជដំណាំ

៤-កម្រៃសេវាកម្មផ្សេងៗក្នុងវិស័យពូជដំណាំ ។

ថវិកា និង រាល់ចំណូលរបស់មូលនិធិជាតិអភិវឌ្ឍពូជដំណាំ ត្រូវបង់ចូលគណនីមូលនិធិជាតិអភិវឌ្ឍពូជដំណាំ ។

**មាត្រា ៦៣.-**

មូលនិធិជាតិអភិវឌ្ឍពូជដំណាំ អាចប្រើប្រាស់បានចំពោះសកម្មភាពដូចខាងក្រោម :

១-ការស្រាវជ្រាវបច្ចេកវិទ្យាជម្រើសពូជ

២-ការពិសោធ ឬ ការសាកល្បងពូជដំណាំ និង ការបង្កាត់ពូជដំណាំ

៣-ការផ្សព្វផ្សាយ អប់រំ និងបណ្តុះបណ្តាលបច្ចេកវិទ្យាពូជដំណាំ

៤-ការចូលរួមជាសមាជិកអង្គការអន្តរជាតិ ឬ តំបន់ក្នុងវិស័យពូជដំណាំ ។

រាជរដ្ឋាភិបាល អាចកំណត់គោលការណ៍លើកទឹកចិត្តដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានស្នាដៃក្នុងការបង្កើត កែលម្អ និងនាំមកនូវធនធានពន្ធុក៏ដូចជាការខិតខំអភិរក្ស ផលិត បង្កាត់ ពិសោធ សាកល្បង ជ្រើសរើស ការបញ្ចេញឱ្យប្រើ និង កែច្នៃពូជដំណាំ ។

...IRE DU CAMBODGE ROYAL

## ជំពូកទី ៦
## ភ្នាក់ងារអធិការកិច្ចពូជដំណាំ

**មាត្រា ៦៤.-**

ភ្នាក់ងារអធិការកិច្ចពូជដំណាំនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានសមត្ថកិច្ច និង បំពេញតួនាទីជាមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ។

បែបបទ និង នីតិវិធីនៃការផ្តល់នីតិសម្បទា ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានចែងក្នុងមាត្រា ៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៦៥.-**

ភ្នាក់ងារអធិការកិច្ចពូជដំណាំ មានភារកិច្ច និងសិទ្ធិដូចខាងក្រោម :

១-តាមដាន និង ត្រួតពិនិត្យជាប្រចាំនូវការធ្វើអាជីវកម្មគ្រប់រូបភាពនិង គ្រប់សកម្មភាពពាក់ព័ន្ធពូជដំណាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា

២-ធ្វើអធិការកិច្ចគ្រប់ទីតាំងអាជីវកម្មពូជដំណាំគ្រប់ប្រភេទ ឃ្លាំងស្តុក រោងចក្រ សហគ្រាស រួមទាំងកសិដ្ឋានដែលពាក់ព័ន្ធ ឬ សង្ស័យថាបានប្រព្រឹត្តល្មើសនឹងច្បាប់នេះ

៣-ដកយកសំណាកពូជដំណាំទាំងឡាយណា ដែលបានសង្ស័យថាល្មើសនឹងច្បាប់នេះ ដើម្បីធ្វើការពិសោធ

៤-តម្រូវឱ្យអាជីវករបង្ហាញនូវលិខិតអនុញ្ញាតពាក់ព័ន្ធ ឬ ឯកសារផ្សេងៗពាក់ព័ន្ធការធ្វើអាជីវកម្មពូជដំណាំ

៥-ដកហូតជាបណ្តោះអាសន្ននូវរាល់លិខិតអនុញ្ញាតគ្រប់ប្រភេទ ឬឯកសារពាក់ព័ន្ធ ក្នុងករណីអ្នកកាន់កាប់លិខិតអនុញ្ញាតនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ

៦-ក្នុងករណីបទល្មើសជាក់ស្តែង មានសិទ្ធិឃាត់ ឬ បញ្ឈប់មធ្យោបាយដឹកជញ្ជូន ឬ មធ្យោបាយផ្ទុកពូជដំណាំ ដើម្បីត្រួតពិនិត្យ និង ឃាត់ទុកជាបណ្តោះអាសន្ននូវវត្ថុតាងនៃបទល្មើស និង មធ្យោបាយ ដើម្បីធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញា ។

ROYAUME DU CAMBODGE ROYAL

**មាត្រា ៦៦.–**

ភ្នាក់ងារភូតគាមអនាម័យមានសមត្ថកិច្ច មានសិទ្ធិចូលរួមបំពេញភារកិច្ចនៅតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៦៧.–**

អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ ស្ថាប័នគយ និង រដ្ឋាករ ស្ថាប័នព្រលានយន្តហោះ កំពង់ផែ និង អាជ្ញាធរពាក់ព័ន្ធដទៃទៀត ជួយសហការក្នុងការស្រាវជ្រាវ ទប់ស្កាត់ និង បង្ក្រាបបទល្មើសពូជដំណាំ ឬ ថែរក្សាវត្ថុតាងបទល្មើសពូជដំណាំជាបណ្តោះអាសន្ន ក្នុងករណីមានការស្នើសុំពីភ្នាក់ងារអធិការកិច្ចពូជដំណាំ ។

**មាត្រា ៦៨.–**

នៅពេលបំពេញបេសកកម្ម ភ្នាក់ងារអធិការកិច្ចពូជដំណាំ ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់ និង ត្រូវមានលិខិតបញ្ជាបេសកកម្ម ។

ឯកសណ្ឋាន និង សញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

### ផ្នែកទី ១

### បទល្មើសលើការការពារពូជថ្មីនៃដំណាំ

**មាត្រា ៦៩.–**

រាល់វិវាទ ដែលបានកើតឡើងពាក់ព័ន្ធទៅនឹងការអនុវត្តជំពូកទី ២ និង បទបញ្ញាទាំងឡាយ ត្រូវប្តឹងទៅមន្ត្រីកាន់កាប់បញ្ជីការពារពូជថ្មីនៃដំណាំ ។

មន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តល់ឱកាសសម្រាប់សវនាការដល់ភាគីនៃបណ្តឹង នៅចំពោះមុខខ្លួន មុនពេលអនុវត្តអំណាចឆន្ទានុសិទ្ធិដែលបានប្រគល់ឱ្យដោយច្បាប់នេះ និងដោយបទបញ្ជាទាំងឡាយចំពោះភាគី ។

**មាត្រា ៧០.-**

ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ អាចប្តឹងទៅតុលាការមានសមត្ថកិច្ចឱ្យជួសជុលសំណងតាមនីតិវិធី ដូចខាងក្រោម ៖

-ធ្វើបណ្តឹងរដ្ឋប្បវេណី ឬ ស្នើសុំដីកាបណ្តោះអាសន្ន ដើម្បីហាមឃាត់ការប្រព្រឹត្ត ឬ ការបន្តការប្រព្រឹត្តអំពើរំលោភបំពានលើសិទ្ធិអ្នកបង្កាត់ពូជដំណាំ

-ស្នើសុំការដាក់ពិន័យ ការរឹបអូស ឬ ការបំផ្លាញចោលពូជដំណាំ ដែលបានផលិតល្មើសលើសិទ្ធិអ្នកបង្កាត់ពូជដំណាំ និង

-ស្នើសុំឱ្យសងការខូចខាតជាទឹកប្រាក់ ។

**មាត្រា ៧១.-**

បុគ្គលណាមួយដែលផ្តល់ព័ត៌មានមិនពិតនៅក្នុងឯកសារ ដែលដាក់សុំការពារពូជថ្មីនៃដំណាំ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន) រៀលទៅ ៥.០០០.០០០(ប្រាំលាន)រៀល ឬ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ ៦(ប្រាំមួយ)ខែ ឬ ត្រូវផ្តន្ទាទោសទាំងពីរខាងលើ ។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

**មាត្រា ៧២.-**

បុគ្គលណាមួយដែលរំលោភដោយចេតនាលើសិទ្ធិការពារពូជថ្មីនៃដំណាំដូចមានចែងក្នុងមាត្រា ១៥ ជំពូកទី ២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២០.០០០.០០០(ម្ភៃលាន)រៀល ឬ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ ឬ ត្រូវផ្តន្ទាទោសទាំងពីរខាងលើ ។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

**មាត្រា ៧៣.-**

ក្នុងករណីបុគ្គលណាមួយ ត្រូវបានផ្តន្ទាទោសតាមបញ្ញត្តិនៃផ្នែកនេះ តុលាការមានសមត្ថកិច្ច អាចបញ្ជាឱ្យធ្វើការរឹបអូសទុកជាសម្បត្តិរដ្ឋ ឬ បំផ្លាញចោលនូវពូជដំណាំដែលរំលោភបំពាន វត្ថុតាង និង សម្ភារៈឧបករណ៍ ដែលយកមកប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ។

## ផ្នែកទី ២

## បទល្មើសលើអាជីវកម្មពូជដំណាំ

**មាត្រា ៧៤.-**

ទណ្ឌកម្មក្នុងបទល្មើសអាជីវកម្មពូជដំណាំមាន : ពិន័យអន្តរការណ៍ ការឃាត់ទុកវត្ថុតាង ការរឹបអូសវត្ថុតាង ការបំផ្លាញវត្ថុតាង ការតម្រូវឱ្យជួសជុលការខូចខាត ការដកហូត ឬ ព្យួរលិខិតអនុញ្ញាតធ្វើអាជីវកម្ម លិខិតអនុញ្ញាតនាំចូល-នាំចេញពូជដំណាំ វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ទោសពិន័យ និង ទោសដាក់ពន្ធនាគារ ។

ការពិន័យអន្តរការណ៍លើបទល្មើសពូជដំណាំ ការឃាត់ទុកវត្ថុតាង ការដកហូត ឬព្យួរលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម លិខិតអនុញ្ញាតនាំចូល-នាំចេញពូជដំណាំ និងវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ជាសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

ក្នុងករណីជនល្មើសមិនព្រមអនុវត្តតាមការសម្រេចរបស់សមត្ថកិច្ច ដូចមានចែងក្នុងវាក្យខណ្ឌទី ២ នៃមាត្រានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវបញ្ជូនសំណុំរឿងប្តឹងទៅតុលាការ ។

ការរឹបអូស និង បំផ្លាញវត្ថុតាង ការជួសជុលលើការខូចខាត ទោសពិន័យ និងទោសដាក់ពន្ធនាគារ ជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៧៥.-**

បែបបទនៃការពិន័យអន្តរការណ៍ និង តម្លៃទីផ្សារពូជដំណាំជាមូលដ្ឋានសម្រាប់

អនុវត្តការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៧៦.-**

ប្រាក់ពិន័យសម្រាប់ផ្តល់ជារង្វាន់លើកទឹកចិត្តដល់អ្នកមានស្នាដៃបង្ក្រាបបទល្មើស និងកម្រិតកំណត់សម្រាប់មូលនិធិជាតិអភិវឌ្ឍពូជដំណាំ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៧៧.-**

អ្នកកាន់កាប់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម លិខិតអនុញ្ញាតឱ្យនាំចេញ-នាំចូលពូជដំណាំណា ដែលផ្ទេរសិទ្ធិទៅឱ្យបុគ្គលដទៃ ដោយគ្មានការយល់ព្រមជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលពិន័យព្យួរលិខិតអនុញ្ញាតឱ្យ នោះក្នុងរយៈពេលមួយឆ្នាំ ។

ក្នុងករណីមិនរាងចាល ត្រូវដកហូតជាស្ថាពរនូវលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ឬ លិខិតអនុញ្ញាតនាំចេញ-នាំចូលពូជដំណាំ និងត្រូវពិន័យអន្តរការណ៍ស្របតាមមាត្រា ៧៨ នៃច្បាប់នេះ ។

**មាត្រា ៧៨.-**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនពី ៥០០.០០០(ប្រាំសែន)រៀល ទៅ ៥.០០០.០០០(ប្រាំលាន)រៀល ចំពោះបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម:

១-មិនធ្វើនិយតកម្មស្របតាមច្បាប់នេះនូវពូជដំណាំ ដែលបានចុះបញ្ជីក្រោមបទប្បញ្ញត្តិនានាក្នុងរយៈពេល៦ខែ (ប្រាំមួយខែ) ក្រោយច្បាប់នេះចូលជាធរមាន

២-គ្មានអ្នកបច្ចេកទេសជំនាញក្សេត្រវិទ្យា ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំការនៅមន្ទីរពិសោធន៍ពូជដំណាំរបស់ខ្លួន

៣-ធ្វើការនាំចេញ នាំចូល ឬ ដឹកជញ្ជូនពូជដំណាំឆ្លងកាត់ដោយ:

ROYAUME DU CAMBODGE

-មិនធ្វើប្រតិវេទន៍ទំនិញឱ្យ បានត្រឹមត្រូវ

-មិនជូនដំណឹងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-មិនរាយការណ៍ជាបន្ទាន់មកភ្នាក់ងារភូតគាមអនាម័យក្នុងពេលដឹកជញ្ជូនឆ្លងកាត់មានរបើកស្លាកសុវត្ថិភាព ធ្លុះធ្លាយកុងតឺន័រ ឬ សម្ភារៈវេចខ្ចប់ ដើម្បីចាត់វិធានការសមស្រប

-មិន បានបំពេញលក្ខខណ្ឌភូតគាមអនាម័យ

-មិនមានការវេចខ្ចប់ត្រឹមត្រូវ ឬ ខូចខាតសម្ភារៈវេចខ្ចប់ ឬ ស្លាកសញ្ញា។

ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ទ្វេដង ឬ បញ្ជូនសំណុំរឿងទៅតុលាការ ។

**មាត្រា ៧៩.-**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួន ២(ពីរ)ដង នៃតម្លៃវត្ថុតាងពិតប្រាកដលើទីផ្សារ ចំពោះបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-ធ្វើអាជីវកម្មពូជដំណាំ ឬ នាំចូលពូជដំណាំដើម្បីធ្វើការសិក្សាពិសោធដោយគ្មានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២-ធ្វើអាជីវកម្មពូជដំណាំ ដោយគ្មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ

៣-យកផលិតផលដែលបាននាំចូល ដើម្បីបម្រើឧស្សាហកម្ម ការប្រើប្រាស់ ឬ គោលបំណងផ្សេងៗទៀតទៅប្រើប្រាស់ជាពូជដំណាំ ឬ កែច្នៃ ដើម្បីប្រើប្រាស់ជាពូជដំណាំ

៤-ធ្វើការនាំចេញ ឬ នាំចូលពូជដំណាំដោយ :

-គ្មានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-គ្មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ។

៥-ធ្វើការដឹកជញ្ជូនឆ្លងកាត់ ដោយគ្មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំចេញដោយសមត្ថកិច្ចនៃប្រទេសនាំចេញ

៦-ធ្វើអាជីវកម្ម ឬ ចរាចរលើទីផ្សារនូវពូជដំណាំដែល :

-ពុំមានគុណភាពទៅតាមព័ត៌មាន ដែលមានចែងលើសំបកវេចខ្ចប់ ឬ ស្លាកសញ្ញា

-ហួសរយៈពេលកំណត់នៃការប្រើប្រាស់

-មិនមានស្លាកសញ្ញា ស្របតាមការកំណត់ ។

ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ទ្វេដង និងត្រូវដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្ម លិខិតអនុញ្ញាតនាំចេញ-នាំចូល ឬវិញ្ញាបនបត្របញ្ជាក់គុណភាពដំណាំ ឬបញ្ជូនសំណុំរឿងទៅតុលាការ ។

**មាត្រា ៨០.—**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និង ត្រូវពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន)រៀល ទៅ១០.០០០.០០០ (ដប់លាន)រៀល ឬ ត្រូវផ្តន្ទាទោសណាមួយនៃទោសទាំងពីរ និងត្រូវដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ បំផ្លាញចោលវត្ថុតាង ឬរឹបអូសវត្ថុតាងទាំងអស់មកជាសម្បត្តិរដ្ឋ ចំពោះបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសណាមួយ ដូចខាងក្រោម៖

១-នាំចូលពូជដំណាំចង្រៃបង្កគ្រោះថ្នាក់មកក្នុងព្រះរាជាណាចក្រកម្ពុជា

២-នាំចេញពូជដំណាំ ដោយបំពានបម្រាមរបស់រដ្ឋនៅពេលដែលព្រះរាជាណាចក្រកម្ពុជាមានតម្រូវការជាចាំបាច់

៣-ក្លែងបន្លំគុណភាពពូជដំណាំ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ដោយពុំទាន់គិតពីការទទួលខុសត្រូវរដ្ឋប្បវេណីថែមទៀត ក្នុងករណីមានផលប៉ះពាល់ដល់សុខភាពសាធារណៈ ឬ ខូចខាតកេរ្តិ៍ប្រពៃណី ឬ សាសនា ។

## ផ្នែកទី ៣
## បទល្មើសដោយមន្ត្រីអនុវត្តច្បាប់

**មាត្រា ៨១.—**

ភ្នាក់ងារអធិការកិច្ច ឬ មន្ត្រីបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬ មិនគោរពបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាល និង/ ឬចោទប្រកាន់ចំពោះមុខតុលាការ ។

ភ្នាក់ងារអធិការកិច្ច ឬ មន្ត្រីបណាដែលសមគំនិតនិងអ្នកប្រព្រឹត្តបទល្មើស ឬ ជួយសម្រួលដល់ការប្រព្រឹត្តបទល្មើសនេះ ត្រូវផ្តន្ទាទោសដូចចារីដែរ ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា ៨២.–**

ពូជដំណាំ ដែលទទួលបានវិញ្ញាបនបត្របញ្ជាក់គុណភាព និង លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មពូជដំណាំក្រោមបទប្បញ្ញត្តិផ្សេងៗ ត្រូវធ្វើនិយតកម្មស្របតាមច្បាប់នេះក្នុងរយៈពេលមិនលើសពី ៦(ប្រាំមួយ)ខែ គិតចាប់ពីកាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ៨៣.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨៤.–**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម.០៥០៨.០១៣ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
**ហត្ថលេខា**
**ច័ន្ទ សារុន**

លេខៈ ៤៩៥ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០០៨
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**ស៊ុន ចិនកេន**

# ឧបសម្ព័ន្ធ

## វាក្យស័ព្ទ

**ក-ការកែច្នៃពូជដំណាំ:** (Seed Processing)

សំដៅដល់ការសម្ងួត ការសម្អាត ប្រព្រឹត្តកម្ម និង ការវេចខ្ចប់ពូជដំណាំសម្រាប់ធ្វើការលក់ដូរ ។

**ខ-ការដឹកជញ្ជូនឆ្លងកាត់:** (Transit)

សំដៅដល់ការដឹកជញ្ជូនពូជដំណាំឆ្លងកាត់ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ការដឹកជញ្ជូនឆ្លងកាត់នេះ មិនរាប់បញ្ចូលនូវការរើទំនិញ ការឈប់ ដើម្បីដាក់ទំនិញចូលក្នុងឃ្លាំង ការបើកសម្ភារៈវេចខ្ចប់ទំនិញ ឬ ការផ្លាស់ប្តូរមធ្យោបាយដឹកជញ្ជូនឡើយ ។

**គ-ការត្រួតពិនិត្យពូជដំណាំ:** (Seed Inspection)

សំដៅដល់ការត្រួតពិនិត្យគុណភាព និងការយកសំណាកពូជដំណាំមកវិភាគ ការស្រាវជ្រាវ ការរុករក និង ការបង្ក្រាបបទល្មើស ។

**ឃ-ការសាកល្បង:** (Seed Testing)

សំដៅដល់ការងារពិសោធន៍តាមដាននៅក្នុងថ្នាលពិសោធន៍ និងវិភាគ គុណភាពពូជដំណាំ នៅក្នុងមន្ទីរពិសោធន៍ ។

**ង-ការបញ្ចេញឱ្យប្រើ:** (Release)

សំដៅដល់ការដល់រំដោះពូជដំណាំ ដើម្បីដាក់ឱ្យប្រើប្រាស់ជាសាធារណៈ ក្រោយពីបានយល់ព្រមពីគណៈកម្មការវាយតម្លៃបច្ចេកទេស ។

**ច-កុងតឺន័រ:** (Container)

សំដៅដល់ឧបករណ៍សម្រាប់ផ្ទុកទំនិញសម្រាប់ការដឹកជញ្ជូន ។

**ឆ-គុណភាពពូជដំណាំ:** (Seed Quality)

សំដៅដល់លក្ខណៈវិនិច្ឆ័យបច្ចេកទេសនៃពូជដំណាំ ដែលមានជាអាទិ៍: កម្រិតសំណើម



កម្រិតតដំណុះ ភាពសុទ្ធ សុខភាពពូជដំណាំ ។ល។

**ជ-ចរាចរណ៍ពូជដំណាំ: (Seed Marketing)**

សំដៅដល់ការទិញ-លក់ ការចែកចាយ និង ការស្តុកពូជដំណាំ ។

**ឈ-នាយកដ្ឋានចុះបញ្ជីពូជថ្មីនៃដំណាំ: (Registration Department)**

សំដៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ញ-ពន្ធុ: (Gene)**

សំដៅដល់ក្រុមនៃក្រូម៉ូសូម ដែលជាឯកតាបន្តពូជអាចបញ្ជូនព័ត៌មានតំណពូជពីជំនាន់មួយទៅជំនាន់មួយក្រោយទៀត ឬ ពីមេបាទៅកូន ។

**ដ-ពូជ: (Variety)**

សំដៅដល់រាល់ប្រភេទពូជដំណាំ ឬ ក្រុមផ្សេងៗនៃប្រភេទពូជដំណាំណាមួយដែលមានលក្ខណៈដូចគ្នា និង ធ្វើឱ្យឃើញថាប្លែកពីរុក្ខជាតិដទៃទៀតក្នុងប្រភេទពូជដំណាំតែមួយក្នុងលក្ខណៈមួយ ឬ ច្រើន ហើយដែលលក្ខណៈទាំងនេះនៅតែអាចរក្សាបាន ដើម្បីយកទៅប្រើប្រាស់ធ្វើជាពូជដំណាំបាន ឬ ការបង្កាត់ដោយសរីរាង្គដទៃទៀត ។

**ឋ-ពូជដំណាំ: (Seed)**

សំដៅដល់រាល់មេជីវិតបន្តពូជ (អំប្រ៊ីយ៉ុងពេញវ័យ) ដែលមានបំណែកអំព្រីយ៉ុង សារធាតុចិញ្ចឹម និងសំបកការពារគ្រាប់ពូជ ឬ សរីរាង្គដាំដុះមួយដែលត្រូវបានយកទៅប្រើប្រាស់ក្នុងការសាប ការបណ្តុះ ឬ ការដាំសម្រាប់ផលិតកម្មដំណាំ ទោះបីជាការបន្តពូជនោះធ្វើឡើងដោយភេទក្តី ឬ អភេទក្តី ។ ដោយរួមបញ្ចូលនូវរាល់ចំណាត់ថ្នាក់នៃគ្រាប់ពូជដំណាំ ឬសរីរាង្គបន្តពូជ(ក្នុងនោះមានពូជដំណាំស្បៀង ដំណាំឧស្សាហកម្ម ដំណាំប្រេង ដំណាំចំណីសត្វ ឬ ផ្កា និងដំណាំលម្អនានា) និងរួមបញ្ចូលនូវកូនបណ្តុះ ឬ សំណាប ដើម ឬស បំណែករុក្ខជាតិ សរីរាង្គផ្សាំរុក្ខជាតិ ដែលបង្កាត់ដោយលក្ខណៈមីក្រូ និង រាល់បណ្តាសរីរាង្គបង្កាត់ដោយលក្ខណៈសរីរាង្គ ។

**ឌ-ពូជដំណាំដែលមានស្រាប់:** (Existing Variety)

សំដៅដល់ពូជដំណាំទាំងឡាយដែលកំពុងត្រូវបានប្រើប្រាស់ និង ធ្វើអាជីវកម្មទូទៅ ដោយពុំមានកម្មសិទ្ធិរបស់នរណាម្នាក់ ។

**ឍ-ពូជថ្មីនៃដំណាំ:** (New Variety)

សំដៅដល់ពូជដំណាំទាំងឡាយ ដែលទើបនឹងរកឃើញ និង អភិវឌ្ឍថ្មីៗ ដោយរុក្ខជម្រើសវិទូ ឬ អ្នកបង្កាត់ពូជដំណាំ និងកាន់កាប់ផ្តាច់មុខយ៉ាងទូលំទូលាយក្នុងរយៈពេលមួយជាក់លាក់ ដែលកំណត់ដោយច្បាប់នេះ ។

**ណ-ភាគីហត្ថលេខី:** (Contracting Party)

សំដៅប្រទេស ឬ អង្គការអន្តរជាតិ ដែលជាភាគីនៃអនុសញ្ញាសហព័ន្ធអន្តរជាតិការពារពូជថ្មីនៃដំណាំ ហៅកាត់ថាយូប៉ុវ (UPOV) ។

**ត-មន្ត្រីកាន់កាប់បញ្ជី:** (Registrar)

សំដៅប្រធាននាយកដ្ឋានចុះបញ្ជីនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ថ-លក្ខខណ្ឌភូតគាមអនាម័យ:** (Phytosanitary Condition)

សំដៅដល់លក្ខខណ្ឌទាមទាររបស់សមត្ថកិច្ចភូតគាមអនាម័យនៃប្រទេសនីមួយៗ ដើម្បីបង្ការទប់ស្កាត់ការឆ្លងរាលដាលចូលមកក្នុងព្រះរាជាណាចក្រកម្ពុជានូវសមាសភាពចង្រៃតាមសកម្មភាពនាំចូលនូវទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ។

**ទ-វិញ្ញាបនបត្របញ្ជាក់សិទ្ធិការពារពូជថ្មីនៃដំណាំ :(Certificate for New Plant Variety Protection)**

សំដៅដល់លិខិតបញ្ជាក់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ដែលផ្តល់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលនូវសិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំ និងចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ធ-វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ: (Certificate for Seed Quality)**

សំដៅដល់លិខិតបញ្ជាក់ពីគុណភាពពូជដំណាំ ហើយផ្តល់ជូនរូបវន្តបុគ្គល ឬ នីតិ-

បុគ្គល ក្រោមកម្មវត្ថុធ្វើអាជីវកម្មពូជដំណាំ និង ចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ន-សមាសភាពចង្រៃ:** (Pest)

សំដៅដល់គ្រប់សត្វ និង រុក្ខជាតិ ទោះជាងាប់ ឬ រស់ក៏ដោយឱ្យតែក្នុងដំណាក់កាលលូតលាស់ណាមួយ វាអាចបង្កគ្រោះថ្នាក់ ឬ បំផ្លាញដំណាំ ។ សមាសភាពចង្រៃទាំងនោះ រាប់បញ្ចូលសត្វល្អិត ចៃ កណ្តុរ ខ្យង បក្សី សារីរៈ ដែលបង្កជំងឺដល់ដំណាំ និងស្មៅចង្រៃ ។

**ប-ស្លាកសុវត្ថិភាព:** (Safety Seal)

សំដៅដល់សំណាបិទភ្ជិត ដើម្បីធានាថា ទំនិញនៅក្នុងខ្ចប់ថែនណីមានសុវត្ថិភាព ឬ ពុំមានការប៉ះពាល់ធ្វើឱ្យខុសភាពដើម ។

**ផ-ស្តង់ដារ:** (Standard)

សំដៅដល់ខ្នាតគំរូមួយ ដែលត្រូវបានកំណត់ដោយច្បាប់នេះ ដើម្បីកំណត់គុណភាពពូជដំណាំ ។

**ព-ភ្នាក់ងារអធិការកិច្ចពូជដំណាំ:** (Seed Inspector)

សំដៅដល់អង្គភាពទទួលបន្ទុកការងារគ្រប់គ្រង និង ត្រួតពិនិត្យគុណភាពពូជដំណាំ ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ រួមមាននាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម និងការិយាល័យក្សេត្រសាស្ត្រ និងកែលំអដីកសិកម្មខេត្ត-ក្រុង ។

**ភ-អាជីវកម្មពូជដំណាំ:** (Seed Bussines)

សំដៅដល់ការផលិត ការកែច្នៃ ការបណ្តុះកូនដំណាំ ការនាំចេញ-នាំចូល និងចរាចរណ៍ពូជដំណាំ ។

**ម-អ្នកបង្កាត់ពូជ ឬ អ្នកជម្រើសទិន្ន:** (Plant Breeder)

សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលធ្វើការអភិរក្ស អភិវឌ្ឍ ឬ បង្កាត់ ពិសោធសាកល្បង ជ្រើសរើស និង រំដោះពូជដំណាំ និងរុក្ខជាតិ ដើម្បីបុព្វហេតុបសិដ្ឋកម្មពូជដំណាំ ស្បៀង និង កសិកម្មប្រកបដោយនិរន្តរភាព ។

# ឧបសម្ព័ន្ធទី២
# អនុសញ្ញាអន្តរជាតិ ស្តីពី កិច្ចការពារពូជ
# ថ្មីនៃដំណាំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អនុសញ្ញាអន្តរជាតិ
# ស្តីពី
# កិច្ចការពារពូជថ្មីនៃដំណាំ

## INTERNATIONAL CONVENTION
## FOR THE PROTECTION OF NEW VARIETIES OF PLANTS


បោះពុម្ពដោយ
ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
អគ្គនាយកដ្ឋានឧស្សាហកម្ម
នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម




UPOV

ការិយាល័យប្រភេទថ្មីនៃរុក្ខជាតិ និងជម្រុញការច្នៃប្រឌិត និងតក្កកម្ម

# អនុសញ្ញាអន្តរជាតិ ស្តីពី កិច្ចការពារពូជថ្មីនៃដំណាំ
ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៦១
កែប្រែនៅទីក្រុងហ្សឺណែវ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧២
ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៧៨ និងចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩១

## បញ្ជីមាត្រា


ជំពូកទី១ : និយមន័យ
មាត្រា១ : និយមន័យ

ជំពូកទី២ : កាតព្វកិច្ចទូទៅ នៃភាគីហត្ថលេខី
មាត្រា២ : កាតព្វកិច្ចជាមូលដ្ឋាននៃភាគីហត្ថលេខី
មាត្រា៣ : អំបូរ និងប្រភេទពូជដែលត្រូវការពារ
មាត្រា៤ : ប្រព្រឹត្តិកម្មជាតិ

ជំពូកទី៣ : លក្ខខណ្ឌសម្រាប់ការផ្តល់សិទ្ធិដល់អ្នកបង្កាត់ពូជដំណាំ
មាត្រា៥ : លក្ខខណ្ឌដើម្បីការពារ
មាត្រា៦ : ភាពថ្មី
មាត្រា៧ : ភាពខុសប្លែក
មាត្រា៨ : ឯកសណ្ឋានភាព
មាត្រា៩ : ស្ថេរភាព

ជំពូកទី ៤ : ការដាក់ពាក្យស្នើសុំសម្រាប់ការផ្តល់សិទ្ធិដល់អ្នកបង្កាត់ពូជដំណាំ

មាត្រា១០ : ការដាក់ពាក្យស្នើសុំ
មាត្រា១១ : សិទ្ធិអាទិភាព
មាត្រា១២ : ការត្រួតពិនិត្យពាក្យស្នើសុំ
មាត្រា១៣ : កិច្ចការពារបណ្ដោះអាសន្ន

**ជំពូកទី ៥ : សិទ្ធិអ្នកបង្កាត់ពូជដំណាំ**
មាត្រា១៤ : វិសាលភាព នៃសិទ្ធិអ្នកបង្កាត់ពូជដំណាំ
មាត្រា១៥ : ការលើកលែងចំពោះសិទ្ធិអ្នកបង្កាត់ពូជដំណាំ
មាត្រា១៦ : ការរលត់សិទ្ធិអ្នកបង្កាត់ពូជដំណាំ
មាត្រា១៧ : ការកម្រិតការអនុវត្តន៍សិទ្ធិអ្នកបង្កាត់ពូជដំណាំ
មាត្រា១៨ : វិធានការគ្រប់គ្រងពាណិជ្ជកម្ម
មាត្រា១៩ : រយៈពេលការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ

**ជំពូកទី ៦ : ការដាក់ឈ្មោះពូជដំណាំ**
មាត្រា២០ : ការដាក់ឈ្មោះពូជដំណាំ

**ជំពូកទី ៧ : មោឃភាព និងការលុបចោលសិទ្ធិអ្នកបង្កាត់ពូជដំណាំ**
មាត្រា២១ : មោឃភាពសិទ្ធិអ្នកបង្កាត់ពូជដំណាំ
មាត្រា២២ : ការលុបចោលសិទ្ធិអ្នកបង្កាត់ពូជដំណាំ

**ជំពូកទី ៨ : សហភាព**
មាត្រា២៣ : សមាជិក
មាត្រា២៤ : ឋានៈផ្លូវច្បាប់ និងអាសនៈ
មាត្រា២៥ : អង្គភាព
មាត្រា២៦ : ក្រុមប្រឹក្សា

មាត្រា២៧ : ការិយាល័យនៃសហភាព
មាត្រា២៨ : ភាសា
មាត្រា២៩ : ហិរញ្ញវត្ថុ

ជំពូកទី ៩ : ការអនុវត្តន៍អនុសញ្ញា កិច្ចព្រមព្រៀងផ្សេងៗទៀត
មាត្រា៣០ : ការអនុវត្តន៍អនុសញ្ញា
មាត្រា៣១ : ទំនាក់ទំនងរវាងភាគីហត្ថលេខីនិងរដ្ឋដែលចងភ្ជាប់ដោយច្បាប់មុនៗ
មាត្រា៣២ : កិច្ចព្រមព្រៀងពិសេស

ជំពូកទី ១០ : អវសានប្បញ្ញត្តិ
មាត្រា៣៣ : ការចុះហត្ថលេខា
មាត្រា៣៤ : ការផ្តល់សច្ចាប័ន ការទទួលយក ឬការយល់ព្រម ការចូលជាសមាជិក
មាត្រា៣៥ : ខដាក់លក្ខខណ្ឌ
មាត្រា៣៦ : ទំនាក់ទំនងចំពោះច្បាប់ អំបូរ និងប្រភេទពូជដែលបានការពារ ព័ត៌មានដែលត្រូវបោះពុម្ពផ្សាយ
មាត្រា៣៧ : ការចូលជាធរមាន ការបិទច្បាប់មុនៗ
មាត្រា៣៨ : ការកែប្រែអនុសញ្ញា
មាត្រា៣៩ : ការប្រកាសដកខ្លួនចេញ
មាត្រា៤០ : ការរក្សាសិទ្ធិដែលមាន
មាត្រា៤១ : អត្ថបទដើម និងអត្ថបទផ្លូវការនៃអនុសញ្ញា
មាត្រា៤២ : តួនាទីនៃការតម្កល់

# ជំពូកទី១
# និយមន័យ

## មាត្រា ១
## និយមន័យ

សម្រាប់គោលបំណងនៃច្បាប់នេះ :

(i) "អនុសញ្ញា " សំដៅដល់ច្បាប់បច្ចុប្បន្ន (១៩៩១) នៃអនុសញ្ញាអន្តរជាតិ ស្តីពីកិច្ចការពារពូជថ្មីនៃដំណាំ

(ii) "ច្បាប់ឆ្នាំ១៩៦១/១៩៧២ " សំដៅដល់ អនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារពូជថ្មីនៃដំណាំចុះថ្ងៃទី២ ខែ ធ្នូ ឆ្នាំ១៩៦១ ដូចដែលបានធ្វើវិសោធនកម្មដោយច្បាប់បន្ថែម ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ១៩៧២

(iii) "ច្បាប់ឆ្នាំ១៩៧៨ " សំដៅដល់ច្បាប់ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ ១៩៧៨ នៃអនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារពូជថ្មីនៃដំណាំ

(iv) " អ្នកបង្កាត់ពូជដំណាំ "សំដៅដល់:

- បុគ្គលដែលបង្កាត់ឬរកឃើញនិងអភិវឌ្ឍពូជដំណាំ
- បុគ្គលដែលជានិយោជកនៃបុគ្គល ដែលបានរៀបរាប់ខាងលើ ឬបុគ្គលដែលបានជួលឱ្យធ្វើការងារឱ្យគាត់ ដែលច្បាប់នៃភាគីហាត្ថលេខីដែលពាក់ព័ន្ធបានចែងបែបនោះ ឬ
- អ្នកទទួលសិទ្ធិពីបុគ្គលទី១ឬទី២ ដូចបានរៀបរាប់ខាងលើ តាមករណីនីមួយៗ

(v) " សិទ្ធិអ្នកបង្កាត់ពូជដំណាំ" សំដៅដល់សិទ្ធិរបស់អ្នកបង្កាត់ពូជដំណាំ ដូចមានចែងក្នុងអនុសញ្ញានេះ

(vi) "ពូជដំណាំ" សំដៅដល់ក្រុមរុក្ខជាតិនៃចំណាត់ថ្នាក់តែមួយ ដែលគេស្គាល់តិចបំផុត ទោះជាមិនបានបំពេញឱ្យបានពេញលេញនូវលក្ខខណ្ឌនៃការផ្ដល់សិទ្ធិអ្នកបង្កាត់ពូជដំណាំក្ដីដែលអាចៈ

- ត្រូវកំណត់ដោយការបង្ហាញ ចរិតលក្ខណៈ ដែលជាលទ្ធផលនៃគំរូហ្សែន ឬ បន្សំគំរូហ្សែន
- ត្រូវខុសប្លែកពីក្រុមរុក្ខជាតិផ្សេងទៀត តាមរយៈការបង្ហាញយ៉ាងហោចណាស់ នូវលក្ខណៈណាមួយនៃចរិកលក្ខណៈខាងលើ ហើយ
- ត្រូវចាត់ទុកជាក្រុមមួយចំពោះលទ្ធភាពដែលអាចដាំដុះបន្ត ដោយមិនផ្លាស់ប្តូរ ។

(vii) "ភាគីហត្ថលេខី" សំដៅដល់រដ្ឋមួយ ឬ អង្គការអន្តររដ្ឋាភិបាលមួយ ដែលជាភាគីនៃអនុសញ្ញានេះ។

(viii)"ដែនដី" ក្នុងទំនាក់ទំនងជាមួយភាគីហត្ថលេខីនៅពេលដែលភាគីហត្ថលេខីជារដ្ឋ សំដៅដល់ដែនដីនៃរដ្ឋនោះ ហើយបើជាអង្គការអន្តររដ្ឋាភិបាលសំដៅដល់ដែនដីដែលអនុវត្តសន្ធិសញ្ញា ដែលបង្កើតអង្គការអន្តររដ្ឋាភិបាលនោះ

(ix)"អាជ្ញាធរ" សំដៅដល់ អាជ្ញាធរ ដូចមានចែងក្នុងមាត្រា ៣០(១)(ii)

(x)"សហភាព" សំដៅដល់សហភាពដើម្បីការពារពូជថ្មីនៃដំណាំដែលត្រូវបានបង្កើតដោយច្បាប់ឆ្នាំ១៩៦១ ហើយត្រូវបានចែងបន្ថែមក្នុងច្បាប់ឆ្នាំ១៩៧២ ច្បាប់ឆ្នាំ១៩៧៨ និងក្នុងអនុសញ្ញានេះ

(xi) "សមាជិកនៃសហភាព" សំដៅដល់រដ្ឋជាភាគីនៃច្បាប់ឆ្នាំ ១៩៦១/១៩៧២ ឬច្បាប់ឆ្នាំ១៩៧៨ឬភាគីហត្ថលេខីមួយ។

# ជំពូកទី២
# ភាតព្វកិច្ចទូទៅ នៃភាគីហត្ថលេខី

## មាត្រា២
## កាតព្វកិច្ចជាមូលដ្ឋាននៃភាគីហត្ថលេខី

ភាគីហត្ថលេខីនីមួយៗត្រូវផ្តល់ និងការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

## មាត្រា៣
## អំបូរ និងប្រភេទពូជដែលត្រូវការពារ

(១) [ រដ្ឋដែលជាសមាជិកហើយនៃសហភាព ] ភាគីហត្ថលេខីនីមួយៗ ដែលចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៦១/១៩៧២ ឬច្បាប់ឆ្នាំ ១៩៧៨ ត្រូវអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ:

(i) ត្រឹមកាលបរិច្ឆេទដែលភាគីហត្ថលេខី ចងភ្ជាប់ដោយអនុសញ្ញានេះចំពោះអំបូរនិងប្រភេទពូជរុក្ខជាតិទាំងអស់ដែលខ្លួនអនុវត្តក្នុងបទប្បញ្ញត្តិនៃច្បាប់ឆ្នាំ១៩៦១/១៩៧២ និងច្បាប់ឆ្នាំ១៩៧៨ តាមកាលបរិច្ឆេនេះ
ហើយ

(ii) យូរបំផុត ត្រឹមផុតកំណត់រយៈពេល៥(ប្រាំ)ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនេះ ចំពោះអំបូរ និងប្រភេទពូជរុក្ខជាតិទាំងអស់

(២) [ សមាជិកថ្មីនៃសហភាព] ភាគីហត្ថលេខីនីមួយៗ ដែលមិនចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៦១/១៩៧២ ឬច្បាប់ឆ្នាំ១៩៧៨ ត្រូវអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ:

(i)ត្រឹមកាលបរិច្ឆេទដែលភាគីហត្ថលេខីចងភ្ជាប់ដោយអនុ-សញ្ញានេះចំពោះអំបូរ និងប្រភេទពូជរុក្ខជាតិយ៉ាងហោច-

ណាស់១៥(ដប់ប្រាំ) ហើយ

(ii) យូរបំផុតត្រឹមផុតកំណត់រយៈពេល១០(ដប់)ឆ្នាំ រាប់ចាប់ពីកាលបរិច្ឆេទនេះចំពោះអំបូរនិងប្រភេទពូជរុក្ខជាតិទាំងអស់។

## មាត្រា៤
## ប្រព្រឹត្តិកម្មជាតិ

(១) [ប្រព្រឹត្តិកម្ម] ដោយមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ ដែលមានចែងក្នុងអនុសញ្ញានេះ ពលរដ្ឋនៃភាគីហត្ថលេខី ក៏ដូចជារូបវន្តបុគ្គលដែលមានលំនៅ និងនីតិបុគ្គលដែលមានការិយាល័យដែលបានចុះបញ្ជីក្នុងដែនដីនៃភាគីហត្ថលេខីមួយចំពោះការផ្តល់និងកិច្ចការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ ត្រូវទទួលក្នុងដែនដីនៃភាគីហត្ថលេខីផ្សេងទៀត នូវប្រព្រឹត្តិកម្មដូចគ្នានឹងប្រព្រឹត្តិកម្មដែលបានផ្តល់ ឬអាចត្រូវបានផ្តល់ នាពេលបន្ទាប់ដោយច្បាប់នៃភាគីហត្ថលេខីនីមួយៗផ្សេងទៀត ចំពោះពលរដ្ឋរបស់ខ្លួន ឱ្យតែពលរដ្ឋទាំងនេះ ទោះជារូបវន្តបុគ្គល ឬនីតិបុគ្គលក្តីអនុ-លោមតាមលក្ខខណ្ឌនិងបែបបទ ដែលបានតម្រូវដល់ពលរដ្ឋនៃភាគីហត្ថលេខីផ្សេងទៀតនេះ។

(២) [ពលរដ្ឋ] សម្រាប់គោលបំណងនៃកថាខណ្ឌខាងលើ "ពលរដ្ឋ" នៅពេលដែលភាគីហត្ថលេខីជារដ្ឋ គឺពលរដ្ឋនៃរដ្ឋនេះ ហើយបើភាគីហត្ថលេខី ជាអង្គការអន្តររដ្ឋាភិបាលគឺពលរដ្ឋនៃរដ្ឋដែលជាសមាជិកនៃអង្គការនេះ។

# ជំពូកទី៣
# លក្ខខណ្ឌសម្រាប់ការផ្តល់សិទ្ធិដល់អ្នកបង្កាត់ពូជដំណាំ

## មាត្រា៥
## លក្ខខណ្ឌដើម្បីការពារ

(១) [ លក្ខណៈវិនិច្ឆ័យដែលត្រូវបំពេញ] សិទ្ធិអ្នកបង្កាត់ពូជដំណាំត្រូវផ្តល់ឱ្យនៅពេលដែលពូជដំណាំ :

(i) ថ្មី

(ii) ភាពខុសប្លែក

(iii) ឯកសណ្ឋានភាព និង

(iv) ស្ថេរភាព។

(២) [ លក្ខខណ្ឌផ្សេងទៀត ] ការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំមិនត្រូវបំពេញលក្ខខណ្ឌបន្ថែម ឬផ្សេងទៀតឡើយ ឱ្យតែពូជដំណាំនេះត្រូវបានកំណត់ដោយការដាក់ឈ្មោះ ស្របតាមបទប្បញ្ញត្តិនៃមាត្រា២០ ហើយឱ្យតែអ្នកដាក់ពាក្យស្នើសុំបានបំពេញតាមទម្រង់ ដូចមានចែងក្នុងច្បាប់នៃភាគីហាត្ថលេខី ជាមួយអាជ្ញាធរនៃភាគីហត្ថលេខី ដែលពាក្យស្នើសុំបានដាក់ និងបានបង់កម្រៃដែលបានកំណត់។

## មាត្រា៦
## ភាពថ្មី

(១) [ លក្ខណៈវិនិច្ឆ័យ ] ពូជដំណាំដែលចាត់ទុកថាថ្មី ត្រឹមកាលបរិច្ឆេទ ការដាក់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ លុះត្រាតែបំណែកពូជដែលអាចយកទៅដាំដុះបាន ឬបំណែកពូជដែលប្រមូលផលបានពីការដាំដុះពុំទាន់ដាក់លក់ ឬដាក់បង្ហាញទៅបុគ្គលដទៃទៀតដោយអ្នកបង្កាត់ពូជដំណាំ ឬដោយមានការយល់ព្រមពីអ្នកបង្កាត់ពូជដំណាំក្នុង

គោលបំណងធ្វើអាជីវកម្មពូជដំណាំ:

(i) ក្នុងដែនដីនៃភាគីហត្ថលេខីដែលការដាក់ពាក្យស្នើសុំបានធ្វើ ក្នុងរយៈពេលមិនលើសពីមួយឆ្នាំមុនកាលបរិច្ឆេទនេះ និង

(ii) ក្រៅដែនដីភាគីហត្ថលេខី ដែលពាក្យស្នើសុំបានដាក់មុនរយៈពេល៤(បួន)ឆ្នាំ ឬក្នុងករណីដំណាំឈើឬដំណាំវល្លិបានដាក់មុនរយៈពេល៦(ប្រាំមួយ)ឆ្នាំមុនកាលបរិច្ឆេទនេះ

(២) [ពូជដំណាំដែលបង្កើតថ្មី] នៅពេលដែលភាគីហត្ថលេខីអនុវត្តអនុសញ្ញានេះចំពោះអំបូរ ឬប្រភេទពូជដំណាំមួយដែលភាគីហត្ថលេខីពីមុនមិនបានអនុវត្តអនុសញ្ញានេះឬច្បាប់មុន ភាគីនេះអាចចាត់ទុកពូជដំណាំដែលបង្កើតថ្មី ដែលមានត្រឹមកាលបរិច្ឆេទនៃការពង្រីកកិច្ចការពារថាបានបំពេញលក្ខខណ្ឌថ្មី ដូចមានចែងក្នុងកថាខណ្ឌទី១ ទោះបីបើការដាក់លក់ ឬដាក់បង្ហាញទៅអ្នកដទៃ ដូចមានចែងក្នុងកថាខណ្ឌនោះប្រព្រឹត្តិទៅមុខការកម្រិតរយៈពេល ដូចមានចែងក្នុងកថាខណ្ឌនោះក៏ដោយ។

(៣) [ "ដែនដី" ក្នុងករណីមួយចំនួន ] សម្រាប់គោលបំណងនៃកថាខណ្ឌទី(១) ភាគីហត្ថលេខីទាំងអស់ដែលជារដ្ឋសមាជិកនៃអង្គការអន្តររដ្ឋាភិបាលមួយដូចគ្នា នៅពេលដែលវិធានរបស់អង្គការតម្រូវ អាចចាត់វិធានការរួមគ្នា ដើម្បីប្រៀបប្រដូចសកម្មភាព ដែលប្រព្រឹត្តិលើដែនដីនៃរដ្ឋសមាជិករបស់អង្គការ ទៅនឹងសកម្មភាពដែលធ្វើឡើងក្នុងដែនដីរបស់ខ្លួនផ្ទាល់ ហើយបើធ្វើបែបនេះ ត្រូវជូនដំណឹងទៅអគ្គលេខាធិការ។

## មាត្រា៧
## ភាពខុសប្លែក

ពូជដំណាំត្រូវចាត់ទុកថាមានភាពខុសប្លែកពីគេ លុះត្រាតែមានភាពខុសគ្នាដាច់ស្រឡះពីពូជឯទៀត ដែលគេស្គាល់ជាទូទៅត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ។ ដោយឡែកការដាក់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ ឬការបញ្ចូលពូជដំណាំផ្សេងក្នុងបញ្ជីពូជដំណាំជាផ្លូវការក្នុងប្រទេសណាមួយ ត្រូវចាត់ទុកថាបានធ្វើឱ្យពូជដំណាំផ្សេងនេះស្គាល់ជាទូទៅត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ លុះត្រាតែការដាក់ពាក្យនេះឈានដល់ការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ឬឈានដល់ការបញ្ចូលពូជដំណាំនេះ ក្នុងបញ្ជីពូជដំណាំជាផ្លូវការ តាមករណីនីមួយៗ។

### មាត្រា៨
### ឯកសណ្ឋានភាព

ពូជដំណាំដែលចាត់ទុកថាមានឯកសណ្ឋានភាព លុះត្រាតែ ចរិតលក្ខណៈពាក់ព័ន្ធរបស់ពូជអាចរក្សាឯកសណ្ឋានគ្រប់គ្រាន់ លើកលែងតែមានការប្រែប្រួលលក្ខណៈពិសេសនៃការដាំដុះ។

### មាត្រា៩
### ស្ថេរភាព

ពូជដំណាំដែលចាត់ទុកថាមានស្ថេរភាព លុះត្រាតែ ចរិតលក្ខណៈពាក់ព័ន្ធរបស់វា គ្មានការប្រែប្រួលនៅគ្រប់ដំណាក់កាលនៃវដ្តលូតលាស់ ឬ ក្នុងករណីវដ្តដោយឡែកនៃការលូតលាស់ គឺគ្មានការប្រែប្រួលពេលបញ្ចប់វដ្តនីមួយៗ។

## ជំពូកទី៤
## ការដាក់ពាក្យស្នើសុំសម្រាប់ការផ្តល់សិទ្ធិដល់អ្នកបង្កាត់ពូជដំណាំ

## មាត្រា១០
## ការដាក់ពាក្យស្នើសុំ

(១)[ទីកន្លែងនៃការដាក់ពាក្យស្នើសុំលើកដំបូង] អ្នកបង្កាត់ពូជដំណាំអាចជ្រើសរើសអាជ្ញាធរនៃភាគីហត្ថលេខី ដែលគាត់ចង់ដាក់ពាក្យស្នើសុំលើកដំបូង ដើម្បីទទួលបានសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

(២)[ពេលវេលានៃពាក្យស្នើសុំបន្ទាប់] អ្នកបង្កាត់ពូជដំណាំអាចដាក់ពាក្យទៅអាជ្ញាធរនៃភាគីហត្ថលេខីផ្សេងទៀតដើម្បីទទួលបានសិទ្ធិអ្នកបង្កាត់ពូជដំណាំ ដោយមិនរងចាំការផ្តល់សិទ្ធិដោយអាជ្ញាធរនៃភាគីហត្ថលេខីដែលបានដាក់ពាក្យលើកដំបូងឡើយ។

(៣)[ឯករាជ្យភាពនៃកិច្ចការពារ] គ្មានភាគីហត្ថលេខីណាបដិសេធន៍មិនផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំឬកម្រិតរយៈពេលការពារដោយមូលហេតុថាកិច្ចការពារពូជដំណាំតែមួយមិនបានដាក់ពាក្យសុំត្រូវបានបដិសេធន៍ឬបានហួសរយៈពេលក្នុងរដ្ឋឬអង្គការអន្តររដ្ឋាភិបាលណាមួយផ្សេងទៀត។

## មាត្រា១១
## សិទ្ធិអាទិភាព

(១) [សិទ្ធិ រយៈពេល] អ្នកបង្កាត់ពូជដំណាំ ដែលបានដាក់ពាក្យស្នើសុំការពារពូជដំណាំត្រឹមត្រូវ ក្នុងភាគីហត្ថលេខីណាមួយ ("ពាក្យស្នើសុំដំបូង") ក្នុងគោលបំណងដាក់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំចំពោះពូជដំណាំតែមួយ នៅអាជ្ញាធរនៃភាគីហត្ថលេខីណាមួយផ្សេងទៀត (ពាក្យស្នើសុំបន្ទាប់) ត្រូវទទួលសិទ្ធិអាទិភាពក្នុងរយៈពេល១២ (ដប់ពីរ) ខែ។រយៈពេលនេះត្រូវរាប់ចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដំបូង ថ្ងៃនៃការដាក់ពាក្យមិនរាប់បញ្ចូលជាកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដំបូងឡើយ។

(២) [ការអះអាងសិទ្ធិ] ដើម្បីទទួលអត្ថប្រយោជន៍ពីសិទ្ធិអាទិភាព អ្នកបង្កាត់ពូជដំណាំត្រូវអះអាងសិទ្ធិអាទិភាព នៃពាក្យស្នើសុំដំបូង ក្នុងពាក្យស្នើសុំបន្ទាប់។ អាជ្ញាធរដែលទទួលពាក្យស្នើសុំបន្ទាប់ក្នុងរយៈពេលតិចជាង៣(បី)ខែ បន្ទាប់ពីកាលបិច្ឆេទដាក់ពាក្យស្នើសុំបន្ទាប់ អាចស្នើសុំឱ្យអ្នកបង្កាត់ពូជដំណាំ ផ្តល់ឯកសារចម្លងនៃពាក្យស្នើសុំដំបូង ដោយបញ្ជាក់ថាជាឯកសារត្រឹមត្រូវដោយអាជ្ញាធរដែលទទួលពាក្យស្នើសុំនោះ គំរូ ឬភស្តុតាងផ្សេងទៀតដែលពូជដំណាំជាកម្មវត្ថុនៃពាក្យស្នើសុំទាំងពីរត្រូវតែដូចគ្នា។

(៣) [ឯកសារ និងបំណែកពូជ] អ្នកបង្កាត់ពូជដំណាំត្រូវបានផ្តល់រយៈពេល២(ពីរ)ឆ្នាំបន្ទាប់ពីផុតរយៈពេលអាទិភាព ឬនៅពេលដែលពាក្យស្នើសុំដំបូងត្រូវបានបដិសេធន៍ ឬដកចេញ ត្រូវបានផ្តល់ឱ្យរយៈពេលសមរម្យមួយ បន្ទាប់ពីការបដិសេធន៍ ឬការដកពាក្យស្នើសុំ ដើម្បីផ្តល់ដល់អាជ្ញាធរនៃភាគីហត្ថលេខី ដែលទទួលពាក្យស្នើសុំបន្ទាប់នូវព័ត៌មានចាំបាច់ ឯកសារ ឬ បំណែកពូជផ្សេងៗ ដែលទាមទារក្នុងការត្រួតពិនិត្យតាមមាត្រា១២ ដូចដែលតម្រូវដោយច្បាប់នៃភាគីហត្ថលេខី។

(៤)[ព្រឹត្តិការណ៍ដែលកើតឡើងក្នុងរយៈពេលអាទិភាព]ព្រឹត្តិការណ៍នានាដែលកើតឡើងក្នុងរយៈពេលដែលមានចែងក្នុងកថាខណ្ឌទី(១) ដូចជាការដាក់ពាក្យស្នើសុំផ្សេងទៀត ឬការបោះពុម្ពផ្សាយ ឬការប្រើប្រាស់ពូជដំណាំដែលជាកម្មវត្ថុនៃការដាក់ពាក្យស្នើសុំដំបូង មិនត្រូវចាត់ទុកជាមូលដ្ឋានក្នុងការបដិសេធន៍ ការដាក់ពាក្យស្នើសុំបន្ទាប់ឡើយ។ ព្រឹត្តិការណ៍ទាំងនេះមិនត្រូវបង្កើតជាសិទ្ធិដល់តតិយជនឡើយ។

## មាត្រា១២
## ការត្រួតពិនិត្យពាក្យស្នើសុំ

សេចក្ដីសម្រេចណា ដែលផ្ដល់សិទ្ធិឱ្យអ្នកបង្កាត់ពូជដំណាំ ត្រូវទាមទារឱ្យត្រួតពិនិត្យអនុលោមភាពជាមួយលក្ខខណ្ឌនៃមាត្រា៥ ដល់មាត្រា៩។ ពេលកំពុងត្រួតពិនិត្យ អាជ្ញាធរអាចបណ្ដុះពូជដំណាំ ឬធ្វើពិសោធន៍ចាំបាច់ផ្សេងៗទៀត ឱ្យគេបណ្ដុះពូជដំណាំ ឬឱ្យគេធ្វើពិសោធន៍ចាំបាច់ផ្សេងៗទៀតឬពិចារណាលើលទ្ធផលនៃការពិសោធន៍បណ្ដុះ ឬការសាកល្បងផ្សេងទៀត ដែលបានធ្វើរួចហើយ។ ក្នុងគោលបំណងត្រួតពិនិត្យ អាជ្ញាធរអាចទាមទារឱ្យអ្នកបង្កាត់ពូជដំណាំផ្ដល់ព័ត៌មាន ឯកសារ ឬបំណែកពូជចាំបាច់នានា។

## មាត្រា១៣
## កិច្ចការពារបណ្ដោះអាសន្ន

ភាគីហត្ថលេខីនីមួយៗ ត្រូវចាត់វិធានការដើម្បីរក្សាប្រយោជន៍របស់អ្នកបង្កាត់ពូជដំណាំ ក្នុងចន្លោះពេលដាក់ពាក្យស្នើសុំ ឬពេលបោះ-ពុម្ពផ្សាយពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងការផ្ដល់សិទ្ធិ។ វិធានការទាំងនេះត្រូវមានអានុភាពផ្ដល់ឱ្យម្ចាស់សិទ្ធិអ្នកបង្កាត់ពូជដំណាំយ៉ាងហោចណាស់សិទ្ធិទទួលបានលាភការសមរម្យ ក្នុងរយៈពេលខាងលើពីបុគ្គលណាដែលបានធ្វើសកម្មភាព ពេលដែលបានផ្ដល់សិទ្ធិហើយដែលត្រូវការការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ ដូចមានចែងក្នុងមាត្រា ១៤។ ភាគីហត្ថលេខីអាចចែងថា វិធានការខាងលើមានអានុភាពតែក្នុងទំនាក់ទំនងជាមួយបុគ្គល ដែលអ្នកបង្កាត់ពូជដំណាំបានជូនដំណឹងអំពីការដាក់ពាក្យស្នើសុំ។

# ជំពូកទី៥
# សិទ្ធិអ្នកបង្កាត់ពូជដំណាំ

## មាត្រា១៤
## វិសាលភាពនៃសិទ្ធិអ្នកបង្កាត់ពូជដំណាំ

(១) [ សកម្មភាពទាក់ទងនឹងបំណែកពូជដែលអាចយកទៅដាំដុះបាន] (ក)លើកលែងតែមាត្រា១៥និងមាត្រា១៦ សកម្មភាពខាងក្រោមទាក់ទងនឹងបំណែកពូជ ដែលអាចយកទៅដាំដុះបាននៃពូជដំណាំដែលបានការពារ ត្រូវមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ:

(i) ការផលិត ឬការផលិតឡើងវិញ(ចំនួនច្រើន)
(ii) ការដាក់លក្ខខណ្ឌក្នុងគោលបំណងនៃការដាំដុះ
(iii) ការដាក់លក់
(iv) ការលក់ ឬចរាចរផ្សេងទៀត
(v) ការនាំចេញ
(vi) ការនាំចូល
(vii) ការស្តុកទុកសម្រាប់គោលបំណងណាមួយដូចមានចែងក្នុងចំណុច (i) ដល់ (vi) ខាងលើ។

(ខ) អ្នកបង្កាត់ពូជដំណាំអាចផ្តល់ការអនុញ្ញាត ដោយភ្ជាប់នូវលក្ខខណ្ឌនិងការកម្រិតសិទ្ធិ។

(២) [ សកម្មភាពទាក់ទងនឹងបំណែកពូជដែលប្រមូលផលបាន ] លើកលែងតែមាត្រា១៥ និងមាត្រា១៦សកម្មភាពដូចមានចែងក្នុងចំណុច (i) ដល់ (vii) នៃកថាខណ្ឌទី(១)(ក) ទាក់ទងនឹងបំណែកពូជដែលប្រមូលផលបាន រួមទាំងដំណាំទាំងមូលនិងផ្នែកនៃដំណាំ ដែលទទួលបានតាមរយៈការប្រើប្រាស់ ដោយគ្មានការអនុញ្ញាតនៃបំណែកពូជ ដែលអាចយកទៅដាំដុះបាននៃពូជដំណាំដែលបានការពារ តម្រូវឱ្យមានការអនុញ្ញាតពី

អ្នកបង្កាត់ពូជដំណាំ លើកលែងតែអ្នកបង្កាត់ពូជដំណាំ មានឱកាសសមរម្យ ដើម្បីអនុវត្តសិទ្ធិរបស់ខ្លួនទាក់ទងនឹងបំណែកពូជដែលអាចយកទៅដាំដុះបានខាងលើ។

(៣) [សកម្មភាពទាក់ទងនឹងផលិតផលមួយចំនួន] លើកលែងតែមាត្រា១៥ និងមាត្រា១៦ ភាគីហត្ថលេខីនីមួយៗ អាចចែងថាសកម្មភាពដូចមានចែងក្នុងចំណុច (i) ដល់ (vii) នៃកថាខណ្ឌទី(១)(ក) ទាក់ទងនឹងផលិតផល ដែលបង្កើតឡើងដោយផ្ទាល់ពីបំណែកពូជដែលប្រមូលផលបាននៃពូជដំណាំដែលបានការពារក្នុងបទប្បញ្ញត្តិនៃកថាខណ្ឌទី(២) តាមរយៈការប្រើប្រាស់ដោយគ្មានការអនុញ្ញាត នៃបំណែកពូជដែលប្រមូលផលបាននេះ តម្រូវឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ លើកលែងតែអ្នកបង្កាត់ពូជដំណាំមានឱកាសសមរម្យ ដើម្បីអនុវត្តសិទ្ធិរបស់ខ្លួនទាក់ទងនឹងបំណែកពូជដែលប្រមូលផលបាននេះ។

(៤) [សកម្មភាពបន្ថែមដែលអាចមាន] លើកលែងតែមាត្រា១៥ និងមាត្រា១៦ ភាគីហត្ថលេខីនីមួយៗ អាចចែងពីសកម្មភាពផ្សេងក្រៅពីសកម្មភាពដែលមានចែង ក្នុងចំនុច (i) ដល់ (vii) នៃកថាខណ្ឌទី(១)(ក) ក៏តម្រូវឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំផងដែរ។

(៥) [ ពូជដំណាំដែលមានស្រឡាយសំខាន់ និងពូជដំណាំផ្សេងទៀតមួយចំនួន] (ក)បទប្បញ្ញត្តិនៃកថាខណ្ឌទី(១) ដល់ទី(៤) ត្រូវអនុវត្តផងដែរទាក់ទងនឹង:

(i) ពូជដំណាំដែលមានស្រឡាយសំខាន់ពីពូជដំណាំដែលបានការពារ នៅពេលដែលពូជដំណាំដែលបានការពារ មិនមែនជាពូជដំណាំដែលមានស្រឡាយសំខាន់នោះទេ

(ii) ពូជដំណាំដែលមិនអាចញែកដាច់ពីគ្នាស្រឡះ អនុលោមតាមមាត្រា៧ ពីពូជដំណាំដែលបានការពារ និង

(iii) ការផលិតពូជដំណាំតម្រូវឱ្យមានការប្រើប្រាស់ ម្តងហើយម្តងទៀត នូវពូជដំណាំដែលបានការពារ។

(ខ) សម្រាប់គោលបំណងនៃអនុកថាខណ្ឌ(ក)(i) ពូជដំណាំត្រូវចាត់ទុកថាមានស្រឡាយសំខាន់ពីពូជដំណាំមួយផ្សេងទៀត("ពូជដំណាំដើម") នៅពេលដែល:

(i) ពូជដំណាំដែលមានស្រឡាយលើសលុបពីពូជដំណាំដើម ឬពីពូជដំណាំមួយ ដែលវាជាស្រឡាយលើសលុបពីពូជដំណាំដើម តែនៅរក្សាការបង្ហាញ ចរិតលក្ខណៈសំខាន់ជាលទ្ធផលនៃគំរូហ្សែន ឬ បន្សំគំរូហ្សែននៃពូជដំណាំដើម

(ii) ពូជដំណាំអាចញែកដាច់ពីគ្នាស្រឡះពីពូជដំណាំដើម និង

(iii) លើកលែងតែភាពខុសគ្នា ដែលកើតពីអំពើនៃការបំប្លែងពូជដំណាំដូចនឹងពូជដំណាំដើម ក្នុងការបង្ហាញ ចរិតលក្ខណៈសំខាន់ជាលទ្ធផលនៃគំរូហ្សែន ឬបន្សំគំរូហ្សែននៃពូជដំណាំដើម។

(គ) ពូជបំលែងសំខាន់ៗដែលអាចទទួលបាន ដូចជាតាមការជ្រើសរើសដោយធម្មជាតិឬដោយការបំបែកកោសិកា ឬដោយបំរែបំរួលហ្សែន ការជ្រើសរើសពូជបំរែបំរួលមួយៗចេញពីពូជដំណាំដែលគេបង្កើតឡើង ត្រូវធ្វើតាមរយៈការបង្កាត់ត្រឡប់ ឬការបំប្លែងតាមរយៈវិស្វកម្មហ្សែន។

## មាត្រា១៥

## ការលើកលែងចំពោះសិទ្ធិអ្នកបង្កាត់ពូជដំណាំ

(១) [ការលើកលែងដោយបង្ខំ] សិទ្ធិអ្នកបង្កាត់ពូជដំណាំគ្មានវិសាលភាពដល់:

(i) សកម្មភាពដែលធ្វើឡើងដោយឯកជន និងគ្មានបំណង

ពាណិជ្ជកម្ម

(ii) សកម្មភាពដែលធ្វើឡើងក្នុងគោលបំណងពិសោធន៍ និង

(iii) សកម្មភាពដែលធ្វើឡើង ក្នុងគោលបំណងបង្កាត់ពូជដំណាំផ្សេងទៀត និង សកម្មភាពដូចមានចែងក្នុងមាត្រា១៤(១)ដល់(៤) ទាក់ទងនឹងពូជដំណាំផ្សេងទៀតនេះ លើកលែងតែអនុវត្ត បទប្បញ្ញត្តិនៃមាត្រា១៤(៥) ។

(២) [ការលើកលែងតាមជម្រើស] ថ្វីបើមានចែងក្នុងមាត្រា១៤ក៏ដោយ ក៏ភាគីហត្ថលេខីនីមួយៗអាចក្នុងកម្រិតសមរម្យ និងលើកលែងតែ ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់អ្នកបង្កាត់ពូជដំណាំ កម្រិតសិទ្ធិអ្នកបង្កាត់ពូជដំណាំទាក់ទងនឹងពូជដំណាំណាមួយ ដើម្បីអនុញ្ញាតឱ្យកសិករប្រើប្រាស់ដោយខ្លួនឯង សម្រាប់គោលបំណងដាំដុះបន្ត នូវផលិតផលដែលប្រមូលផលបាន ពីពូជដំណាំដែលបានការពារ ឬពូជដំណាំដែលគ្រប់គ្រងដោយមាត្រា១៤(៥)(ក)(i)ឬ(ii) ។

## មាត្រា១៦
## ការរលត់សិទ្ធិអ្នកបង្កាត់ពូជដំណាំ

(១) [ការរលត់សិទ្ធិ] សិទ្ធិអ្នកបង្កាត់ពូជដំណាំគ្មានវិសាលភាពដល់សកម្មភាពពាក់ព័ន្ធនឹងបំណែកពូជណាមួយនៃពូជដំណាំ ដែលបានការពារឬនៃពូជដំណាំដែលគ្រប់គ្រងដោយបទប្បញ្ញត្តិនៃមាត្រា១៤(៥) ដែលបានលក់ ឬចរាចរដោយអ្នកបង្កាត់ពូជដំណាំ ឬ ដោយមានការយល់ព្រមពីខ្លួនក្នុងដែនដីនៃភាគីហត្ថលេខីដែលពាក់ព័ន្ធ ឬ បំណែកពូជណាមួយដែលមានស្រឡាយពីបំណែកពូជនេះ លើកលែងតែសកម្មភាពទាំងនេះ :

(i) ទាក់ទងនឹងការដាំដុះបន្តនៃពូជដំណាំនេះ ឬ

(ii) ទាក់ទងនឹងការនាំចេញបំណែកនៃពូជដំណាំ ដែលអាច

បណ្តុះពូជដំណាំបានទៅប្រទេសមួយដែលមិនការពារពូជ ដំណាំនៃអំបូរឬប្រភេទពូជរុក្ខជាតិដែលជាពូជដំណាំលើក លែងតែបំណែកពូជដំណាំនាំចេញមានគោលបំណងសម្រាប់ ប្រើប្រាស់ចុងក្រោយ។

(២) [ អត្ថន័យនៃ"បំណែកពូជដំណាំ"]សម្រាប់គោលបំណងនៃកថា-ខណ្ឌទី(១) ទាក់ទងនឹងពូជដំណាំ "បំណែកពូជដំណាំ" មានន័យថា:

(i) បំណែកពូជនៃប្រភេទណាមួយដែលអាចយកទៅដាំដុះបាន

(ii) បំណែកពូជដែលប្រមូលផលបាន រួមទាំងដំណាំទាំងមូល និងផ្នែកនៃដំណាំ និង

(iii) ផលិតផលណាមួយ ដែលបង្កើតឡើងដោយផ្ទាល់ពីបំ-ណែកពូជដែលប្រមូលផលបាន។

(៣) ["ដែនដី" ក្នុងករណីមួយចំនួន] សម្រាប់គោលបំណងក្នុង កថាខណ្ឌ(១)ភាគីហត្ថលេខីទាំងអស់ ដែលជារដ្ឋសមាជិកនៃអង្គការអន្តរ រដ្ឋាភិបាលមួយដូចគ្នា នៅពេលដែលវិធានរបស់អង្គការតម្រូវ អាចចាត់ វិធានការរួមគ្នាដើម្បីប្រៀបប្រដូចសកម្មភាពដែលប្រព្រឹត្តិលើដែនដីនៃរដ្ឋ សមាជិករបស់អង្គការនោះ ទៅនឹងសកម្មភាពដែលធ្វើឡើង ក្នុងដែនដី របស់ខ្លួនផ្ទាល់ ហើយបើធ្វើបែបនេះត្រូវជូនដំណឹងទៅអគ្គលេខាធិការ។

## មាត្រា១៧
## ការកម្រិតការអនុវត្តន៍សិទ្ធិអ្នកបង្កាត់ពូជដំណាំ

(១) [ផលប្រយោជន៍សាធារណៈ] លើកលែងតែមានចែងច្បាស់ក្នុង អនុសញ្ញានេះ គ្មានភាគីហត្ថលេខីណាមួយ អាចកម្រិតសេរីភាពអនុវត្ត សិទ្ធិអ្នកបង្កាត់ពូជដំណាំ ដោយមូលហេតុផ្សេងក្រៅពីផលប្រយោជន៍ សាធារណៈឡើយ។

(២) [ លាភការសមរម្យ ] នៅពេលដែលការកម្រិតបែបនេះមាន

អនុភាពអនុញ្ញាតឱ្យតតិយជន ដើម្បីធ្វើសកម្មភាពណាមួយដែលតម្រូវឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ ភាគីហត្ថលេខីពាក់ព័ន្ធត្រូវចាត់វាល់វិធានការចាំបាច់ដើម្បីធានាថា អ្នកបង្កាត់ពូជដំណាំទទួលបានលាភការសមរម្យ។

## មាត្រា១៨

## វិធានការគ្រប់គ្រងពាណិជ្ជកម្ម

សិទ្ធិអ្នកបង្កាត់ពូជដំណាំ ត្រូវឯករាជ្យពីវិធានការរបស់ភាគីហត្ថលេខីក្នុងការគ្រប់គ្រងលើដែនដីរបស់ខ្លួននូវ ការផលិត ការបញ្ជាក់ និងចរាចរបំណែកពូជដំណាំ ឬការនាំចូលឬការនាំចេញបំណែកពូជនេះ។ ប៉ុន្តែវិធានការទាំងនេះមិនត្រូវប៉ះពាល់ដល់ការអនុវត្តន៍បទប្បញ្ញត្តិនៃសន្ធិសញ្ញានេះឡើយ។

## មាត្រា១៩

## រយៈពេលការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ

(១) [រយៈពេលនៃកិច្ចការពារ] សិទ្ធិអ្នកបង្កាត់ពូជដំណាំ ត្រូវផ្តល់ឱ្យក្នុងរយៈពេលកំណត់មួយ។

(២) [រយៈពេលអប្បបរមា] រយៈពេលនេះមិនត្រូវខ្លីជាង២០(ម្ភៃ)ឆ្នាំរាប់ចាប់ពីកាលបរិច្ឆេទនៃការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ។ចំពោះដំណាំឈើនិងដំណាំវល្លិ រយៈពេលនេះមិនត្រូវខ្លីជាង២៥(ម្ភៃប្រាំ)រាប់ចាប់ពីការបរិច្ឆេទទទួលបានសិទ្ធិនេះ។

# ជំពូកទី៦
# ការដាក់ឈ្មោះពូជដំណាំ

## មាត្រា២០
## ការដាក់ឈ្មោះពូជដំណាំ

(១) [ការកំណត់ពូជដំណាំដោយការដាក់ឈ្មោះ ការប្រើប្រាស់ការដាក់ឈ្មោះ] (ក) ពូជដំណាំត្រូវតំណត់ដោយការដាក់ឈ្មោះ ដែលនឹងក្លាយជាការកំណត់ប្រភេទពូជដំណាំ។

(ខ) លើកលែងតែកថាខណ្ឌទី(៤) ភាគីហត្ថលេខីនីមួយៗត្រូវធានាថា សិទ្ធិចំពោះការកំណត់ដែលបានចុះបញ្ជីជាការដាក់ឈ្មោះពូជដំណាំមិនត្រូវរាំងការប្រើប្រាស់ដោយសេរីនៃការដាក់ឈ្មោះពូជដំណាំ ទោះបីបន្ទាប់ពីផុតសុពលភាពសិទ្ធិអ្នកបង្កាត់ពូជដំណាំក៏ដោយ។

(២) [ ចរិតលក្ខណៈនៃការដាក់ឈ្មោះ] ការដាក់ឈ្មោះត្រូវតែអាចសម្គាល់ពូជដំណាំបាន។ ការដាក់ឈ្មោះមិនត្រូវមានសញ្ញាតែមួយទេ លើកលែងតែសញ្ញានេះ ជាការអនុវត្តន៍ពីមុន ក្នុងការកំណត់ពូជដំណាំ។ ការដាក់ឈ្មោះមិនត្រូវនាំឱ្យយល់ខុស ឬបណ្ដាលឱ្យភ័ន្តច្រឡំទៅនឹងចរិតលក្ខណៈ តម្លៃ ឬ អត្តសញ្ញាណនៃពូជដំណាំ ឬ អត្តសញ្ញាណរបស់អ្នកបង្កាត់ពូជដំណាំឡើយ។ ជាពិសេស ការដាក់ឈ្មោះត្រូវខុសពីរាល់ការដាក់ឈ្មោះលើពូជដំណាំដែលមានរួចហើយ ក្នុងប្រភេទពូជដំណាំតែមួយឬ ក្នុងប្រភេទដែលទាក់ទងជិតស្និទ្ធក្នុងដែនដីនៃភាគីហត្ថលេខីណាមួយ។

(៣) [ការចុះបញ្ជីការដាក់ឈ្មោះ] ការដាក់ឈ្មោះពូជដំណាំត្រូវស្នើដោយអ្នកបង្កាត់ពូជដំណាំទៅអាជ្ញាធរ។ ប្រសិនបើអាជ្ញាធររកឃើញថាការដាក់ឈ្មោះមិនបានបំពេញលក្ខខណ្ឌតម្រូវនៃកថាខណ្ឌទី(២) អាជ្ញាធរត្រូវបដិសេធន៍ការចុះបញ្ជី ហើយតម្រូវឱ្យអ្នកបង្កាត់ពូជដំណាំស្នើការ

ដាក់ឈ្មោះមួយផ្សេងទៀត ក្នុងរយៈពេលកំណត់មួយ។ ការដាក់ឈ្មោះត្រូវចុះបញ្ជីដោយអាជ្ញាធរក្នុងពេលតែមួយ ស្របគ្នានឹងការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ។

(៤) [សិទ្ធិពីមុននៃតតិយជន] សិទ្ធិពីមុននៃតតិយជនមិនត្រូវប៉ះពាល់ឡើយ។ ដោយមូលហេតុនៃសិទ្ធិពីមុន ប្រសិនបើ ការប្រើប្រាស់ការដាក់ឈ្មោះពូជដំណាំ ត្រូវហាមឃាត់ចំពោះបុគ្គលណាមួយ ដែលតាមបទប្បញ្ញត្តិនៃកថាខណ្ឌទី(៧) តម្រូវឱ្យប្រើប្រាស់ការដាក់ឈ្មោះនេះ អាជ្ញាធរត្រូវតម្រូវឱ្យអ្នកបង្កាត់ពូជដំណាំ ស្នើការដាក់ឈ្មោះមួយផ្សេងទៀតសម្រាប់ពូជដំណាំនេះ។

(៥) [ការដាក់ឈ្មោះដូចគ្នាក្នុងដែនដីភាគីហត្ថលេខីទាំងអស់] ពូជដំណាំមួយត្រូវបញ្ជូនទៅភាគីហត្ថលេខីទាំងអស់ក្រោមការដាក់ឈ្មោះតែមួយ។ អាជ្ញាធរនៃភាគីហត្ថលេខីនីមួយៗត្រូវចុះបញ្ជីការដាក់ឈ្មោះដែលបានបញ្ជូនមក លើកលែងតែយល់ថាការដាក់ឈ្មោះនេះមិនសមស្របក្នុងដែនដីរបស់ខ្លួន។ ក្នុងករណីនេះ តម្រូវឱ្យអ្នកបង្កាត់ពូជដំណាំផ្តល់ការដាក់ឈ្មោះមួយផ្សេងទៀត។

(៦) [ព័ត៌មានរវាងអាជ្ញាធរនៃភាគីហត្ថលេខី] អាជ្ញាធរនៃភាគីហត្ថលេខីត្រូវធានាថាអាជ្ញាធរនៃភាគីហត្ថលេខីផ្សេងទៀតទាំងអស់ ត្រូវបានជូនដំណឹងពីបញ្ហាពាក់ព័ន្ធនឹងការដាក់ឈ្មោះពូជដំណាំ ជាពិសេសការបញ្ចូល ការចុះបញ្ជី និងការលុបចោលការដាក់ឈ្មោះ។ អាជ្ញាធរណាមួយអាចលើកឡើងអំពីការសង្កេតរបស់ខ្លួន បើមានលើការចុះបញ្ជីការដាក់ឈ្មោះទៅអាជ្ញាធរដែលបានជូនដំណឹងពីការដាក់ឈ្មោះនេះ ។

(៧) [កាតព្វកិច្ចប្រើប្រាស់ការដាក់ឈ្មោះ] ក្នុងដែនដីភាគីហត្ថលេខីមួយ បុគ្គលណាមួយដែលដាក់លក់ ឬចរាចរបំណែកនៃពូជដំណាំដែលបានការពារក្នុងដែនដីនេះ ត្រូវប្រើប្រាស់ការដាក់ឈ្មោះពូជដំណាំនេះទោះបីបន្ទាប់ពីសិទ្ធិអ្នកបង្កាត់ពូជដំណាំផុតសុពលភាពចំពោះពូជដំណាំ

នេះក៏ដោយ លើកលែងតែសិទ្ធិពីមុនណាមួយរាំងដល់ការប្រើប្រាស់បែបនេះតាមបទប្បញ្ញត្តិនៃកថាខណ្ឌទី(៤)។

(៨) [ការបញ្ជាក់ដែលប្រើប្រាស់ទាក់ទងនឹងការដាក់ឈ្មោះ] នៅពេលដែលពូជដំណាំមួយ ត្រូវបានដាក់លក់ ឬចរាចរ ពូជដំណាំត្រូវបានអនុញ្ញាឱ្យភ្ជាប់ទៅនឹង ពាណិជ្ជសញ្ញា ពាណិជ្ជនាម ឬការបញ្ជាក់ប្រហាក់ប្រហែលផ្សេងទៀតជាមួយការដាក់ឈ្មោះពូជដំណាំដែលបានចុះបញ្ជី។ ប្រសិនបើការបញ្ជាក់នេះត្រូវបានភ្ជាប់បែបនេះ ការដាក់ឈ្មោះត្រូវធ្វើយ៉ាងណាឱ្យងាយស្គាល់។

## ជំពូកទី៧
## មោឃភាពនិងការលុបចោលសិទ្ធិអ្នកបង្កាត់ពូជដំណាំ

### មាត្រា ២១
### មោឃភាពសិទ្ធិអ្នកបង្កាត់ពូជដំណាំ

(១) [មូលហេតុនៃមោឃភាព] ភាគីហត្ថលេខីនីមួយៗត្រូវប្រកាសថា សិទ្ធិអ្នកបង្កាត់ពូជដំណាំដែលបានផ្តល់ ត្រូវធ្វើមោឃភាព នៅពេលដែល:

- (i) លក្ខខណ្ឌក្នុងមាត្រា៦ឬមាត្រា៧មិនបានបំពេញដូចកាលពីពេលផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ
- (ii) ក្នុងករណីដែលការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ផ្អែកជាសំខាន់លើព័ត៌មាន និងឯកសារដែលផ្តល់ឱ្យដោយអ្នកបង្កាត់ពូជដំណាំ លក្ខខណ្ឌក្នុងមាត្រា៨ ឬមាត្រា៩ មិនបានបំពេញដូចកាលពីពេលផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ឬ
- (iii) សិទ្ធិអ្នកបង្កាត់ពូជដំណាំ បានផ្តល់ទៅឱ្យបុគ្គលមួយដែលគ្មានសិទ្ធិទទួល លើកលែងតែសិទ្ធិនេះ ត្រូវបានផ្ទេរទៅឱ្យបុគ្គលដែលមានសិទ្ធិទទួល។

(២) [ ការបដិសេធន៍មូលហេតុផ្សេងៗទៀត ] សិទ្ធិអ្នកបង្កាត់ពូជដំណាំមិនត្រូវបានប្រកាសថា មោឃភាពដោយមូលហេតុផ្សេងក្រៅពីមូលហេតុដូចមានចែងក្នុងកថាខណ្ឌទី(១)ឡើយ។

## មាត្រា២២
## ការលុបចោលសិទ្ធិអ្នកបង្កាត់ពូជដំណាំ

(១) [មូលហេតុនៃការលុបចោល] (ក) ភាគីហត្ថលេខីនីមួយៗ អាចលុបចោលសិទ្ធិអ្នកបង្កាត់ពូជដំណាំដែលខ្លួនបានផ្តល់ឱ្យ ប្រសិនបើមានភស្តុតាងបង្ហាញថាលក្ខខណ្ឌក្នុងមាត្រា៨ ឬមាត្រា៩ លែងបំពេញបាន។

(ខ) ជាងនេះទៅទៀត ភាគីហត្ថលេខីនីមួយៗ អាចលុបចោលសិទ្ធិអ្នកបង្កាត់ពូជដំណាំដែលខ្លួនបានផ្តល់ឱ្យ ប្រសិនបើបន្ទាប់ពីមានសំណើ និងក្នុងរយៈពេលកំណត់មួយៈ

- (i) អ្នកបង្កាត់ពូជដំណាំមិនបានផ្តល់ព័ត៌មាន ឯកសារ ឬបំណែកពូជដែលចាំបាច់សម្រាប់ផ្ទៀងផ្ទាត់ការរក្សាសិទ្ធិនៃពូជដំណាំដល់អាជ្ញាធរ
- (ii) អ្នកបង្កាត់ពូជដំណាំខកខានមិនបានបង់កម្រៃដើម្បីរក្សាសិទ្ធិខ្លួនឱ្យនៅជាធរមាន ឬ
- (iii) អ្នកបង្កាត់ពូជដំណាំមិនបានផ្តល់ឈ្មោះថ្មីសមស្របបន្ទាប់ពីឈ្មោះពូជដំណាំដែលទទួលបានសិទ្ធិនេះ ត្រូវបានលុបចោល។

(២) [ការបដិសេធន៍មូលហេតុផ្សេងទៀត] សិទ្ធិអ្នកបង្កាត់ពូជដំណាំមិនត្រូវបានលុបចោលដោយមូលហេតុផ្សេង ក្រៅពីមូលហេតុដូចមានចែងក្នុងកថាខណ្ឌទី(១)ឡើយ។

# ជំពូកទី៨
# សហភាព

## មាត្រា២៣
## សមាជិក

ភាគីហត្ថលេខីទាំងឡាយត្រូវជាសមាជិកនៃសហភាព។

## មាត្រា២៤
## ឋានៈផ្លូវច្បាប់ និងអាសនៈ

(១) [បុគ្គលភាពគតិយុត្ត] សហភាពមាន បុគ្គលភាពគតិយុត្ត។

(២) [សមត្ថភាពផ្លូវច្បាប់] ក្នុងដែនដីភាគីហត្ថលេខីនីមួយៗដោយអនុលោមតាមច្បាប់ដែលអនុវត្តក្នុងដែនដីនេះ សហភាពមានសមត្ថភាពផ្លូវច្បាប់ដែលចាំបាច់ដើម្បីបំពេញគោលបំណងសហភាព និង ដើម្បីអនុវត្តមុខងាររបស់ខ្លួន ។

(៣) [ អាសនៈ ] អាសនៈនៃសហភាពនិងអង្គភាពអចិន្ត្រៃយ៍របស់ខ្លួនត្រូវមានទីតាំងក្នុងទីក្រុងហ្សឺណែវ។

(៤) [កិច្ចព្រមព្រៀងទីស្នាក់ការ] សហភាពមានកិច្ចព្រមព្រៀងទីស្នាក់ការជាមួយសហព័ន្ធស្វីស។

## មាត្រា ២៥
## អង្គភាព

អង្គភាពអចិន្ត្រៃយ៍នៃសហភាពគឺ ក្រុមប្រឹក្សានិងការិយាល័យរបស់សហភាព។

## មាត្រា២៦
## ក្រុមប្រឹក្សា

(១) [សមាសភាព] ក្រុមប្រឹក្សាត្រូវមានតំណាងសមាជិកទាំងឡាយនៃសហភាព។ សមាជិកនីមួយៗនៃសហភាព ត្រូវចាត់តាំងតំណាងមួយរូបប្រចាំនៅក្រុមប្រឹក្សានិងអ្នកជំនួសម្នាក់។តំណាង ឬអ្នកជំនួស អាចអមដោយជំនួយការ ឬទីប្រឹក្សាមួយចំនួន។

(២) [មន្ត្រី] ក្រុមប្រឹក្សាត្រូវបោះឆ្នោតជ្រើសរើសប្រធានមួយរូបនិងអនុប្រធានទីមួយ មួយរូបពីក្នុងចំណោមសមាជិករបស់ខ្លួន។ ក្រុមប្រឹក្សាអាចបោះឆ្នោតជ្រើសរើសអនុប្រធានផ្សេងៗទៀត។ អនុប្រធានទីមួយត្រូវជំនួសប្រធាន ប្រសិនបើប្រធានមិនអាចធ្វើជាអធិបតី។ ប្រធានត្រូវមានអាណត្តិ៣(បី)ឆ្នាំ។

(៣) [សម័យប្រជុំ] ក្រុមប្រឹក្សាត្រូវប្រជុំតាមការកោះប្រជុំដោយប្រធានក្រុមប្រឹក្សា។ សម័យប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ត្រូវធ្វើប្រចាំឆ្នាំ។ ជាងនេះទៅទៀត ប្រធានអាចកោះប្រជុំ ក្រុមប្រឹក្សាតាមឆន្ទានុសិទ្ធិរបស់ខ្លួន។ តាមសំណើរបស់សមាជិកសហភាព១/៣(មួយភាគបី) ក្នុងរយៈពេល៣(បី)ខែ ប្រធានត្រូវកោះប្រជុំ ។

(៤) [អ្នកសង្កេតការណ៍] រដ្ឋមិនមែនជាសមាជិកសហភាព អាចត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំក្នុងក្រុមប្រឹក្សាជាអ្នកសង្កេតការណ៍។ អ្នកសង្កេតការណ៍ផ្សេងទៀត និងអ្នកជំនាញ ក៏អាចត្រូវអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំនេះ បានផងដែរ។

(៥) [ការងារ] ការងាររបស់សហភាពមានដូចជា:

(i) សិក្សាវិធានការសមស្របដើម្បីការពារផលប្រយោជន៍និងដើម្បីជំរុញការអភិវឌ្ឍន៍នៃសហភាព

(ii) បង្កើតបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន

(iii) ចាត់តាំងអគ្គលេខាធិការ និងប្រសិនបើចាំបាច់ ចាត់តាំង

អគ្គលេខាធិការរង និងកំណត់អំពីលក្ខខណ្ឌនៃការចាត់តាំង

(iv) ពិនិត្យរបាយការណ៍ប្រចាំឆ្នាំ ស្តីពី សកម្មភាពសហភាព និងដាក់ចេញកម្មវិធី សម្រាប់កិច្ចការទៅអនាគតរបស់ខ្លួន

(v) ផ្តល់សេចក្តីណែនាំចាំបាច់នានាដល់អគ្គលេខាធិការដើម្បីសម្រេចកិច្ចការរបស់សហភាព

(vi) បង្កើតបទបញ្ជារដ្ឋបាលនិងហិរញ្ញវត្ថុរបស់សហភាព

(vii) ពិនិត្យនិងអនុម័តថវិកាសហភាព និងកំណត់វិភាគទានរបស់សមាជិកនីមួយៗនៃ សហភាព

(viii) ពិនិត្យនិងអនុម័តគណនីដែលបានលើកឡើងដោយអគ្គលេខាធិការ

(ix) កំណត់កាលបរិច្ឆេទនិងទីកន្លែងសម្រាប់សន្និសីទដូចមានចែងក្នុងមាត្រា៣៨ និងចាត់វិធានការចាំបាច់សម្រាប់ការរៀបចំសន្និសីទ និង

(x) ជាទូទៅធ្វើសេចក្តីសម្រេចចាំបាច់នានាដើម្បីធានាឱ្យមានប្រសិទ្ធិភាពក្នុងការអនុវត្តន៍មុខងាររបស់សហភាព។

(៦) [ ការបោះឆ្នោត ] (ក) សមាជិកនីមួយៗនៃសហភាពដែលជារដ្ឋត្រូវមានសំលេងឆ្នោតមួយក្នុងក្រុមប្រឹក្សា។

(ខ) ភាគីហត្ថលេខីណាមួយ ដែលជាអង្គការអន្តររដ្ឋាភិបាលក្នុងបញ្ហាដែលជាសមត្ថកិច្ចរបស់ខ្លួន អាចអនុវត្តសិទ្ធិបោះឆ្នោតរបស់រដ្ឋសមាជិករបស់ខ្លួនដែលជាសមាជិកនៃសហភាព។ អង្គការអន្តររដ្ឋាភិបាលនេះ មិនត្រូវអនុវត្តសិទ្ធិបោះឆ្នោតរបស់រដ្ឋសមាជិករបស់ខ្លួនឡើយ ប្រសិនបើរដ្ឋសមាជិក បានអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួន។ ប្រសិនបើរដ្ឋសមាជិកមិនអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួននោះអង្គការអន្តររដ្ឋាភិបាលនេះ ត្រូវអនុវត្តសិទ្ធិបោះឆ្នោតរបស់រដ្ឋសមាជិករបស់ខ្លួន ។

(៧) [សំលេងភាគច្រើន] សេចក្តីសម្រេចណាមួយរបស់ក្រុមប្រឹក្សាទាមទារឱ្យមានសំលេងភាគច្រើនធម្មតានៃសំលេងឆ្នោតដែលបាន បោះ ។ប៉ុន្តែសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដែលមានចែងក្នុងកថាខណ្ឌទី(៥)(ii)(vi)និង(vii) និងក្នុងមាត្រា២៨(៣) មាត្រា២៩(៥)(ខ) និងមាត្រា៣៨(១) ទាមទារឱ្យមានសំលេង ៣/៤ (បីភាគបួន)នៃសំលេងឆ្នោតដែលបានបោះ។ អនុប្បវាទមិនចាត់ទុកជាសំលេងឆ្នោតទេ។

## មាត្រា២៧
## ការិយាល័យរបស់សហភាព

(១) [ការងារនិងការដឹកនាំរបស់ការិយាល័យ] ការិយាល័យនៃសហ-ភាពត្រូវអនុវត្តតួនាទី និងការងារទាំងអស់ដែលបានប្រគល់ឱ្យដោយក្រុមប្រឹក្សា។ ការិយាល័យត្រូវស្ថិតក្រោមការដឹកនាំរបស់អគ្គលេខាធិការ។

(២)[តួនាទីរបស់អគ្គលេខាធិការ] អគ្គលេខាធិការត្រូវទទួលខុសត្រូវចំពោះក្រុមប្រឹក្សា។ អគ្គលេខាធិការត្រូវទទួលខុសត្រូវក្នុងការអនុវត្តន៍សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។ អគ្គលេខាធិការត្រូវស្នើថវិកាសហភាពឱ្យក្រុមប្រឹក្សាអនុម័ត និងត្រូវទទួលខុសត្រូវលើការអនុវត្តន៍ថវិកា។ អគ្គ-លេខាធិការត្រូវធ្វើរបាយការណ៍ ស្តីពី ការគ្រប់គ្រង និងសកម្មភាពរបស់ខ្លួន និងស្ថានភាពហិរញ្ញវត្ថុនៃសហភាពទៅក្រុមប្រឹក្សា។

(៣) [ បុគ្គលិក ] លើកលែងតែបទប្បញ្ញត្តិនៃមាត្រា២៦(៥)(iii) លក្ខខណ្ឌនៃការចាត់តាំង និងការជួលបុគ្គលិកចាំបាច់សម្រាប់ប្រសិទ្ធភាពនៃការអនុវត្តន៍ការងារការិយាល័យនៃសហភាព ត្រូវបានកំណត់ក្នុងបទបញ្ជារដ្ឋបាលនិងហិរញ្ញវត្ថុ។

## មាត្រា២៨
## ភាសា

(១) [ភាសានៃការិយាល័យ] ភាសាអង់គ្លេស ភាសាបារាំង ភាសាអាល្លឺម៉ង់ និង ភាសាអេស្ប៉ាញ ត្រូវបានប្រើប្រាស់ដោយការិយាល័យនៃសហភាពក្នុងការអនុវត្តន៍តួនាទីរបស់ខ្លួន។

(២) [ភាសាក្នុងកិច្ចប្រជុំមួយចំនួន] កិច្ចប្រជុំក្រុមប្រឹក្សា និងកិច្ចប្រជុំសន្និសីទកែប្រែ ត្រូវធ្វើឡើងក្នុង៤(បួន)ភាសាខាងលើ។

(៣) [ភាសាផ្សេងៗទៀត] ក្រុមប្រឹក្សាអាចសម្រេចឱ្យប្រើភាសាផ្សេងៗទៀត។

## មាត្រា២៩
## ហិរញ្ញវត្ថុ

(១) [ចំនូល] រាល់ការចំណាយនៃសហភាព បានមកពីៈ

(i) វិភាគទានប្រចាំឆ្នាំរបស់រដ្ឋជាសមាជិកនៃសហភាព

(ii) កម្រៃដែលទទួលបានពីការផ្តល់សេវាកម្ម

(iii) ប្រាក់ចំនូលផ្សេងទៀត។

(២) [វិភាគទាន : ឯកតា ] (ក) ចំណែករបស់រដ្ឋជាសមាជិកនីមួយៗនៃសហភាពក្នុងចំនួនសរុបនៃវិភាគទានប្រចាំឆ្នាំ ត្រូវកំណត់ដោយយោងទៅលើការចំណាយសរុប ដែលបានពីវិភាគទាននៃរដ្ឋជាសមាជិកសហ-ភាព និងយោងទៅលើចំនួនឯកតាវិភាគទានដែលអនុវត្តចំពោះរដ្ឋនីមួយៗក្នុងកថាខណ្ឌទី(៣)។ ចំណែកនេះត្រូវគណនាតាមកថាខណ្ឌទី (៤)។

(ខ) ចំនួនឯកតាវិភាគទានត្រូវបង្ហាញជាចំនួនគត់ ឬប្រភាគ។ ប្រភាគមិនត្រូវតូចជាង១/៥(មួយភាគប្រាំ)ឡើយ។

(៣) [វិភាគទាន : ចំណែកនៃសមាជិកនីមួយៗ] (ក) ចំនួនឯកតាវិភាគទានដែលអនុវត្តចំពោះសមាជិកណាមួយនៃសហភាពដែលជាភាគីនៃច្បាប់ឆ្នាំ ១៩៦១ / ១៩៧២ ឬច្បាប់ឆ្នាំ ១៩៧៨ ត្រឹមកាលបរិច្ឆេទដែល

សមាជិកនេះចងភ្ជាប់ដោយអនុសញ្ញា ត្រូវដូចនឹងចំនួនដែលអនុវត្ត ទៅលើសមាជិកភ្លាមមុនកាលបរិច្ឆេទនេះ។

(ខ) រដ្ឋជាសមាជិកផ្សេងទៀតណាមួយនៃសហភាព ពេលចូលជាសមាជិកនៃសហភាព ត្រូវបង្ហាញចំនួនឯកតាវិភាគទានដែលអនុវត្តចំពោះខ្លួនក្នុងសេចក្តីប្រកាសដាក់ជូនអគ្គលេខាធិការ។

(គ) រដ្ឋជាសមាជិកណាមួយនៃសហភាព អាចបង្ហាញ នៅពេលណាក៏ដោយ ចំនួនឯកតាវិភាគទានផ្សេងពីចំនួនដែលអនុវត្តចំពោះខ្លួនក្នុងអនុកថាខណ្ឌ(ក)ឬ(ខ) ក្នុងសេចក្តីប្រកាសដាក់ជូនអគ្គលេខាធិការ។ សេចក្តីប្រកាសនេះ ប្រសិនបើធ្វើឡើងក្នុងអំឡុងពេល៦ (ប្រាំមួយ)ខែដំបូងនៃឆ្នាំប្រតិទិន ត្រូវចូលជាធរមានចាប់ពីដើមឆ្នាំប្រតិទិនបន្ទាប់ បើពុំនោះទេសេចក្តីប្រកាសនេះត្រូវចូលជាធរមានចាប់ពីដើមឆ្នាំប្រតិទិន ទីពីរបន្ទាប់ពីឆ្នាំដែលធ្វើសេចក្តីប្រកាស។

(៤) [វិភាគទាន : ការគណនានៃចំណែក ] (ក) ចំពោះរយៈពេលថវិកានីមួយៗ ចំនួនមួយឯកតាវិភាគទាន ត្រូវគណនាដោយយកចំនួនសរុបនៃចំណាយក្នុងរយៈពេលនោះដែលបានពីវិភាគទានរដ្ឋជាសមាជិកនៃសហភាព ចែកនឹងចំនួនឯកតាសរុបដែលអនុវត្តចំពោះរដ្ឋជាសមាជិកទាំងនោះនៃសហភាព។

(ខ) ចំនួនវិភាគទាននៃរដ្ឋជាសមាជិកនីមួយៗនៃសហភាព ត្រូវគណនាដោយយកចំនួនមួយឯកតាវិភាគទានគុណនឹងចំនួនឯកតា វិភាគទាន ដែលអនុវត្តចំពោះរដ្ឋជាសមាជិកនោះនៃសហភាព។

(៥) [ការយឺតយ៉ាវក្នុងការបង់វិភាគទាន] (ក) រដ្ឋជាសមាជិកមួយនៃសហភាពដែលយឺតយ៉ាវក្នុងការបង់វិភាគទាន លើកលែងតែអនុកថាខណ្ឌ(ខ) មិនអាចអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួនក្នុងក្រុមប្រឹក្សា ប្រសិនបើ ចំនួនប្រាក់ដែលមិនបានបង់ស្មើឬលើសពីចំនួនវិភាគទានដែលត្រូវបង់នាឆ្នាំមុនពេញមួយឆ្នាំ។ ការព្យួរសិទ្ធិបោះឆ្នោត មិនត្រូវឱ្យរដ្ឋជាសមា-

ជិកនៃសហភាពរួចផុតពីកាតព្វកិច្ចរបស់ខ្លួនក្នុងអនុសញ្ញានេះ និងមិនត្រូវដកហូតសិទ្ធិផ្សេងទៀតណាមួយរបស់រដ្ឋជាសមាជិកនោះឡើយ។

(ខ) ក្រុមប្រឹក្សាអាចអនុញ្ញាតឱ្យរដ្ឋជាសមាជិកនេះនៃសហភាពបន្តអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួនបាន ដរាបណាបានផ្តល់ហេតុផលត្រឹមត្រូវពីការយឺតយ៉ាវក្នុងការបង់វិភាគទាន ដោយកាលៈទេសៈពិសេស និងមិនអាចជៀសវាងបាន។

(៦) [សវនកម្មគណនី] សវនកម្មគណនីនៃសហភាពត្រូវធ្វើឡើងដោយរដ្ឋជាសមាជិកមួយនៃសហភាព ដូចមានចែងក្នុងបទបញ្ជារដ្ឋបាល និងហិរញ្ញវត្ថុ។ រដ្ឋជាសមាជិកនេះនៃសហភាពត្រូវបានចាត់តាំងដោយក្រុមប្រឹក្សា ដោយមានការយល់ព្រមពីរដ្ឋនេះ។

(៧) [វិភាគទាននៃអង្គការអន្តររដ្ឋាភិបាល] ភាគីហត្ថលេខីណាមួយដែលជាអង្គការអន្តររដ្ឋាភិបាល គ្មានកាតព្វកិច្ចបង់វិភាគទានទេ។ ប៉ុន្តែប្រសិនបើអង្គការអន្តររដ្ឋាភិបាលនេះយល់ព្រមបង់វិភាគទាន បទប្បញ្ញត្តិនៃកថាខណ្ឌទី(១)ដល់ទី(៤) ត្រូវយកមកអនុវត្ត។

## ជំពូកទី៩
## ការអនុវត្តន៍អនុសញ្ញា កិច្ចព្រមព្រៀងផ្សេងៗទៀត

### មាត្រា៣០
### ការអនុវត្តន៍អនុសញ្ញា

(១) [វិធានការអនុវត្ត] ភាគីហត្ថលេខីនីមួយៗ ត្រូវអនុម័តវិធានការដែលចាំបាច់ដើម្បីអនុវត្តអនុសញ្ញានេះ ជាពិសេស ភាគីហត្ថលេខីត្រូវៈ

(i) ចែងពីវិធានការដោះស្រាយផ្លូវច្បាប់សមរម្យដើម្បីការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព នៃសិទ្ធិអ្នកបង្កាត់ពូជដំណាំ

(ii) បង្កើតអាជ្ញាធរដែលទទួលកិច្ចការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ឬ ផ្តល់កិច្ចការនេះទៅអាជ្ញាធរដែលបង្កើតដោយភាគីហត្ថលេខីមួយផ្សេងទៀត

(iii) ធានាថា សាធារណជនត្រូវបានជូនដំណឹងតាមរយៈការបោះពុម្ពផ្សាយជាទៀងទាត់នូវព័ត៌មានដែលពាក់ព័ន្ធនឹង:

- ពាក្យស្នើសុំនិងការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ និង
- ការដាក់ឈ្មោះដែលបានស្នើឡើងនិងដែលបានយល់ព្រម។

(២) [ការអនុលោមតាមច្បាប់] ត្រូវយល់ថាការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិករបស់ខ្លួនតាមករណីនីមួយៗ រដ្ឋឬអង្គការអន្តររដ្ឋាភិបាលនីមួយៗត្រូវមានលទ្ធភាពតាមច្បាប់របស់ខ្លួនបង្កើតអានុភាពអនុវត្តដល់បទប្បញ្ញត្តិនៃអនុសញ្ញានេះ។

## មាត្រា៣១

## ទំនាក់ទំនងរវាងភាគីហត្ថលេខីនិងរដ្ឋដែលចងភ្ជាប់ដោយច្បាប់មុនៗ

(១) [ទំនាកទំនងរវាងរដ្ឋដែលចងភ្ជាប់ដោយអនុសញ្ញានេះ] រវាងរដ្ឋជាសមាជិកនៃសហភាពដែលចងភ្ជាប់ដោយអនុសញ្ញានេះ និងច្បាប់មុនៗណាមួយនៃអនុសញ្ញា មានតែអនុសញ្ញានេះទេដែលត្រូវអនុវត្ត។

(២) [ទំនាក់ទំនងដែលអាចមានជាមួយរដ្ឋដែលមិនចងភ្ជាប់ដោយអនុសញ្ញានេះ]សមាជិករដ្ឋណាមួយនៃសហភាពដែលមិនជាប់ កាតព្វកិច្ចដោយអនុសញ្ញានេះ អាចថ្លែងក្នុងសេចក្តីប្រកាសដាក់ជូន អគ្គលេខាធិការ ក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយសមាជិកណាមួយនៃសហភាពដែលចងភ្ជាប់ដោយអនុសញ្ញានេះ តែប៉ុណ្ណោះថាខ្លួននឹង អនុវត្តច្បាប់ក្រោយបំផុតដែលចងភ្ជាប់។ ចាប់ពីពេលផុតកំណត់១(មួយ) ខែបន្ទាប់

ពីកាលបរិច្ឆេទនៃការជូនដំណឹងនេះ និងរហូតដល់រដ្ឋជាសមាជិកនៃសហភាពដែលបានប្រកាសនោះ បានចងភ្ជាប់ដោយអនុសញ្ញានេះ សមាជិកនេះនៃសហភាព ត្រូវអនុវត្តច្បាប់ក្រោយបំផុតដែលខ្លួនបានចងភ្ជាប់ក្នុងទំនាក់ទំនង របស់ខ្លួនជាមួយសមាជិកនៃសហភាពនីមួយៗ ដែលចងភ្ជាប់ដោយអនុសញ្ញានេះតែប៉ុណ្ណោះហើយសមាជិកនៃសហភាពនីមួយៗនេះ ក៏ត្រូវអនុវត្តអនុសញ្ញានេះ ចំពោះសមាជិកដែលបានធ្វើសេចក្តីប្រកាសដែរ។

មាត្រា៣២

កិច្ចព្រមព្រៀងពិសេស

សមាជិកទាំងឡាយនៃសហភាពរក្សាសិទ្ធិបង្កើតកិច្ចព្រមព្រៀងពិសេសរវាងគ្នា ស្តីពី កិច្ចការពារពូជដំណាំ ឱ្យតែកិច្ចព្រមព្រៀងទាំងនេះមិនផ្ទុយនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

## ជំពូកទី១០

## អវសានប្បញ្ញត្តិ

មាត្រា៣៣

ការចុះហត្ថលេខា

អនុសញ្ញានេះត្រូវបើកចំហសម្រាប់ការចុះហត្ថលេខា ដោយរដ្ឋណាមួយដែលជាសមាជិកនៃសហភាពនៅកាលបរិច្ឆេទនៃការអនុម័តអនុសញ្ញានេះ។ អនុសញ្ញានេះនៅតែបើកចំហសម្រាប់ការចុះហត្ថលេខារហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩២។

មាត្រា៣៤

ការផ្តល់សច្ចាប័ន ការទទួលយកឬការយល់ព្រម ការចូលជាសមាជិក

(១) [រដ្ឋនិងអង្គការអន្តររដ្ឋាភិបាលមួយចំនួន] (ក) រដ្ឋណាមួយ អាចក្លាយជាភាគីនៃអនុសញ្ញានេះ ដូចមានចែងក្នុងមាត្រានេះ។

(ខ) អង្គការអន្តររដ្ឋាភិបាលណាមួយ អាចក្លាយជាភាគីនៃអនុសញ្ញានេះ ដូចមានចែងក្នុងមាត្រានេះ ប្រសិនបើអង្គការអន្តររដ្ឋាភិបាលនេះ :

(i) មានសមត្ថកិច្ចចំពោះបញ្ហាដែលគ្រប់គ្រងដោយអនុសញ្ញានេះ

(ii) មានច្បាប់ផ្ទាល់ខ្លួនដែលចែងពីការផ្តល់ និងកិច្ចការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ ដែលចងរដ្ឋសមាជិករបស់ខ្លួនទាំងអស់ និង

(iii) ត្រូវបានអនុញ្ញាតត្រឹមត្រូវ តាមនីតិវិធីផ្ទៃក្នុង ដើម្បីចូលជាសមាជិកនៃអនុសញ្ញានេះ។

(២) [លិខិតុបករណ៍នៃការចូលជាសមាជិក] រដ្ឋណាមួយដែលបានចុះហត្ថលេខាលើអនុសញ្ញានេះ ត្រូវក្លាយជាភាគីនៃអនុសញ្ញានេះ ដោយការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ឬការយល់ព្រមនៃអនុសញ្ញានេះ។ រដ្ឋណាមួយដែលមិនបានចុះហត្ថលេខាលើអនុសញ្ញានេះ និងអង្គការអន្តររដ្ឋាភិបាលណាមួយ ត្រូវក្លាយជាភាគីនៃអនុសញ្ញានេះ ដោយការតម្កល់លិខិតុបករណ៍នៃការចូលជាសមាជិកនៃអនុសញ្ញានេះ។ លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិក ត្រូវតម្កល់ជូនអគ្គលេខាធិការ។

(៣) [យោបល់នៃក្រុមប្រឹក្សា] រដ្ឋណាមួយដែលមិនមែនជាសមាជិកនៃសហភាពនិងអង្គការអន្តររដ្ឋាភិបាលណាមួយមុនពេលតម្កល់លិខិតុបករណ៍នៃការចូលជាសមាជិករបស់ខ្លួន ត្រូវសុំយោបល់ ពីក្រុមប្រឹក្សាអំពីអនុលោមភាពនៃច្បាប់របស់ខ្លួន ជាមួយបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ។ ប្រសិនបើសេចក្តីសម្រេចផ្តល់យោបល់មានលក្ខណៈវិជ្ជមានលើ

លិខិតុបករណ៍នៃការចូលជាសមាជិកអាចតម្កល់បាន។

## មាត្រា៣៥
## ខដាក់លក្ខខណ្ឌ

(១) [គោលការណ៍] លើកលែងតែកថាខណ្ឌទី(២) គ្មានខដាក់លក្ខខណ្ឌត្រូវបានអនុញ្ញាតចំពោះអនុសញ្ញានេះឡើយ។

(២) [ការលើកលែងដែលអាចមាន] (ក) ថ្វីបើមានចែងក្នុងបទប្បញ្ញត្តិនៃមាត្រា៣(១)ក៏ដោយនៅពេលក្លាយជាភាគីនៃអនុសញ្ញានេះ ក៏រដ្ឋណាមួយដែលជាភាគីនៃច្បាប់ឆ្នាំ១៩៧៨ចំពោះពូជដំណាំដែលត្រូវបានផលិតឡើងវិញដោយអភេទ ហើយដែលចែងពីកិច្ចការពារដោយកម្មសិទ្ធិឧស្សាហកម្មផ្សេងពីសិទ្ធិអ្នកបង្កាត់ពូជដំណាំ ត្រូវមានសិទ្ធិបន្តធ្វើដូច្នេះ ដោយមិនអនុវត្តអនុសញ្ញានេះចំពោះពូជដំណាំទាំងនេះឡើយ។

(ខ) នៅពេលតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិក តាមករណីនីមួយៗ រដ្ឋណាមួយដែលប្រើប្រាស់នូវសិទ្ធិខាងលើ ត្រូវជូនដំណឹងទៅអគ្គលេខាធិការ។ រដ្ឋនេះអាចដកការជូនដំណឹងនេះនៅពេលណាក៏បាន។

## មាត្រា៣៦
## ទំនាក់ទំនងចំពោះច្បាប់ និង អំបូរនិងប្រភេទពូជដែលបានការពារ ព័ត៌មានដែលត្រូវការបោះពុម្ពផ្សាយ

(១) [ការជូនដំណឹងដំបូង] នៅពេលតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ឬ ការយល់ព្រម ឬការចូលជាសមាជិកនៃអនុសញ្ញានេះ តាមករណីនីមួយៗ រដ្ឋឬអង្គការអន្តររដ្ឋាភិបាលណាមួយត្រូវជូនដំណឹងដល់អគ្គលេខាធិការនូវៈ

(i) ច្បាប់របស់ខ្លួនដែលគ្រប់គ្រងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និង

(ii) បញ្ជីអំបូរ និងប្រភេទពូជដំណាំដែលត្រូវអនុវត្តបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះត្រឹមកាលបរិច្ឆេទ ដែលចងភ្ជាប់ដោយអនុសញ្ញានេះ។

(២) [ការជូនដំណឹងពីការផ្លាស់ប្តូរ] ភាគីហត្ថលេខីនីមួយៗត្រូវជូនដំណឹងភ្លាមទៅអគ្គលេខាធិការពី:

(i) ការផ្លាស់ប្តូរណាមួយក្នុងច្បាប់របស់ខ្លួនដែលគ្រប់គ្រងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និង

(ii) ការពង្រីកវិសាលភាពអនុវត្តនៃអនុសញ្ញានេះចំពោះអំបូរ និងប្រភេទពូជដំណាំបន្ថែម។

(៣) [ការបោះពុម្ពផ្សាយព័ត៌មាន] ផ្អែកលើកទំនាក់ទំនងដែលទទួលបានពីភាគីហត្ថលេខីពាក់ព័ន្ធនីមួយៗ អគ្គលេខាធិការត្រូវបោះពុម្ពផ្សាយព័ត៌មានស្តីពី:

(i) ច្បាប់ដែលគ្រប់គ្រងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងការផ្លាស់ប្តូរណាមួយក្នុងច្បាប់នេះ និង

(ii) បញ្ជីអំបូរនិងប្រភេទពូជដំណាំដូចមានចែងក្នុងកថាខណ្ឌទី(១)(ii) និងការពង្រីកវិសាលភាពណាមួយដូចមានចែងក្នុងកថាខណ្ឌទី(២)(ii)។

## មាត្រា៣៧

## ការចូលជាធរមាន ការបិទច្បាប់មុនៗ

(១) [ការចូលជាធរមានដំបូង] អនុសញ្ញានេះ ត្រូវចូលជាធរមាន១(មួយ)ខែបន្ទាប់ពីរដ្ឋប្រាំបានតម្កល់លិខិតុបករណ៍នៃ ការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិករបស់ខ្លួន តាមករណីនីមួយៗ ឱ្យតែយ៉ាងហោចណាស់លិខិតុបករណ៍ចំនួនបី ត្រូវបានតម្កល់ដោយរដ្ឋជាភាគីច្បាប់ឆ្នាំ១៩៦១/១៩៧២ ឬ ច្បាប់ឆ្នាំ១៩៧៨។

(២) [ការចូលជាធរមានបន្ទាប់]រដ្ឋណាមួយដែលមិនគ្រប់គ្រងដោយ

កថាខណ្ឌទី(១) ឬ អង្គការអន្តររដ្ឋាភិបាលណាមួយត្រូវចងភ្ជាប់ដោយអនុសញ្ញានេះ ១(មួយ)ខែ បន្ទាប់ពីកាលបរិច្ឆេទដែលបានតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិករបស់ខ្លួន តាមករណីនីមួយៗ។

(៣) [ការបិទច្បាប់ឆ្នាំ១៩៧៨] លិខិតុបករណ៍នៃការចូលជាសមាជិកនៃច្បាប់ឆ្នាំ១៩៧៨ មិនអាចតម្កល់ បន្ទាប់ពីការចូលជាធរមាននៃអនុសញ្ញានេះតាមកថាខណ្ឌទី(១)លើកលែងតែរដ្ឋណាមួយ ដែលស្របតាមការអនុវត្តន៍ពីមុននៃមហាសន្និបាតអង្គការសហប្រជាជាតិ ដែលត្រូវចាត់ទុកជាប្រទេសកំពុងអភិវឌ្ឍ អាចតម្កល់លិខិតុបករណ៍នេះរហូតដល់ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ១៩៩៥ ហើយរដ្ឋណាមួយផ្សេងទៀតអាចតម្កល់លិខិតុបករណ៍នេះរហូតដល់ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ១៩៩៣ ទោះបីបើអនុសញ្ញានេះចូលជាធរមានមុនកាលបរិច្ឆេទនេះក៏ដោយ។

## មាត្រា៣៨
## ការកែប្រែអនុសញ្ញា

(១) [សន្និសីទ]អនុសញ្ញានេះអាចកែប្រែដោយសន្និសីទនៃសមាជិកសហភាព។ ការកោះប្រជុំសន្និសីទនេះ ត្រូវសម្រេចដោយក្រុមប្រឹក្សា។

(២) [កូរ៉ុម និងសំលេងភាគច្រើន] សន្និសីទអាចដំណើរការទៅបានលុះត្រាតែយ៉ាងហោចណាស់មានរដ្ឋជាសមាជិកនៃសហភាពពាក់កណ្តាលបានចូលរួមក្នុងសន្និសីទនេះ។ ការអនុម័តលើការកែប្រែណាមួយទាមទារឱ្យមានសំលេងភាគច្រើន៣/៤(បីភាគបួន) នៃរដ្ឋជាសមាជិកនៃសហភាពដែលមានវត្តមាន និងដែលបានបោះឆ្នោតក្នុសន្និសីទ។

## មាត្រា៣៩
## ការប្រកាសដកខ្លួនចេញ

